D59681

TSL

M

M.122

Moeng Teng dit Moeng Sam Mang

[illegible]

[illegible]

[illegible]

[illegible] 22.3.78 39 ans

រួចហើយ ថាច់ ទីវ ក៏បានបញ្ចូលខ្ញុំជាសមាជិកខ្មែរសេរី នៅចុងឆ្នាំ១៩៥៨ ចូលនៅវត្តមហាមន្ត្រី ដោយថាច់ ទីវ ជាអ្នកឧទ្ទេសនាម ហើយលោកគ្រូថាច់ ពៀង ជាអ្នកទទួលស្គាល់ ។ ពេលចូលនោះគ្មានកម្មវិធីត្រឹមត្រូវទេ គឺថាច់ ទីវ និងលោកគ្រូថាច់ ពៀង ណែនាំភារកិច្ច ឱ្យខ្ញុំអនុវត្តតែម្តង ។ ភារកិច្ចទាំងនោះគឺ:

១- ឱ្យខ្ញុំ ខិតខំកសាងកម្លាំង ដើម្បីពង្រីកជួរខ្មែរសេរី

២- ឱ្យខ្ញុំ តាមដានពិនិត្យរកខ្មែរក្រហម ដើម្បីបោសសំអាត

រួចហើយ ថាច់ ទីវ និងថាច់ ពៀង បានណែនាំឱ្យខ្ញុំស្គាល់កម្លាំងខ្មែរសេរីមួយចំនួន ដែលនៅកុដិជាមួយគ្នា ដើម្បីទាក់ទងធ្វើការងារ ។ កម្លាំងខាងផ្នែកលោកសង្ឃមាន :

១- ថាច់ កើត　　　　　　３- ថាច់ ចើង

២- ថាច់ យុង　　　　　　៤- ថាច់ យួន

ឯកម្លាំងខាងយុវជន ដែលមកពីកម្ពុជាក្រោមដែរ មាន:

១- ថាច់ យាន　　　２- ថាច់ នាគ　　　៣- គីម សោម៉ាន

ឆ្នាំ១៩៥៩ ខ្ញុំបានកសាងកម្លាំងយុវជននៅក្នុងវត្តមហាមន្ត្រី បាន២នាក់ ។ យុវជនទាំង២នោះ ស្នាក់នៅកុដិជិតខ្ញុំដែរ ហើយរាប់អានគ្នាស្និតស្នាល ។ ហើយយុវជនទាំង២នោះ គឺ:

១- អ៊ុន សាមុត　　　　　２- ថាន់

ចំណុចខ្សោយរបស់អ្នកទាំង២នោះ គឺជាកូនអ្នកធូរធា ចូលចិត្តលេងល្បែងភ្លើតភ្លើនហ៊ឺហា ស៊ីចាយដែលខ្ញុំអប់រំអូសទាញបញ្ចូលបានមកក្នុងខ្សែខ្មែរសេរីរបស់ខ្ញុំ នៅឆ្នាំ១៩៥៩ ។ រួចហើយ ខ្ញុំក៏បាន រាយការណ៍អំពីកម្លាំងនេះ ឱ្យថាច់ ទីវ និងថាច់ ពៀង ហើយបន្ទាប់មក គាត់ក៏បានណែនាំឱ្យខ្ញុំខិតខំក្តាប់ និងពង្រឹងកម្លាំងនោះឱ្យរឹងមាំ ហើយឱ្យខិតខំពង្រីកកម្លាំងតទៅទៀត ។ ថាច់ ទីវបានណែនាំខ្ញុំអំពីកម្លាំងដែលកសាងបាន គឺផ្នែកយុវជនត្រូវបញ្ជូនទៅចូលទ័ពនៅក្នុងព្រៃ តាមព្រំដែនកម្លាំងមួយផ្នែកទៀត សំរាប់នៅបង្កប់ខាងក្នុងប្រទេស ដើម្បីធ្វើសកម្មភាពប្រឆាំងស៊ីហនុ និងដើម្បីតាមដានរកកម្លាំងខ្មែរក្រហម ដើម្បីបោសសំអាត ។

ហើយនៅឆ្នាំ១៩៥៩នោះ ខ្ញុំត្រូវរកការធ្វើ ពេលនោះខ្ញុំប្រឡងខាងជួសជុល យន្តហោះ ប្រឡងខាងក្រសួងគិញ្ចា និងខាងប៉ូលិសក្រុង ហើយខ្ញុំបានប្រឡងជាប់ទាំង៣ក្រសួង តែខ្ញុំចូលធ្វើខាងប៉ូលិសក្រុង ក្នុងឆ្នាំ១៩៦០ ។ ពេលនោះរាជការក្រុងបានឱ្យខ្ញុំទៅធ្វើខាងក្រសួង

១៧.៧.៧៨

ម៉ុង តេង

តុបតែងក្រុង ភារៈខាងគូរផ្លង់ផ្ទះវិញ ។ ហើយខ្ញុំ ក៏នៅធ្វើការខាងគូរផ្លង់នៅសាលាក្រុង រហូតមក តាំងពីឆ្នាំ១៩៦០ ។

ឆ្នាំ១៩៦០នោះ ខ្ញុំកសាងកម្លាំងនៅក្នុងក្រសួងប៉ូលិសក្រុង បាន២នាក់ គឺ:

១- មាស ផេង ២- អ៊ុង សាមឿន

បន្ទាប់មក ខ្ញុំបានណែនាំភារកិច្ចឱ្យអ្នកទាំង២នោះអនុវត្ត គឺ:

១- ឱ្យខិតខំកសាងពង្រីកកម្លាំង នៅក្នុងប៉ូលិសក្រុងបន្តទៀត

២- ឱ្យខិតខំពិនិត្យតាមដានរកខ្មែរក្រហមដែលបង្កប់នៅភ្នំពេញ

រួចហើយ ខ្ញុំក៏បានជួបថាច់ វ៉ែវ ដើម្បីរាយការណ៍អំពីកម្លាំងនៅក្នុងក្រសួងប៉ូលិសក្រុងទាំង២ ដែលខ្ញុំក្តាប់ និងកសាងបាន ។ ហើយ ថាច់ វ៉ែវ បានណែនាំខ្ញុំឱ្យខិតខំពង្រឹងកម្លាំងនេះ ឱ្យតាមដានសកម្មភាពខ្មែរក្រហម ដែលលួចខិតប័ណ្ណនៅក្នុងក្រុង ពេលយប់ ។

ឆ្នាំ១៩៦១ ខ្ញុំកសាងកម្លាំងនៅក្នុងក្រសួងប៉ូលិសក្រុងបានម្នាក់ទៀត គឺឈ្មោះឌុស ហឿង រួចហើយ ខ្ញុំក៏បានណែនាំភារកិច្ចឱ្យ ឌុស ហឿងអនុវត្ត គឺដូចភារកិច្ចដែលបានណែនាំកម្លាំងខាងលើដែរ ។ ហើយ ខ្ញុំបានណែនាំ ឌុស ហឿង ឱ្យស្គាល់កម្លាំងនៅក្នុងក្រសួងប៉ូលិសក្រុង ដែលនៅ ក្នុងខ្សែខ្មែរសេរីជាមួយគ្នា គឺមាស ផេង និង អ៊ុង សាមឿន ដើម្បីទាក់ទងធ្វើការងារ ។ រួចហើយ ខ្ញុំក៏បានរាយការណ៍អំពីកម្លាំងដែលទើបកសាងបាននេះ ឱ្យថាច់ វ៉ែវក្តាប់បានទៀត រួចគាត់ក៏បានជំរុញខ្ញុំ ឱ្យខិតខំកសាងកម្លាំងនៅក្នុងក្រសួងប៉ូលិសក្រុងនេះតទៅទៀត ។

ឆ្នាំ១៩៦២ អ៊ុង សាមឿន បានជួបរាយការណ៍អំពីកម្លាំងដែលកសាងបានឱ្យខ្ញុំដឹង គឺ:

១- សួស សាវិន ២- ញ៉ែម តាមិ

កម្លាំងទាំង២នេះ សុទ្ធតែជាប៉ូលិសក្រុងដែរ ដែលអ៊ុង សាមឿន បានទាក់ទងអប់រំអូសទាញ ចូល
១៧.៧.៧៨ មកក្នុងខ្សែខ្មែរសេរី នៅឆ្នាំ១៩៦២ ។ រួចហើយ ខ្ញុំបានណែនាំអ៊ុង សាមឿន ឱ្យខិតខំ ពង្រឹងកម្លាំងដែលកសាងបាននេះ និងខំកសាងពង្រីកកម្លាំងនៅក្នុងក្រសួងប៉ូលិសក្រុងថែមទៀត ដើម្បីត្រៀមកម្លាំងធំ សំរាប់សំរេចផែនការរបស់ចលនាខ្មែរសេរីនៅថ្ងៃខាងមុខ ។
ម៉ុង តេង

ឆ្នាំ១៩៦៣ ខ្ញុំបានអប់រំកសាងកម្លាំងនៅក្នុងក្រសួងតុបតែងក្រុង បាន៣នាក់ គឺ:

១- ប៊ុត សារ៉ាត ២- ទន់ គន្ធរ៉ូ ៣- អ៊ឹម ភិម

អ្នកទាំង៣នេះ មានភារកិច្ចខាងគូរផ្លង់២នាក់ និងខាងផ្លង់តុងម្នាក់ ដែលសុទ្ធជាអ្នកជូរធា[illegible]

បន្ទាប់មក ខ្ញុំបានណែនាំភារកិច្ច ឱ្យអ្នកទាំង៣នោះអនុវត្ត ដូចភារកិច្ចដែលខ្ញុំបានណែនាំខាងផ្នែកកម្លាំងនៅក្រសួងប៉ូលិស ក្រុងដែរ ។ តែខ្ញុំបានសង្កត់ពីភារកិច្ចតាមដានរកកម្លាំងខ្មែរក្រហម នៅក្នុងក្រសួងតុបតែងក្រុង ព្រោះមានកម្លាំងកម្មករច្រើននៅក្នុងក្រសួងនេះ ដែលខ្មែរក្រហមយកធ្វើជាមូលដ្ឋាន ។ រួចហើយ ខ្ញុំក៏បានរាយការណ៍អំពីកម្លាំងទាំង៣នេះឱ្យថាច់ វ៉ែ ក្តាប់បានទៀត ថាច់ វ៉ែ ក៏បានណែនាំខ្ញុំបន្ថែមទៀត ឱ្យចូលបង្កប់នៅក្នុងចលនារបស់ពួកខ្មែរក្រហម បើ បានរកឃើញខ្សែពួកនេះហើយ ដើម្បីបោសសំអាតក្នុងផែនការយូរអង្វែង ។

ឆ្នាំ១៩៦៣ ខ្ញុំបានជួបទូច សារឿម នៅក្រុមល្ខោនជាតិ ។ ជាគោលបំណង គឺដើម្បីអូសទាញគាត់ឱ្យចូលក្នុងខ្សែខ្មែរសេរីជាមួយខ្ញុំ ។ តែពេលនោះ គាត់បានណែនាំអូសទាញខ្ញុំឱ្យចូលក្នុងខ្សែសេអ៊ីអាជាមួយគាត់វិញ ដោយទូច សារឿមបានបញ្ជាក់ប្រាប់ខ្ញុំអំពីខ្លួនគាត់ នៅក្នុងខ្សែសេអ៊ីអារបស់ហង់ធុនហាក់ ។ ទូច សារឿម និងខ្ញុំ ស្គាល់រាប់អានគ្នាជិតស្និតណាស់ ពីនៅធ្វើការក្នុងក្រសួងពេទ្យជាមួយគ្នា កាលពីឆ្នាំ១៩៥៨ ។ បន្ទាប់មក ខ្ញុំក៏បានយល់ស្របតាមការណែនាំអូសទាញរបស់ទូច សារឿម។ ហើយខ្ញុំបានទៅរាយការណ៍ស្នើយោបល់ ថាច់ វ៉ែ និងថាច់ពឿង រួចគាត់ក៏យល់ព្រមតាមការស្នើរបស់ខ្ញុំ ហើយក៏បានឧទ្ទេសនាមរូបខ្ញុំឱ្យទៅទូច សារឿម ។ ថាច់ វ៉ែ ក៏ស្គាល់ទូច សារឿមដែរ ដោយធ្លាប់នៅវិត្តមហាមន្ត្រី កុដិជិតខ្ញុំដែរ ។ រួចហើយ ខ្ញុំក៏បានចូលក្នុងខ្សែសេអ៊ីអាជាមួយទូច សារឿម ដែលចូលនៅផ្ទះរបស់គាត់នៅខាងលិចពេទ្យចិន នៅក្នុងឆ្នាំ១៩៦៣ ។ ពេលចូលនោះ គ្មានពិធីត្រឹមត្រូវទេ គឺទូច សារឿម ណែនាំភារកិច្ច-ឱ្យខ្ញុំអនុវត្តតែម្តង គឺ:

១ - ឱ្យខិតខំកសាងពង្រីកកម្លាំងឱ្យបានច្រើនទៀត

២ - ឱ្យខិតខំពិនិត្យតាមដានរកកម្លាំង និងមូលដ្ឋានរបស់ខ្មែរក្រហម

១៧.៧.៧៨ ៣ - ឱ្យចូលបង្កប់ក្នុងចលនាខ្មែរក្រហមបើពិនិត្យឃើញ ដើម្បីរកស្គាល់មេដឹកនាំ

៤ - រស់នៅទីណា ឱ្យបំផុសការលេបប្រយុទ្ធការពារ

ម៉ុង តេង

រួចហើយ ទូច សារឿមបានណែនាំឱ្យខ្ញុំស្គាល់កម្លាំងក្នុងខ្សែសេអ៊ីអារបស់ទូច សារឿម ដើម្បីទាក់ទងធ្វើសកម្មភាពតាមភារកិច្ចដែលគាត់បានណែនាំ ។ កម្លាំងមួយចំនួននោះ គឺ:

១ - មាស សំអ៊ែល ២ - សាលឹម ៣ - សួសហន

រួចហើយ ខ្ញុំបានឱ្យទូលនាមកម្លាំងមួយចំនួនក្នុងខ្សែរខ្មែរសេរីដែលខ្ញុំកសាងបាន ដើម្បីនាំមកឱ្យ ទួចលាទៀមក្តាប់បាន ហើយបញ្ចូលក្នុងខ្សែរស៊េអ៊ីអារបស់គាត់វិញ ។ កម្លាំងទាំងអស់នោះគឺ យុវជននៅវិទ្យាល័យមហាមន្ត្រី២នាក់ ប៉ូលិសក្រុង៥នាក់ និងបុគ្គលិកក្រសួងគុបដែនក្រុង៣នាក់ ។ ទួចលាទៀមក៏បានទទួលកម្លាំងទាំងនោះ ហើយបានណែនាំខ្ញុំ ឱ្យពិតខំពង្រឹងកម្លាំងនោះឱ្យខ្លាំងទៀត ក្នុងការលបប្លាយហ៊ុយហា និងឱ្យខំពិនិត្យតាមដានសកម្មភាពខ្មែរក្រហម និងរកកម្លាំងខ្មែរក្រហមដើម្បីធ្វើឃាត ។

បន្ទាប់មក ខ្ញុំបានទៅជួបកម្លាំងនៅវិទ្យាល័យមហាមន្ត្រី គឺអ៊ុន សាមុត និងថាន់ ដើម្បីណែនាំ និងពង្រឹងជំហរ ។ ពេលនោះ ឈ្មោះថាន់ បានរាយការណ៍ឱ្យខ្ញុំដឹងអំពីកម្លាំងដែលកសាងបាននៅក្នុងវិទ្យាល័យមហាមន្ត្រី គឺ:

១- ឈ្មោះ អ៊ុំ ២- ឈ្មោះ សុវណ្ណ

អ្នកទាំង២នេះជាយុវជនម្នាក់នៅភូមិជាមួយថាន់ ហើយប្រុកកំណើតនៅកំពង់ស្ពឺជាមួយគ្នាទៀត ហើយស្រលាញ់ជិតស្និតជាមួយថាន់ ស្តាប់ការណែនាំរបស់គាត់ ហើយឈ្មោះអ៊ុំ និងសុវណ្ណ ចូលចិត្តលបប្លាយភ្លើតភ្លើនហ៊ុយហា ដែលឈ្មោះថាន់អប់រំកូលទាញកសាងបានបញ្ចូលមកក្នុងខ្សែរស៊េអ៊ីអារបស់ខ្ញុំនៅក្នុងឆ្នាំ១៩៦៣ ។ រួចហើយ ខ្ញុំក៏បានណែនាំថាន់ ឱ្យក្តាប់និងពង្រឹងកម្លាំងនេះ ដោយបំផុសឱ្យធ្វើសកម្មភាពលបប្លាយហ៊ុយហា ហើយឱ្យខំពិនិត្យខ្មែរក្រហមនៅក្នុងវិទ្យាល័យមហាមន្ត្រី ទាំងក្នុងយុវជន ទាំងក្នុងលោកសង្ឃ ។

ហើយក្នុងរយៈ ពីឆ្នាំ១៩៦១ ដល់១៩៦៤ ខ្ញុំបានស្លៀតពេលយប់ ដើម្បីទៅរៀនសាលាឈ្នួល ។ ពេលនោះ ខ្ញុំរៀននៅសាលាមុខផ្សារទឹកល្អក់បាន២ខែ ខ្ញុំក៏ទៅរៀននៅសាលាគារស៊ីនៅផ្លូវមុនីវង្សខាងជើងពេទ្យចិនវិញ ។ ហើយដល់ឆ្នាំ១៩៦៥ ខ្ញុំបានប្រឡងជាប់ សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ។ ក្នុងរយៈរៀននោះ ខ្ញុំបានជិតស្និតស្រលាញ់រាប់អានជាមួយយុវជន

១៧.៣.៧៨ ៣នាក់ដែលនៅរៀនជាមួយគ្នា ហើយខ្ញុំក៏បានណែនាំអប់រំកូលទាញបញ្ចូលបានមកក្នុងខ្សែរ ស៊េអ៊ីអារបស់ខ្ញុំនៅក្នុងឆ្នាំ១៩៦៤ ។ យុវជនទាំង៣នាក់នោះគឺ:

ម៉ុង ទេង

១- កិច ចុងប៊ួន ២- ពិសិដ ៣- ហ៊ុយ

មូលហេតុកសាងបាន ដោយយុវជនទាំង៣នោះសុទ្ធជាកូនអ្នកធូរធា អំនួតមុខមាត់ហើយចូលចិត្តលបប្លាយហ៊ុយហា ភ្លើតភ្លើន ។

រួចហើយ ខ្ញុំបានណែនាំភារកិច្ច ឱ្យអ្នកទាំង៣នោះអនុវត្ត គឺ៖

១- ឱ្យខិតខំពិនិត្យតាមដានមើលសកម្មភាពខ្មែរក្រហមនៅក្នុងសាលា

២- ឱ្យបំផុសការលបប្លាយភ្លើតភ្លើនហ៊ុហានៅក្នុងសាលា

ឆ្នាំ ១៩៦៥ ខ្ញុំបានទាក់ទងជាមួយសាស្ត្រាចារ្យម្នាក់ឈ្មោះកង យុំ ។ ឈ្មោះនេះ - ត្រូវជាសាច់ញាតិខាងប្រពន្ធខ្ញុំ ។ ពេលនោះ ជាគោលបំណងខ្ញុំ គឺដើម្បីអូសទាញកង យុំនេះ ឱ្យចូលក្នុងខ្សែសេរីអាជាមួយខ្ញុំ ។ ខ្ញុំបានរាយការណ៍អំពីខ្សែរបស់ខ្ញុំជាមួយទូច សារឿម ខាងល្វានជាតិ ឱ្យកង យុំភ្ជាប់បាន ។ ពេលនោះ គាត់ក៏បានបញ្ជាក់ប្រាប់ខ្ញុំ គឺខ្លួនគាត់ជាខ្សែសេ-រីអា នៅក្នុងខ្សែរបស់ម៉ែកវ លន់ និងក្រាហិការនៅសាលាស៊ីសុវត្ថិ ។ ហើយគាត់ ក៏បាន ណែនាំអូសទាញខ្ញុំឱ្យចូលក្នុងខ្សែរបស់គាត់វិញ ។ ខ្ញុំក៏យល់ស្របតាមការណែនាំរបស់គាត់ ជាមូលហេតុដោយគាត់ត្រូវជាសាច់ញាតិនឹងខ្ញុំ ហើយនៅជិតគ្នាផង ងាយស្រួលក្នុងការទាក់ទងធ្វើការងារ ឯទូច សារឿម ច្រើនចេញទៅបេសកកម្មនៅខែត្រក្រៅ ពិបាកក្នុងការទាក់ទង ។
បន្ទាប់មក ខ្ញុំក៏បានទៅជួបទូច សារឿម ដើម្បីរាយការណ៍អំពីការទាក់ទងជាប់ខ្សែថ្មីរបស់ខ្ញុំជាមួយ កង យុំ ។ ទូច សារឿមយល់ព្រមតាមសេចក្តីស្នើរបស់ខ្ញុំ ហើយក៏បានឧទ្ទុសនាមរូបខ្ញុំ ឱ្យមកកង យុំ ហើយគាត់ក៏ស្គាល់កង យុំដែរ ដោយធ្លាប់ជួបគ្នានៅផ្ទះខ្ញុំ ។
ខ្ញុំ បានជាប់ខ្សែទាក់ទង ក្នុងខ្សែសេរីអាជាមួយ កង យុំវិញ នៅក្នុងឆ្នាំ១៩៦៥ ។ បន្ទាប់មក គាត់ក៏បានណែនាំភារកិច្ចឱ្យខ្ញុំអនុវត្ត ដូចទូច សារឿមបានណែនាំខ្ញុំដែរ ។ រួចហើយ គាត់ ក៏បានណែនាំខ្ញុំឱ្យស្គាល់ឈ្មោះអ៊ុក តាត ជាកម្លាំងក្នុងខ្សែសេរីអារបស់គាត់ ដើម្បីទាក់ទងធ្វើការ ។ បន្ទាប់មក ខ្ញុំក៏បានរាយការណ៍អំពីកម្លាំងទាំងអស់ដែលខ្ញុំកសាងបាន ដើម្បីឱ្យគាត់ភ្ជាប់បានហើយទទួលស្គាល់ក្នុងខ្សែរបស់គាត់វិញ ។ កម្លាំងទាំងនោះ គឺយុវជននៅវត្តមហាមន្ត្រី៤នាក់ទាំងខ្សែបន្ត
១៧.៧.៧៨ ផង នៅក្នុងក្រសួងប៉ូលិសក្រុង៥នាក់ នៅក្រសួងតុបតែងក្រុង៣នាក់ និងយុវជនសិស្ស នៅសាលាតារារស្មី៣នាក់ ។ បន្ទាប់មក កង យុំ ក៏បានណែនាំខ្ញុំឱ្យខិតខំពង្រឹងកម្លាំងដែលកសាងបានរួចហើយ
ម៉ុង តេង នោះ ដោយបំផុសឱ្យសបប្លាយហ៊ុហាឱ្យខ្លាំង ហើយឱ្យខំពិនិត្យតាមដានរកខ្មែរក្រហម ដើម្បីបោសសំអាត ។

ឆ្នាំ ១៩៦៦ ខ្ញុំបានជួបទាក់ទងជាមួយអ្នកចំរើនម្នាក់ឈ្មោះបងសឿន ។

បងសឿន ជាខ្មែរក្រហម មានភារៈដឹកនាំសម្ងាត់នៅក្នុងកម្មករក្រសួងតុបតែងក្រុង ។ ហើយពេលនោះ គាត់នៅសង់ផ្ទះក្នុងការដ្ឋានសំណង់របស់ឈ្មោះ លុយ បានហាប់ នៅតាមផ្លូវ មុនីវង្ស ម្តុំបឹងត្របែក ហើយខ្ញុំត្រូវគូរផ្លង់នៅក្នុងការដ្ឋានសំណង់នោះដែរ ។

ពេលនោះ បងសឿន បានអប់រំខ្ញុំឱ្យយល់បដិវត្ត ហើយអូសទាញខ្ញុំឱ្យចូលក្នុងចលនាខ្មែរក្រហម ជាមួយគាត់ដែរ ។ ខ្ញុំ ក៏យល់ព្រមតាមការណែនាំអូសទាញរបស់បងសឿន ព្រោះស្របតាមបំណងនិងផែនការរបស់ខ្ញុំដែលត្រូវចូលទៅបង្កប់នៅក្នុងចលនាខ្មែរក្រហមនោះ ។ រួចហើយ ក៏បងសឿន បានណែនាំឱ្យខ្ញុំស្គាល់កម្លាំងនៅក្នុងខ្សែរបស់គាត់ ដែលធ្វើការនៅក្នុងកម្មករសំណង់ របស់លុយ បានហាប់ដែរដើម្បីទាក់ទងធ្វើការងារ :

១- ចិក ឈិន　　　២- សំរ៉ង　　　៣- ងនស្រ៊ី

បន្ទាប់មក ខ្ញុំក៏បានទៅជួប កង ឈុំ ដើម្បីរាយការណ៍អំពីសភាពការណ៍ដែលខ្ញុំបានទាក់ទងចូលទៅបង្កប់នៅក្នុងក្រុមខ្មែរក្រហម នៅក្នុងការដ្ឋានសំណង់របស់ លុយ បានហាប់ ។ កង ឈុំ ក៏ណែនាំខ្ញុំបន្ថែមឱ្យខិតខំអនុវត្តភារកិច្ចរបស់ខ្មែរក្រហម ដើម្បីឱ្យមានការទុកចិត្តពីឈ្មោះសឿន សំរាប់ផែនការបង្កប់យូរអង្វែង ដើម្បីស៊ីជំរៅ ក្តាប់ឱ្យបានច្រើននូវកម្លាំងខ្មែរក្រហម ហើយក្តាប់ឱ្យបានទាំងក្បាលម៉ាស៊ីនដឹកនាំខាងលើរបស់ឈ្មោះសឿនថែមទៀត ព្រមទាំងក្តាប់ ឱ្យបានមូលដ្ឋានសំខាន់របស់ក្រុមខ្មែរក្រហមនេះទៀត ដើម្បីបោសសំអាតនៅថ្ងៃខាងមុខ ។

រួចហើយ កង ឈុំ បានណែនាំខ្ញុំឱ្យខំធ្វើការងារអូសទាញកសាងកម្លាំងនៅក្នុងក្រុមនោះ ដើម្បីពង្រីកកម្លាំងនៅក្នុងក្រុមខ្មែរក្រហមតែម្តង ។

បន្ទាប់មក ខ្ញុំក៏បានជាប់សកម្មភាពក្នុងចលនាខ្មែរក្រហមជាមួយបងសឿន រួចខ្ញុំក៏បានណែនាំអប់រំ ហើយអូសទាញកម្លាំងពីក្នុងក្រុមបងសឿន បានម្នាក់ឈ្មោះសំរ៉ងមកជាកម្លាំងក្នុងខ្សែ សេស៊ីអារបស់ខ្ញុំវិញ ។ រួចហើយ ខ្ញុំក៏បានជួបបងសឿន ដើម្បីបញ្ចូលកម្លាំងក្នុងខ្សែរបស់ខ្ញុំម្នាក់ទៀតឈ្មោះឈាងលីជូ ឱ្យចូលបង្កប់ក្នុងក្រុមរបស់គាត់ដែរ ។ បងសឿន ក៏យល់ព្រមតាមការស្នើ របស់ខ្ញុំ ដោយបងសឿនក៏ស្គាល់ឈាងលីជូស្រាប់ ព្រោះធ្វើការនៅក្នុងកម្មករសំណង់ជាមួយគ្នា ។

១៧.៧.៧៨
ម៉ុង តេង

ឆ្នាំ ១៩៦៨ ខ្ញុំត្រូវខ្មាំងចាប់ដាក់គុក ពេលនោះខ្មាំងចាប់បានទាំងអស់ គឺ រួបខ្ញុំ ចិកឈិន សំរ៉ង ងនស្រ៊ី និងឈាងលីជូ លើកលែងតែបងសឿនដែលបានគេចខ្លួនទាន់ ។

មូលហេតុខ្មាំងចាប់បាន ដោយឈ្មោះងនស្រ៊ី និងឈាងលីជូ បានទៅចូលរួមបាចខិតប័ណ្ណជាមួយខ្មែរផង នៅខាងទឹកល្អក់ ហើយត្រូវពួកខ្មាំងចាប់បាន ក្នុងពេលកំពុងធ្វើសកម្មភាពបាចខិតប័ណ្ណ ។ ហើយងនស្រ៊ី និងឈាងលីជូ បានឆ្លើយប្រាប់ខ្មាំង អំពីកម្លាំងទាំងអស់នៅក្នុងខ្សែរបស់បងសឿន ។

នៅក្នុងគុកខ្មាំង ខ្ញុំបានធ្វើសកម្មភាពបំផុសការស៊ីផឹកសប្បាយ ដើម្បីអូសទាញកម្លាំងចំរើនមួយចំនួន គឺៈ ១- សុខ ឡាយ ២- មាស សារឿន ៣- សំ ណុំ ៤- សឿន

កម្លាំងទាំងនេះ សុទ្ធតែជាប់ពីបទធ្វើសកម្មភាពបំរើចលនាបដិវត្ត ហើយត្រូវខ្ញុំទាក់ទងកេ្សកកិតអូសទាញបាន ឱ្យគិតតែពីការស៊ីផឹក ស្រា-ទឹកត្នោតជូ សប្បាយនៅក្នុងគុកខ្មាំង ។

ឆ្នាំ ១៩៦៩ ខ្ញុំត្រូវចេញពីគុកខ្មាំងវិញ ហើយចូលទៅធ្វើការនៅក្រសួងប៉ូលិសក្រុងវិញ ដោយខ្មាំងចាប់យកទៅដាក់គុក គ្មានភស្តុតាង ត្រូវបានរួចពីបទចោទ ។ ពេលនោះ ខ្ញុំបានជួបទាក់ទងជាមួយកង យុំ ឡើងវិញ ហើយគាត់ក៏បានណែនាំខ្ញុំឱ្យជួបកម្លាំងទាំងអស់ ដើម្បីណែនាំពង្រឹងថែម ពិសេសខំតាមដានសកម្មភាពខ្មែរក្រហម ដែលកំពុងតែមានសកម្មភាពខ្លាំងគ្រប់ទីកន្លែង ។

បន្ទាប់មក ខ្ញុំបានជួបឈ្មោះ ប៉ិត សារ៉ាត នៅក្រសួងតុបតែងក្រុង ពេលនោះ -គាត់ក៏បានរាយការណ៍ឱ្យខ្ញុំដឹង អំពីកម្លាំងដែលកសាងបាន២នាក់ គឺៈ

១- ហង់ ផាន់ ២- ភោគ ពី

អ្នកទាំង២នេះ ធ្វើការនៅក្នុងក្រសួងតុបតែងក្រុងដែរ ហើយត្រូវជាសាច់ញាតិរបស់ ប៉ិត-សារ៉ាត ស្តាប់ការណែនាំរបស់គាត់ ដែលគាត់បានអប់រំកសាងបញ្ចូលមកក្នុងខ្សែរសេអ៊ីអា របស់ខ្ញុំ នៅក្នុងឆ្នាំ ១៩៦៩ ។ រួចហើយ ខ្ញុំក៏បានណែនាំប៉ិត សារ៉ាត ឱ្យជំរុញកម្លាំងនេះ ខំតាមដានរកកម្លាំងខ្មែរក្រហម ។ ព្រោះ សព្វថ្ងៃខ្មែរក្រហមកំពុងធ្វើសកម្មភាពកាន់តែខ្លាំងនៅក្នុងក្រុង
១៣.៣.៧៨ ដើម្បីទប់ស្កាត់ និងកំទេចកម្លាំងចលនាខ្មែរក្រហមនេះឱ្យទាន់ពេល កុំឱ្យរីករាលបាន ។

១០៦

បន្ទាប់មក ខ្ញុំបានទៅជួបសួរសុខទុក្ខ ថាច់រ៉ែវ និងលោកគ្រូ ថាច់ញៀង នៅវត្ត
ម៉ុង ពេង មហាមន្ត្រី ។ ពេលនោះ ខ្ញុំបានជួបថាច់រ៉ែវ ហើយខ្ញុំរាយការណ៍អំពីផ្ទាល់ខ្លួនខ្ញុំ ដែលជួបគ្រោះ-ថ្នាក់កាលពីឆ្នាំ១៩៦៨ ធ្វើឱ្យខូចខាតពេលវេលាក្នុងសកម្មភាពការងារ ។ បន្ទាប់មក គាត់ក៏បានឱ្យខ្ញុំដឹងអំពីកម្លាំងនៅក្នុងក្រុមត្រូវបែកគ្នា គឺថាច់ញៀង ថាច់ហេង និងថាច់ឃួន ទាំងពួកនេះទៅនៅបាត់ដំបង ។

យុវជនតឹម យ៉ាតាំន ចូលធ្វើខាងបូលិសខែត្រ ចំណែកយុវជនថាច់យ៉ាន និងថាច់នាត ត្រូវបាន -
បញ្ជូនឱ្យទៅចូលកងទ័ពខាងកងវេ្រងឈននៅក្នុងព្រៃរួចហើយ ។ នៅសល់តែលោកគ្រូ ថាច់កើត
និងថាច់យុង ដែលនៅក្នុងវត្តមហាមន្ត្រីសព្វថ្ងៃ ។ រួចហើយ ថាច់ទីវ បានឱ្យខ្ញុំនឹងអ៊ីពីកម្លាំង ផ្នែក
ខាងលោកសង្ឃដែលទើបកសាងបានបន្តិចទៀត គឺលោកគ្រូយ៉ង់ និងមួយអង្គទៀតខ្ញុំភ្លេចឈ្មោះ
នៅកុដិជិតគ្នាដែរ ។ បន្ទាប់មក គាត់បានណែនាំខ្ញុំថែម ឱ្យខិតខំជំរុញចលនាឱ្យខ្លាំងទៀត -
ដើម្បីទប់ទល់ កំចាត់ចលនាខ្មែរក្រហមដែលជាពួកកុម្មុយនិស្តឱ្យបាន ។ គាត់បានជំរុញខ្ញុំ ជាសំខាន់
គឺខំក្តាប់កម្លាំងដែលកសាងបានហើយ រួចជំរុញឱ្យខិតខំធ្វើសកម្មភាពតាមដានរកខ្មែរក្រហម ហើយ
ឱ្យខិតខំកសាងកម្លាំងឱ្យបានច្រើនស្អេកស្កះតទៅទៀត ដើម្បីមានកម្លាំងធំ សំរាប់វាយ កំចាត់
ពួកខ្មែរក្រហម ។

ឆ្នាំ ១៩៦៩ ខ្ញុំបានអប់រំកសាងឈ្មោះម៉ុងរ៉ែត បញ្ចូលមកក្នុងខ្សែរសេអ៊ីអារបស់ខ្ញុំ ។
ម៉ុងរ៉ែត ហៅម៉ុងសំនិត ជាប្អូនរបស់ខ្ញុំ ហើយបានមកនៅភ្នំពេញជាមួយខ្ញុំ ដើម្បីរៀនសូត្រ ដែល
នៅឆ្នាំ១៩៦៩នោះ វាអាយុបាន១៨ឆ្នាំ ហើយរៀនដល់ថ្នាក់ទី៣ ។ ខ្ញុំអប់រំវា នៅផ្ទះ ម្តាយធំ
ខាងប្រពន្ធខ្ញុំនៅទួលស្វាយព្រៃ ដែលខ្ញុំបានសុំសំណាក់ ។
ខ្លឹមសារអប់រំ គឺខ្ញុំបានណែនាំឱ្យវាយល់ អំពីរបបកុម្មុយនិស្ត ដែលមានការកៀបត្បៀត ជិះជាន់
សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ធ្វើឱ្យលំបាកវេទនាក្រៃពេកហាម ហើយបង្ខិតបង្ខំឱ្យធ្វើការដូច
សត្វធាតុ ។ រួចហើយ ខ្ញុំបានណែនាំវាឱ្យឃើញអំពីរបបលោកសេរី ដែលប្រជាពលរដ្ឋ មានសិទ្ធិ
សេរីភាពគ្រប់បែបយ៉ាង រស់នៅមានការសប្បាយហ៊ឺហា ហើយម្នាក់ៗចង់ធ្វើអ្វីបានតាមបំណង របស់
ខ្លួន ។ យុវជន ដែលបានខិតខំរៀនសូត្រ ហើយមានការចេះដឹងខ្ពស់ៗ អាចយកវិជ្ជារបស់ខ្លួន -
១៧.៧.៧៨ ទៅកសាងសុភមង្គលឱ្យខ្លួន និងគ្រួសារខ្លួនបានយ៉ាងថ្លៃថ្នូរ ។
ម៉ុង តេង
រួចហើយ ខ្ញុំក៏បានណែនាំភារកិច្ច ឱ្យម៉ុង រ៉ែត អនុវត្ត គឺ:

១- ឱ្យខំកសាងកម្លាំងបន្តទៀត នៅក្នុងចំណោមសិស្ស

២- ឱ្យខំពិនិត្យ តាមដានរកកម្លាំងខ្មែរក្រហមនៅក្នុងសាលា ដើម្បីបោសសំអាត

បន្ទាប់មក ខ្ញុំក៏បានណែនាំឱ្យវាស្គាល់កម្លាំងខាងលើក្នុងខ្សែរសេអ៊ីអារបស់ខ្ញុំមួយចំនួន ដើម្បីឱ្យ
វាទាក់ទងធ្វើការងារ គឺ:កង យ៉ុ សាស្ត្រាចារ្យ និងទូច សារឿម នៅខាងស្ពានជាតិ។

រួចហើយ ខ្ញុំបានរាយការណ៍ពីកម្លាំងថ្មី គឺម៉ុងរ៉េត ដែលខ្ញុំទើបកសាងបញ្ចូលមក ក្នុងខ្សែរបស់ខ្ញុំ - នៅក្នុងឆ្នាំ ១៩៦៩នេះ ឱ្យ កង ឃុំក្តាប់បាន និងដើម្បីទទួលស្គាល់ក្នុងខ្សែសេអ៊ីអារបស់គាត់ ។

ខែ ៥-១៩៦៩ ក្រោយពីខ្ញុំរួចពីគុកខ្មាំងវិញ ខ្ញុំបានទៅលេងស្រុកកំណើតនៅ ខាងកោះធំ ។ ពេលនោះ ខ្ញុំបានជួបឈ្មោះទៀវលិញ ជាឪពុកមាររបស់ខ្ញុំ ។ ហើយទៀវលិញ ក៏មានការកៀកកិតជាមួយខ្ញុំហើយពេលមុនៗ បានជួបគ្នាស៊ីផឹកនៅក្នុងពេលចូលឆ្នាំខ្មែរ សប្បាយរាល់ថ្ងៃជាមួយគ្នា ។ គាត់ក៏កាន់តែបានយល់ជំហររបស់ខ្ញុំ ហើយក៏បានពិភាក្សាគ្នា ពេលនោះ ខ្ញុំក៏បានលើកបញ្ជាក់ឱ្យគាត់ដឹង អំពីហេតុផលដែលខ្ញុំបានជាប់គុកពីបទធ្វើជាខ្មែរក្រហម ដែលជាផែនការបង្កប់របស់ខ្ញុំ ដើម្បីតាមដានរកខ្មែរក្រហម ។ បន្ទាប់មក ខ្ញុំក៏បានរាយការណ៍ពីខ្សែរបស់ខ្ញុំ ជាមួយកង ឃុំ នៅភ្នំពេញ ។

រួចហើយ ទៀវលិញ ក៏បានណែនាំខ្ញុំ ឱ្យចូលក្នុងខ្សែរនៅជនបទជាមួយគាត់វិញ ។ គាត់ ក៏បានបញ្ជាក់ប្រាប់ខ្ញុំ អំពីខ្សែរបស់គាត់ជាមួយគ្រូសុខ ដែលជាខ្សែសេអ៊ីអាដែរ ហើយបង្កប់ក្នុង ចលនាខ្មែរក្រហមនៅក្នុងជនបទ ។ គាត់បានណែនាំហេតុផលឱ្យខ្ញុំដឹង អំពីការដែលឱ្យខ្ញុំភ្ជាប់ខ្សែជាមួយគាត់វិញនេះ គឺងាយក្នុងការកសាងពង្រីកកម្លាំងនៅជនបទ ពិសេសក្នុងស្រុកកោះធំ ដែលជាស្រុកកំណើតរបស់ខ្ញុំ ហើយខ្ញុំមានឈ្មោះជាខ្មែរក្រហមស្រាប់ ។ ខ្ញុំបានយល់ស្របតាមការដែលគាត់ណែនាំ ហើយគាត់ក៏បាននាំខ្ញុំទៅជួបគ្រូសុខ នៅឃុំពោធិបាន រួចគាត់ក៏បានឧទ្ទេសនាមរូបខ្ញុំ ឱ្យគ្រូសុខទទួលស្គាល់ ។ គ្រូសុខ ក៏បានទទួលស្គាល់ខ្ញុំ ជាប់ខ្សែទាក់ទងជាមួយគាត់ក្នុងខែ៥-១៩៦៩ ។ បន្ទាប់មក ខ្ញុំក៏បានត្រឡប់មកភ្នំពេញវិញ ហើយខ្ញុំទៅជួប កង ឃុំ ដើម្បីរាយការណ៍ពីការទាក់ទងរបស់ខ្ញុំ ជាមួយខ្សែបង្កប់នៅជនបទ ក្នុងខែត្រកណ្តាល ដែលជាខ្សែរបស់ឪពុកមាររបស់ខ្ញុំ ឈ្មោះទៀវលិញ ហើយដែលមានឈ្មោះគ្រូសុខ ជាខ្សែដឹកនាំខាងលើ ។ កង ឃុំ ក៏បានយល់ស្រប

១៧.៧.៧៨ តាមសេចក្តីរាយការណ៍នេះរបស់ខ្ញុំ ព្រោះកង ឃុំ បានឃើញសារសំខាន់ក្នុងការរៀបចំ ពង្រីកកម្លាំងនៅជនបទ ដើម្បីត្រៀមកំទេចបដិវត្តទៅថ្ងៃខាងមុខ ។

ម៉ុង តេង ដើមឆ្នាំ ១៩៧០ ខ្ញុំបានឧទ្ទេសនាម ម៉ុងរ៉េត ឱ្យកង ឃុំក្តាប់ និងគ្រប់គ្រងផ្ទាល់ដោយ វាត្រូវចូលរៀនថ្នាក់ទី២នៅសាលាចំការមន ។ ហើយគ្រូកងឃុំ ជាចាងហ្វាងសាលាចំការមន - នោះ ។

ហើយឆ្នាំ ១៩៧០នោះ ម៉ុងរ៉េត បានរាយការណ៍ឱ្យខ្ញុំដឹងអំពីសកម្មភាពកសាងកម្លាំង ។

ម៉ុង ទិត បានកសាងអូសទាញយុវជន បាន២នាក់បញ្ចូលមកក្នុងខែ្សរយៈអ៊ីអារបស់ខ្ញុំ គឺ:

១- ឈ្មោះ ជួង ចំរើន ហៅបុកជួ

២- " ច័ន្ទា

អ្នកទាំង២នេះ សុទ្ធតែស្រឡាញ់រាប់អានជិតដិតជាមួយ ម៉ុង ទិត ។ ហើយ ជួងចំរើនត្រូវជាសាច់ញាតិខាងប្រពន្ធខ្ញុំ ឯច័ន្ទាត្រូវជាប្អូនរបស់មាសផេង ដែលជាសាច់ញាតិ របស់ខ្ញុំដែរ ហើយយុវជនទាំង២នេះ ចូលចិត្តសប្បាយហ៊ឺហា មុខមាត់ ដែលម៉ុង ទិត អប់រំអូសទាញ បញ្ចូលបានមកក្នុងខែ្សរយៈអ៊ីអារបស់ខ្ញុំ នៅក្នុងឆ្នាំ ១៩៧០ ។

ហើយកន្លាំងទាំង២នេះ ខ្ញុំក៏បានរាយការណ៍ឱ្យកង ឈុំ ក្តាប់បានរួចហើយ ។

ខែ ៣-១៩៧០ មានរដ្ឋប្រហាររបស់អាលន់ណុល ខ្ញុំបានពិភាក្សាជាមួយកង ឈុំ ដើម្បីឱ្យម៉ុងទិត ចុះទៅបង្កប់ក្នុងបដិវត្ត គឺឱ្យទៅជួបទាក់ទងជាប់ខែ្សជាមួយវៀលលិញ ដែលជាខែ្សរបស់ខ្ញុំ ។ គាត់ក៏បានយល់ស្របតាមការស្នើរបស់ខ្ញុំ ហើយដល់ខែ៤-១៩៧០ ខ្ញុំក៏បានណែនាំឱ្យ - ម៉ុងទិត ចុះទៅស្រុកកោះធំ ដើម្បីជួបវៀលលិញ និងគ្រួសុខ ។

ខែ ៩-១៩៧០ ខ្ញុំបានពិភាក្សាជាមួយកង ឈុំទៀត ដោយខ្លួនផ្ទាល់ត្រូវចុះទៅមូលដ្ឋានបដិវត្ត ដើម្បីចូលបង្កប់ក្នុងបដិវត្តឱ្យបានទាន់ពេល ។ គាត់ក៏យល់ស្របតាមការស្នើ របស់ខ្ញុំទៀត តែគាត់ឥតស្គាល់ វៀលលិញ និងគ្រួសុខ ដែលជាខែ្សថ្មីរបស់ខ្ញុំទេ គឺក្តាប់បាន តាមខ្ញុំរាយការណ៍ ។

ចុងខែ១៩-១៩៧០ ខ្ញុំក៏បានចុះទៅដល់ស្រុកកោះធំ ហើយក៏បានទៅជួប វៀលលិញ រួចគាត់និងខ្ញុំ ក៏បានទៅជួបគ្រួសុខ នៅមន្ទីររបស់គាត់ នៅព្រែកដើមផ្តី ឃុំពោធិបាន ស្រុកកោះធំ ។ ពេលនោះ គ្រួសុខ បានចាត់តាំងខ្ញុំ ជាប្រធានសន្តិសុខស្រុកកោះធំ ។ ចំណែក ម៉ុងទិត គ្រួសុខ

១៧.៧.៧៨ បានចាត់តាំងជាពេទ្យកងទ័ពតំបន់២៥ ។

ខ្ញុំបានទទួលការចាត់តាំងពីគ្រួសុខ នៅក្នុងខែ១០-១៩៧១ ។ រួចហើយគាត់បានណែនាំភារកិច្ច ឱ្យខ្ញុំអនុវត្ត គឺ:

ម៉ុង តេង

១- ឱ្យខ្ញុំ អនុវត្តបំផ្លែចាត់ចែកឱ្យដាច់

២- ឱ្យខ្ញុំ បំផុសស្ដីអ៊ីមាតម៍ ស្រី-ស្រា ភារីវ៉ាសែ ឱ្យខូចមាគ៌ារបស់បក្ស

៣- ឱ្យទំពិនិត្យតាមផ្លូវ កន្លែងដែលចេញពីក្រុងភ្នំពេញ ដើម្បីចាប់ឈ្លបអាត

បន្ទាប់មក គ្រូសុខបានណែនាំខ្ញុំ ឱ្យស្គាល់កម្លាំងមួយចំនួននៅក្នុងតំបន់ដើម្បីទាក់ទងធ្វើការងារ ។ កម្លាំងទាំងនោះ មាន៖

១- សុខ ប៊ុតចំរើន
២- ហួត សេ
៣- ហ៊ុយ
៤- គ្រូជាង ទៅចៅសឹក
៥- គ្រូហ៊ាង ទៅស្ទួចពិសី
៦- កាត ទៅចិន្ត ណារេន
៧- ញ៉ី ប៊ុន

ខែ ១-១៩៧១ ខ្ញុំបានជួបទាក់ទង សុខប៊ុតចំរើន ដើម្បីធ្វើសកម្មភាពបង្ក្រាបឈ្មួញ-ទុច្ចរិតដែលបានសឹកជញ្ជូនគោ និងជ្រូកទៅតំបន់ខ្មាំង ។ ពេលនោះ សុខប៊ុតចំរើន បានណែនាំខ្ញុំ ឱ្យអនុវត្ត គឺចំពោះជ្រូកឱ្យរឹបអូសយកមកមន្ទីរ កាប់យកសាច់ចែកគ្នាស៊ី ។ ចំណែកគោ ឱ្យបង់ប្រាក់ពិន័យពី៥.០០០រ. ទៅ១០.០០០រ.ក្នុងគោមួយក្បាល រួចដោះលែងវិញ ។ ចំពោះអ្នកគ្មានប្រាក់បង់ពិន័យ ត្រូវរឹបអូសយកគោ ។
ជាគោលបំណង គឺដើម្បីឱ្យប្រជាជនក្តៅក្រហាយចំពោះបដិវត្ត ឃើញគេរៀបលក្ខណ៍ ប្រជាជនធ្ងន់ជាងរបបសង្គមចាស់ ។
បន្ទាប់មក ខ្ញុំក៏បានចាត់តាំងកម្លាំងសន្តិសុខ ឱ្យចេញធ្វើសកម្មភាពបង្ក្រាបឈ្មួញ តាមការណែនាំរបស់ សុខប៊ុតចំរើន ហើយបានសំរេចតាមផែនការនេះជាច្រើន ដែលធ្វើឱ្យប្រជាជន ក្តៅក្រហាយចំពោះបដិវត្តយ៉ាងខ្លាំង ។ ពេលនោះ បានសំរេចជាប្រាក់ពិន័យ ជាច្រើនសែនរៀល ហើយបានប្រគល់ឱ្យ សុខប៊ុតចំរើនហើយ ឯគោដែលរឹបអូស ក៏បានជាច្រើនក្បាល ។ ចំណែកជ្រូកទាំងតូច ទាំងធំ រឹបអូសបានជាច្រើនក្បាល ។
ហើយពេលនោះ គ្រូជាង ដែលជាប្រធានមន្ទីរតំបន់២៥ ក៏បានជួបណែនាំខ្ញុំបន្ថែម ឱ្យយក ជ្រូក
១៧.៧.៧៨ ដែលរឹបអូសបានកាប់យកសាច់ចែកគ្នាស៊ីនៅតាមមន្ទីរ ។ ជាគោលបំណង ដើម្បីឱ្យប្រជាជន-ឃើញ ហើយស្អប់ខ្ពើម និងក្តៅក្រហាយចំពោះអង្គការ ។ បន្ទាប់មក ខ្ញុំក៏បានឱ្យយុទ្ធជន កាប់
ម៉ឹង តេង ជ្រូក ហើយចែកគ្នាតាមមន្ទីរ ស៊ើររាល់ថ្ងៃ ។

ខែ ១-១៩៧១នោះដែរ ខ្ញុំបានជួបទាក់ទង ហួតសេ ដើម្បីធ្វើសកម្មភាព បង្ក្រាបពួកលេងល្បែងស៊ីសង ។ ពេលនោះ ហួតសេ បានណែនាំឱ្យខ្ញុំ ចាប់ឃាត់ខ្លួន អ្នកលេងល្បែងស៊ីសង-

ហើយឱ្យបង់ប្រាក់ពិន័យក្នុងម្នាក់ៗចំនួន៣.០០០រ. ហើយដោះលែងវិញ ។ ពេលនោះ ខ្ញុំក៏មានវិធានការចាប់បានអ្នកលេងបៀបន្តបន្ទាប់ ហើយឱ្យបង់ប្រាក់តាមការណែនាំរបស់ពួកគេ បានជាច្រើនម៉ឺនទៀត រួចបានយកទៅប្រគល់ឱ្យពួកគេ នៅសន្តិសុខតំបន់ ។

ខែ១១-១៩៧១នោះ ឈ្មោះប្រជាងបានប្រគល់កម្លាំងក្នុងខ្សែរបស់គាត់ម្នាក់ ឈ្មោះទិ ហៅគង់ តាមសេចក្តីស្នើរបស់ខ្ញុំ ដើម្បីបានជាកម្លាំង រួមសកម្មភាពក្នុងសន្តិសុខស្រុក ព្រោះទើបចាត់តាំងថ្មី នៅខ្វះកម្លាំង ។ ពេលនោះ ខ្ញុំបានទទួលឈ្មោះទិ មកសន្តិសុខ ហើយឱ្យក្តាប់កងទ័ពសន្តិសុខជាមួយ ហ៊ូចេវ ។

ហើយនៅដើមឆ្នាំ១៩៧១នោះ ខ្ញុំបានអប់រំកសាងកម្លាំងក្នុងខ្សែក្បត់របស់ខ្ញុំ បាន ៧នាក់ គឺ:

១- ហ៊ូ ចេវ　　៣- សោម ជួ ហៅសានិត　　៥- ហ៊ិន ហៅគង់

២- ហម ម៉េង　　៤- ឃិន កិចទៀង ហៅម៉េង　　៦- គីមផាង "នារី"

៧- គីមឃី .

កម្លាំងទាំង៧នេះ ខ្ញុំបានប្រមូលយកមកក្តាប់នៅសន្តិសុខស្រុក ហើយខ្ញុំបានអប់រំអូសទាញ រួចបញ្ចូលក្នុងខ្សែសេអ៊ីអារបស់ខ្ញុំ ។ ជាចំណុចខ្សោយ គឺអ្នកទាំងនេះ មានធាតុសេរី ភ្លើតភ្លើន មុខមាត់បុណ្យស័ក្តិ ហើយជាកូនអ្នកធូរធា ។ បន្ទាប់មក ខ្ញុំបានបំផុសកម្លាំងនេះ ឱ្យអារ៉ាវែសខាងសិលធម៌នារី ។ រួចឈ្មោះចេវ និងនារីគីមផាង ក៏បានទាក់ទងខូចសិលធម៌និងគ្នា ។

ក្នុងខែ២.១៩៧១ ខ្ញុំបានទាក់ទងខូចសិលធម៌ ជាមួយនារីម្នាក់ឈ្មោះស៊ាងហេង ។ នារីនេះ ជាពេទ្យនៅក្នុងសន្តិសុខ ។ នារីនេះ ភូមិកំណើតនៅជិតខ្ញុំ ស្គាល់គ្នាជិតស្និត ហើយមកធ្វើការនៅក្នុងសន្តិសុខជាមួយគ្នា កាន់តែកៀកកិត ស្និតស្នាលគ្នាខ្លាំងទៀត រួច
១៨.៧.៧៨ នារីនេះ ជាកូនអ្នកធូរធា ចូលចិត្តសប្បាយលេងសើច ភ្លើតភ្លើនសំភារៈ ខ្ញុំក៏អូសទាញ ហើយខូចសិលធម៌ជាមួយគ្នា ។ បន្ទាប់មក ខ្ញុំក៏បានទាក់ទងគ្រូសុខ ដកនារីនេះឱ្យទៅមូល-
ម៉ឹង តេង ដ្ឋានវិញ ដើម្បីការពារកុំឱ្យបែករឿងខូចសិលធម៌នេះ ។

បន្ទាប់មក ខ្ញុំបានទៅជួប ម៉ឹងទែត នៅមន្ទីរពេទ្យរបស់កងទ័ពតំបន់ ដែលស្នាក់នៅភូមិស្វាយតាមេឃ ក្នុងឃុំកោះធំ ។ ពេលនោះ វាឱ្យខ្ញុំដឹងអំពីកម្លាំងដែលកសាងបាន ។

កម្លាំងទាំងនោះ មាន :

១- ឈ្មោះ ជួ ពេទ្យតំបន់ ៤- ឈ្មោះ គាង នារីពេទ្យតំបន់
២- " ខួយ សេដ្ឋកិច្ចតំបន់ ៥- " សៅ "
៣- " គា កងទ័ពតំបន់

មូលហេតុកសាងបាន ដោយអ្នកទាំងនេះមានចំណុចខ្សោយដូចកម្លាំងដែលខ្ញុំកសាងដែរ ដែល ម៉ឹងតែ អប់រំអូសទាញបញ្ចូលបាន មកក្នុងខ្សែរបស់ខ្ញុំ នៅខែ ២.១៩៧១ ។
រួចហើយ ខ្ញុំបានណែនាំ ម៉ឹងតែ ឱ្យបំផុសបាតុភាពសីលធម៌អាវ៉ាសែ នៅក្នុងពេទ្យឱ្យខ្លាំង រវាង យុទ្ធជន និងនារីពេទ្យ ។ ហើយខ្ញុំណែនាំឱ្យវាបំផុសបុគ្គលិកពេទ្យ ធ្វើសកម្មភាពអុកឡុកអ្នក-ជំងឺក្នុងមន្ទីរពេទ្យ ដោយវិធីមិនយកចិត្តទុកដាក់ព្យាបាល ។

ខែ២.១៩៧១ ឈ្មោះប្រាជ្ញបានទៅជួបណែនាំខ្ញុំ នៅមន្ទីរសន្តិសុខស្រុក នៅភូមិ-ស្វាយតាមេឃ ក្នុងឃុំកោះធំ ។ ពេលនោះ គាត់បានឱ្យខ្ញុំ ទាក់ទងប្រមូលអ្នកតស៊ូ នៅក្នុង-សម័យវាយចក្រពត្របារាំង មកចូលរួមការងារបដិវត្តន៍ឡើងវិញ ។ គាត់បានបញ្ជាក់ឱ្យខ្ញុំដឹង អំពីកម្លាំងនេះ សុទ្ធជាកម្លាំងក្នុងសម័យវៀតណាមគ្រប់គ្រងចាត់តាំង ដែលអាចប្រមូលយកមក-ជាកម្លាំងក្បត់ក្នុងខ្សែរបស់តំបន់២៥បច្ចុប្បន្ន ដើម្បីរួមកម្លាំងធ្វើសកម្មភាពបានខ្លាំង ត្រៀម-វាយបដិវត្តទៅថ្ងៃមុខ ។
រួចហើយ ខ្ញុំបានធ្វើការទាក់ទង តាមការណែនាំរបស់គាត់ ដែលពេលនោះ ខ្ញុំទាក់ទងបាន២-នាក់ គឺឈ្មោះតាក់ ហៅសុគន្ធ និងឈ្មោះឃើន ហៅសែម សូរៀ ។
ហើយ ខ្ញុំក៏បាននាំអ្នកទាំង២ ប្រគល់ទៅឈ្មោះប្រាជ្ញ នៅមន្ទីរតំបន់ ។
បន្ទាប់មក ខែ៤.១៩៧១ សុខបុំតចំរើន និងគ្រូសុខ បានចាត់តាំងអ្នកទាំង២នេះ ជាគណៈ-ស្រុកកោះធំ គឺឈ្មោះតាក់ ទទួលជាប្រធានស្រុក ហើយឈ្មោះឃើន ទទួលជាអនុប្រធាន ។

ខែ ៤.១៩៧១ ខ្ញុំបានទាក់ទងខូចសីលធម៌ ជាមួយនារីម្នាក់ឈ្មោះ គឹមយី ។
នារីនេះ ធ្វើការនៅក្នុងសន្តិសុខស្រុក ដែលខ្ញុំបានប្រមូលយកមកក្តាប់នៅក្នុងមន្ទីរតាំងពីឆ្នាំ-១៩៧០ ។
រួចបន្ទាប់មក ខ្ញុំក៏បានអប់រំអូសទាញបញ្ចូលបាន មកក្នុងខ្សែរបស់ខ្ញុំ ។ ហើយ ខ្ញុំ និងនារីគឹមយី កាន់តែមានការស្និតស្នាលនិងគ្នា រហូតបានខូចសីលធម៌ ជាមួយគ្នា ។
នារី គឹមយី ជាស្រីមេម៉ាយ អាយុជិត៣០ឆ្នាំ តែគ្មានកូនទេ ហើយបានលែងលះប្តី តាំងពីក្នុងសង្គមចាស់ម្ល៉េះ ។

១៨.៧.៧៨
ម៉ុង តេង

ហើយនារីឈ្មោះគីមយីនេះ ជាអ្នកធូរធា ធ្លាប់មានគ្រួសារធ្វើជានាម៉ឺនពីសង្គមចាស់-ចូលចិត្តសប្បាយហ៊ឺហា ដែលខ្ញុំទាក់ទងខូចសីលធម៌ជាមួយគ្នាបាន ។ រួចហើយ ខ្ញុំក៏បានទាក់ទង-គ្រូហ៊ាង ឱ្យយកនារីនេះទៅសន្តិសុខតំបន់ បំបែកគ្នាកុំឱ្យបែករឿងរបស់ខ្ញុំទាន់ ។

ខែ៤.១៩៧១នោះ នៅពេលបុណ្យចូលឆ្នាំខ្មែរ ឈ្មោះជ្រាងបានទទួលការណែនាំពីគ្រូសុខ និងសុខប៊ុតចំរើន ឱ្យរៀបចំពិធីជប់លៀង ។ ពេលនោះ គាត់ក៏បានរៀបចំនៅភូមិសំប៉ានលើ ឃុំព្រែកអំបិល ក្នុងស្រុកស្អាង ដោយមានការចាត់តាំងស៊ីផឹក និងរាំផង។ ហើយគាត់ក៏បានទាក់ទងមកខ្ញុំ ឱ្យយកនារីស្អាតបាតនៅសន្តិសុខបាន២នាក់ដែលចេះរាំ ដើម្បីទៅចូលរួមក្នុងពិធីជប់លៀងនោះ ។ ពេលនោះ ខ្ញុំបានរើសឱ្យនារីគីមជាងទៅចូលរួម-ហើយខ្ញុំក៏បានឱ្យឈ្មោះចេវ និងទិ ទៅចូលរួមដែរ ដើម្បីព្រងឹងអ្នកទាំង២នេះ ក្នុងការសប្បាយភ្លើតភ្លើន ។

ហើយពេលនោះ មានភ្ញៀវវៀតណាមជាច្រើនបានត្រូវគ្រូសុខ និងសុខប៊ុតចំរើន ហៅទៅចូលរួមក្នុងពិធីនោះដែរ ។ ក្នុងចំណោមនោះ ខ្ញុំបានស្គាល់ អាទីហ៊ឹង អាហៃថាញ់-និងអាតាំ ដែលសុទ្ធជាបញ្ជាការកងទ័ព និងអាថានប៊ិន ជាគណៈទាក់ទងវៀតណាមប្រ-ចាំតំបន់២៥ ។ ពេលនោះ មានការស៊ីផឹក និងមានចាត់តាំងស្ត្រីទំនើប រាំសប្បាយ-គគ្រឹកគគ្រេងរហូតជិតភ្លឺទើបចប់ ។

ខែ៤.១៩៧១នោះ គ្រូសុខបានណែនាំខ្ញុំឱ្យស្គាល់កម្លាំងថែមទៀត ដើម្បីទាក់-ទងធ្វើការងារ ។ កម្លាំងទាំងនោះមាន :

១- តាក់ ហៅសុគន្ធ
២- ណើន ហៅសែមសួរ
៣- ឈុនគ្រី ហៅខៀវសំអាត
៤- ហុង ហៅចិនហុង

១៨.៧.៧៨ អ្នកទាំង៤នេះ សុទ្ធជាសមាសភាពថ្មី ក្នុងគណៈស្រុកកោះធំ ដែលសុខប៊ុតចំរើន និងគ្រូសុខបានរៀបចំចាត់តាំងក្នុងខែ៤.១៩៧១ រួមមានទាំងរូបខ្ញុំ និងប៉ាប៉ុនផង ។ ហើយអ្នកទាំង-នេះសុទ្ធជាកម្លាំងក្បត់បក្ស ដែលសុខប៊ុតចំរើន និងគ្រូសុខ ភ្ជាប់និងអប់រំពង្រឹងថែម ។

ម៉ឹង តេង

បន្ទាប់មក គ្រូសុខ ក៏បានណែនាំខ្ញុំបន្ថែម ឱ្យអនុវត្តគ្រប់សកម្មភាពបំផ្លែមាគ៌ាបក្ស ឱ្យ-កាន់តែខ្លាំងទៀតនៅក្នុងប្រជាជន ។

ខែ ៥-១៩៧១ ខ្ញុំបានជួបទាក់ទង សុខប៊ុតចំរើន ដើម្បីធ្វើសកម្មភាពបង្ក្រាបឈ្មួញទុច្ចរិត ដែលដឹកនាំទំនិញចេញចូលតំបន់ខ្មាំងនៅវៀតណាមខាងត្បូង ។ ពេលនោះ សុខប៊ុតចំរើន ក៏បានណែនាំខ្ញុំឱ្យអនុវត្ត គឺចំពោះទំនិញដែលដឹកចេញពីកម្ពុជាទៅវៀតណាម ដូចជាពោត-សណ្ដែក គឺឱ្យបង់ជាប្រាក់វិភាគទាន តែចំពោះទំនិញដែលដឹកពីប្រទេសវៀតណាមមកវិញ ឱ្យរឹបអូស ទាំងអស់ ពិសេស ស្រា និងបារី ។

បន្ទាប់មក ខ្ញុំក៏បានឱ្យកងសន្តិសុខចេញទៅធ្វើការ ហើយចាប់បានឈ្មួញបន្តបន្ទាប់ រួចរឹបអូស បាន ស្រាផង បារី និងទំនិញផ្សេងទៀត ហើយក៏បាននាំទៅឱ្យសុខប៊ុតចំរើន រួចគាត់ ក៏បានឱ្យ យកស្រា និងបារី ចែកចាយគ្នាប្រើប្រាស់ទាំងអស់ ។

ជាគោលបំណង គឺម្យ៉ាងដើម្បីឱ្យប្រជាជនមានការក្ដៅក្រហាយចំពោះអង្គការដែលតឹងតែង ហើយម្យ៉ាងទៀតធ្វើឱ្យយុទ្ធជន-កម្មាភិបាលនៅក្នុងក្រសួងមន្ទីរឈ្លក់សប្បាយភ្លើតភ្លើនស៊ីផឹកហ៊ឺហា ។

ហើយក្នុងខែ៥-១៩៧១នោះ ខ្ញុំបានជួបទាក់ទងធ្វើការពិភាក្សាជាមួយ ហួតសេ និងគាត់ ដែលពេលនោះ ហួតសេ ជាប្រធានសន្តិសុខតំបន់ ហើយគាត់ ជាប្រធានស្រុកកោះធំ ។ ពេលនោះបានពិភាក្សាលើកគោលការបំផ្លាញសេដ្ឋកិច្ចពីតំបន់រំដោះដោយវិធីស្របច្បាប់ គឺ ចេញច្បាប់អនុញ្ញាតិឱ្យប្រជាជនទិញគោយកទៅប្រើប្រាស់ ។ ជាបំណង គឺធ្វើឱ្យពួក ឈ្មួញ បាននិកាយទិញគោប្រមូលយកទៅក្នុងឃុំជិតព្រំដែន ដើម្បីងាយបញ្ចេញទៅតំបន់ខ្មាំង ។ ពេលនោះ ហួតសេ ក៏បានរៀបចំចាត់តាំងឱ្យខ្ញុំទទួលភារៈអនុវត្តលើពាក្យសុំទិញគោ ហើយ គាត់ ទទួលភារៈធ្វើសេចក្ដីបញ្ជាក់លើការអនុវត្ត រួចហួតសេ ជាអ្នកចេញច្បាប់ ។

រួចហើយ ហួតសេ ណែនាំខ្ញុំ ឱ្យយកកម្លាំងកងសន្តិសុខស្រុកចេញទៅស្ទាក់ចាប់ឈ្មួញទុច្ចរិត ដែលដឹក ដញ្ជូនគោទៅតំបន់ខ្មាំង ដែលជារូបភាពបោកបំភ័ន្តប្រជាជន ធ្វើឱ្យប្រជាជនជឿថាពួកគាត់

១៨.៧.៧៨

បានខិតខំការពារសេដ្ឋកិច្ចបដិវត្ត ។

ម៉ុង តេង

ពេលនោះ ឈ្មួញបានដឹកដញ្ជូនគោអស់ជាច្រើនក្បាល ពីតំបន់២៥ រហូតធ្វើឱ្យប្រជាជនខ្វះគោ ភ្ជួរ ហើយព្រួយបារម្ភចំពោះបាតុភាពនេះដែលឃើញអនាគតរបស់តំបន់រំដោះត្រូវអស់គោប្រើ បន្ទាប់មក ហួតសេ ក៏បានបញ្ឈប់សកម្មភាពនេះ ដើម្បីការពារមុខមាត់ទៀតវិញ ។

នៅក្នុងឆ្នាំ ១៩៧១នោះដែរ ហួតសេ បានឱ្យខ្ញុំទៅចាប់ប្រជាជនម្នាក់ឈ្មោះតាល់ នៅឃុំអណ្ដូងសំរោង ស្រុកកោះធំ ។ មូលហេតុ ដោយឈ្មោះនេះបានវាយប្រហារពួកតំបន់ ២៥ គឺសុខប៊ុតចំរើន គ្រូសុខ និងហួតសេ ថាជាពួកពុករលួយអាវ៉ារ៉ែល ។
បន្ទាប់មក ខ្ញុំក៏បានឱ្យកម្លាំងសន្តិសុខ២នាក់ ទៅចាប់ឈ្មោះតាល់នោះ ដើម្បីការពារមុខមាត់បក្សពួករបស់ខ្ញុំ ដោយចោទថា ឈ្មោះតាល់ ជាខ្មាំងបង្កប់ធ្វើវិទ្ធង្សនាបំបែកបំបាក់សាមគ្គី នៅក្នុងតំបន់២៥ ។ ចាប់ហើយ យកទៅវាយសួរចំលើយ រួចឃុំឃាំងនៅសន្តិសុខស្រុកអស់រយៈជិត មួយឆ្នាំ ទើបដោះលែងវិញ ។

ក្នុងឆ្នាំ ១៩៧១នោះដែរ គ្រូសុខបានណែនាំខ្ញុំ ឱ្យទៅចាប់ប្រជាជនវៀតណាមមួយគ្រួសារ នៅផ្សារព្រែកស្ដី ក្នុងឃុំព្រែកស្ដី ស្រុកកោះធំ ។ មូលហេតុ ដោយប្រជាជនវៀតណាមនោះ បានលាក់បង្កប់កងទ័ពវៀតណាមមួយចំនួននៅក្នុងផ្ទះរបស់ខ្លួន ហើយលបលួចបញ្ចេញឱ្យទៅបាញ់កងឈ្លបកម្ពុជា នៅឃុំព្រែកស្ដី ធ្វើឱ្យប្រជាជនភ័យជ្រួលច្របល់ ។
វៀតណាមមួយគ្រួសារនោះ មានគ្នាជិត១០នាក់ ខ្ញុំភ្លេចចំនួនច្បាស់ ដោយរាប់ទាំងកូនតូចៗ-ផង ហើយគ្រូសុខទាក់ទងចេញចូលជិតស្និតជាមួយវៀតណាមនោះ ។ ហើយគោលបំណងដែល គ្រូសុខឱ្យចាប់វៀតណាមនោះ គឺគ្រាន់តែធ្វើឱ្យប្រជាជនរលត់កំហឹងជាមួយវា ហើយជឿថា ពួកគ្រូសុខប្រឆាំងយួន ស្អប់យួនដែរ ។ តែតាមការពិត គឺគ្រូសុខណែនាំខ្ញុំ ឱ្យយកវៀតណាម-នោះចេញពីផ្ទះមួយរយៈ រួចយកទៅរក្សាទុកនៅជិតសន្តិសុខ ដោយរៀបចំផ្ទះឱ្យនៅ និងជីវភាពត្រឹមត្រូវ ។
បន្ទាប់មក ខ្ញុំក៏បានអនុវត្តការណែនាំនេះ ហើយបានយកវៀតណាមមួយគ្រួសារនោះទៅស្នាក់នៅផ្ទះមួយយ៉ាងធំ នៅភូមិស្វាយតាមេឃ ក្នុងឃុំកោះធំ ហើយថែរក្សាម៉ត់ចត់ ។ រហូតជាង២ខែ - គ្រូសុខ ក៏បានឱ្យខ្ញុំបញ្ជូនវៀតណាមទាំងគ្រួសារនោះត្រឡប់ទៅផ្ទះខ្លួននៅផ្សារព្រែកស្ដី - ក្នុងឃុំព្រែកស្ដីវិញ ។

១៨.៧.៧៨

ម៉ឹង តេង

ហើយឆ្នាំ ១៩៧១នោះ គ្រូហាង ជាប្រធានមន្ទីរសន្តិសុខតំបន់ បានទទួលការណែនាំពី ហួតសេ ឱ្យខ្ញុំប្រគល់កម្លាំងកងទ័ពសន្តិសុខស្រុកមួយកងអនុសេនាតូច ដើម្បីយកទៅបង្គ្រប់កម្លាំងកងទ័ពនៅឯសន្តិសុខតំបន់ ។

បន្ទាប់មក ខ្ញុំក៏បានរៀបចំកម្លាំងមួយកងអនុសេនាតូច តាមការស្នើរបស់គ្រូហ៊ាង ហើយខ្ញុំបាន - ចាត់តាំង ហ៊ូចេវ ជាកម្លាំងក្នុងខ្សែសេអ៊ីអារបស់ខ្ញុំ ឱ្យទទួលភារៈជាបញ្ជាការអនុសេនាតូច ដឹកនាំកម្លាំងនោះទៅ ។ ខ្ញុំចាត់តាំង ហ៊ូចេវ ដើម្បីឱ្យចូលទៅបង្កប់នៅក្នុងសន្តិសុខតំបន់ ។ រួចហើយ ខ្ញុំបានណែនាំហ៊ូចេវបន្ថែមឱ្យស្គាល់ ហួតសេ និងគ្រូហ៊ាង ជាកម្លាំងខាងលើក្នុងខ្សែក្បត់ជាមួយគ្នា ដើម្បីទាក់ទងធ្វើសកម្មភាពប្រឆាំងបក្ស នៅសន្តិសុខតំបន់ ។

នៅឆ្នាំ១៩៧១នោះ ខ្ញុំបានកសាងកម្លាំងបញ្ចូលមកក្នុងខ្សែសេអ៊ីអារបស់ខ្ញុំ បាន៦នាក់ទៀត គឺ:

១ - ឈ្មោះ ផាម
២ - " ស្រេង
៣ - " ហ៊ិន
៤ - ឈ្មោះ ងនលី ហៅងន
៥ - " ស្រ៊ុន
៦ - " ផេង

អ្នកទាំង៦នេះ សុទ្ធតែធ្វើការនៅសន្តិសុខដែលខ្ញុំប្រមូលក្តាប់ និងអប់រំកសាង ហើយអ្នកទាំងនេះមានចំណុចខ្សោយប្រហាក់ប្រហែលគ្នា គឺជាកូនអ្នកធូរធា ចូលចិត្តសប្បាយភ្លើតភ្លើន មុខមាត់អំនួត ហើយសេរី ដែលខ្ញុំអប់រំអូសទាញបញ្ចូលបានមកក្នុងខ្សែសេអ៊ីអារបស់ខ្ញុំនៅឆ្នាំ ១៩៧១ ។ រួចហើយ ខ្ញុំបានណែនាំភារកិច្ចឱ្យអ្នកទាំង៦នេះអនុវត្ត គឺ:

១- ឱ្យខិតខំកសាងកម្លាំងនៅក្នុងសន្តិសុខបន្ថែមទៀត

២- ឱ្យទាក់ទងអារ៉ាសែសិលធម៌នារី ដើម្បីធ្វើឱ្យខូចមាគ៌ាបក្ស

ហើយខ្ញុំក៏បានណែនាំអ្នកទាំងនេះ ឱ្យស្គាល់ ហួតសេ និងគ្រូហ៊ាង ដែលនៅផ្នែកសន្តិសុខជាមួយគ្នានិងជាកម្លាំងខាងលើក្នុងខ្សែក្បត់បក្សជាមួយគ្នា ដើម្បីទាក់ទងធ្វើការងារ ។

១៨.៧.៧៨ នៅក្នុងឆ្នាំ ១៩៧១នោះ ខ្ញុំមិនចាំខែច្បាស់ គ្រូសុខ បានត្រឡប់មកពីភូមិភាគ - បូព៌ាវិញ ។ គ្រូសុខ ទៅភូមិភាគក្នុងពេលនោះ ដោយមាននាំបញ្ជាការកងទ័ពតំបន់២៥មួយចំនួន មានឈ្មោះ សាយ យ៉ុង សុងលី គា ពិសិដ្ឋ គួយ និងមួយចំនួនទៀត ខ្ញុំមិនបានចាំ - ដើម្បីឱ្យទៅចូលរៀននៅសាលាយោធានៅភូមិភាគផង ។

ម៉ុង តេង

គ្រូសុខត្រឡប់មកដល់តំបន់វិញ នៅជិតចុងឆ្នាំ១៩៧១ តែខ្ញុំមិនបានចាំខែ ។ ពេលនោះគាត់បានហៅខ្ញុំទៅណែនាំនៅមន្ទីរ សុខប៊ុតចំរើន នៅព្រែកដើមស្តី ឃុំពោធិបាន ស្រុកកោះធំ ។

គ្រូសុខ បានណែនាំខ្ញុំថែមទៀត អំពីភារកិច្ចដែលត្រូវអនុវត្ត ដើម្បីសំរេចផែនការយូរ-អង្វែងក្នុងការយកជ័យជំនះលើបក្ស ។ ភារកិច្ចទាំងនោះ គឺ:

១- ឱ្យខ្ញុំអនុវត្តបំបែកបំបាក់សាមគ្គីផ្ទៃក្នុង ធ្វើឱ្យច្របូកច្របល់

២- ឱ្យខ្ញុំធ្វើសកម្មភាពបំភ្លៃមាគ៌ាបក្ស ឱ្យខ្លាំងទៀត

៣- ឱ្យខិតខំបំផុសសីលធម៌អាវ៉ាសែ ធ្វើឱ្យបក្សស្អុកស្អាញជាប់

រួចហើយ គាត់ក៏បានបង្ហាញខ្ញុំអំពីផែនការបង្កិចបំផ្លាញកម្លាំងកងទ័ព ដែលគាត់បានទទួលការណែនាំពីភូមិភាគមក ដោយវិធីវាយសំរុក ដើម្បីឱ្យខូចខាតកម្លាំងកងទ័ព ។
បន្ទាប់មក គាត់ក៏បានណែនាំឱ្យខ្ញុំស្គាល់ឈ្មោះកម្លាំងដឹកនាំខាងលើនៅភូមិភាគ ដែលជាខ្សែរបស់គាត់ផ្ទាល់ ដើម្បីធ្វើឱ្យខ្ញុំកាន់តែរឹងថែមទៀត ក្នុងការធ្វើសកម្មភាពប្រឆាំងបក្ស ព្រោះកាន់តែឃើញកម្លាំងធំ ក្នុងខ្សែរបស់ខ្ញុំ ។
កម្លាំងដឹកនាំ ដែលគ្រូសុខណែនាំឱ្យខ្ញុំស្គាល់ឈ្មោះទាំងនោះ គឺសុទ្ធជាឈើអាខ្សែរបស់គាត់:

១ - តា ភឹម លេខា ភូមិភាគបូព៌ា

២- តា ឈូក លេខា តំបន់ ២៤

៣- ច័ន្ទ ចក្រី ទទួលភារៈខាងកងទ័ពរបស់ភូមិភាគបូព៌ា

រួចហើយ គ្រូសុខបានជំរុញខ្ញុំ ឱ្យខិតខំកសាងកម្លាំងក្នុងខ្សែរបស់ខ្ញុំ ឱ្យបានច្រើនទៀតដើម្បីអនុវត្តភារកិច្ចបានខ្លាំង យកជ័យជំនះលើបក្សបន្តបន្ទាប់បាន ។

ខែ ៩-១៩៧១ គ្រូសុខ បានផ្លាស់ខ្ញុំពីសន្តិសុខស្រុកកោះធំ ឱ្យទៅទទួលសន្តិសុខតំបន់ជាមួយ ហួតសេរិញ ។ ហើយ វៀលលិញ ចូលទៅទទួលសន្តិសុខស្រុកកោះធំ ។ ពេលនោះ ខ្ញុំបានស្នើយកកម្លាំងមួយចំនួនទៅបន្តរួមការងារជាមួយខ្ញុំនៅសន្តិសុខតំបន់ ហើយទុកតែកងទ័ពសន្តិសុខមួយក្រុមឱ្យ វៀលលិញ ដោយខ្ញុំបានចាត់តាំងឈ្មោះស៊ុង ជាកម្លាំងក្នុងខ្សែរបស់ខ្ញុំឱ្យនៅជាមួយគាត់ ដើម្បីក្តាប់កងសន្តិសុខមួយក្រុមនោះ ។

១៨.៧.៧៨
មុឹង តេង

ខែ ១២-១៩៧១ ខ្ញុំបានចូលជាសមាជិកបក្សពលករ ។ ចូលនៅមន្ទីរសន្តិសុខតំបន់ ២៥ ដែលតាំងនៅភូមិព្រែកស្លែង ឃុំខ្ពប ក្នុងស្រុកស្អាង ។ ពេលចូលនោះ មានរៀបចំ-ពិធីត្រឹមត្រូវ ដោយមានផ្កាភ្ញី និងនំចំណីផង ។ ហើយក្នុងពិធីនោះ មានជាអង្គប្រជុំ -

ហើយអង្គប្រជុំនោះ មានលក្ខណៈសម្ងាត់ ដែលមានសមាសភាព ក្នុងអង្គប្រជុំ៣រូប គឺ:

១- តា ជ័យ ជាប្រធានអង្គប្រជុំ ជាអ្នកប្រកាសទទួលស្គាល់

២- គ្រូ សុខ ជាសមាជិក ជាអ្នកឧទ្ទេសនាម

៣- ហួត សេ • ជាអ្នកស្ប្រតប្រវត្តិរបស់ខ្ញុំ

ក្រៅពីនេះ គឺរូបខ្ញុំ ដែលត្រូវចូលជាសមាជិកបក្ស ក្នុងពេលធ្វើពិធីនេះ ។ ហើយក្នុងការបញ្ចូល គឺមានការណែនាំម៉ត់ចត់ច្បាស់លាស់ អំពីគ្រូសុខ និង តាជ័យ ដើម្បីឱ្យខ្ញុំក្ដាប់បានខ្លឹមសារនៃគោលជំហររបស់បក្ស និងអំពីការដែលខ្ញុំចូលជាសមាជិកបក្ស ។ តាជ័យ បានណែនាំខ្ញុំ ឱ្យឃើញអំពីគោលជំហររបស់បក្សពលករ ដែលត្រូវដឹកនាំប្រជាជនធ្វើការតស៊ូ វាយបណ្ដេញចក្រពត្តិអាមេរិក និងបរិវារ ហើយកសាងរបបសង្គមមួយ ដែលប្រជាជនមានសិទ្ធិសេរីភាព សំបូរសប្បាយ ។ គាត់បានបញ្ជាក់ថា ជាសង្គមសង្គមនិយម ដែលប្រជាជនមានសិទ្ធិក្នុងការរស់នៅតាមជំហររបស់ខ្លួន គឺជាសង្គមយុត្តិធម៌ ។ គាត់បានណែនាំដោយធ្វើការប្រៀបធៀបឱ្យខ្ញុំយល់ អំពីបក្សពលករ និងបក្សកុម្មុយនិស្តកម្ពុជា ដែលកំពង់ធ្វើសង្គ្រាម ។ គាត់បង្ហាញច្បាស់អំពីបក្សកុម្មុយនិស្តកម្ពុជា ដែលអយុត្តិធម៌ កៀបសង្កត់ ជិះជាន់សិទ្ធិសេរីភាពរបស់ប្រជាជន មើលងាយប្រជាជន ធ្វើបាបប្រជាជនឱ្យក្រីក្រលំបាកវេទនា ហើយបង្ខិតបង្ខំប្រជាជនឱ្យធ្វើការងារដូចសត្វធាតុ គ្មានគិតគូរពីការនឿយហត់របស់ប្រជាជនទេ ។ ហើយបក្សកុម្មុយនិស្តកម្ពុជា ធ្វើបាបប្រជាជនឱ្យព្រាត់ប្រាស់គ្រួសារ រួចធ្វើឱ្យប្រជាជនលែងស្គាល់ការសប្បាយអស់ ។ ហើយក្នុងមួយថ្ងៃៗ ធ្វើការគ្មានឈប់សំរាក តែបានត្រឹមតែមួយវែក ហើយពេលខ្លះមិនបានឆ្អែតផង ។ រួចតាជ័យបានសារុបថា រស់នៅក្នុងរបបដែលបក្សកុម្មុយនិស្តដឹកនាំ ដូចស្ថិតក្នុងគុកងងឹតសូន្យ ដែលគ្មានពន្លឺសុភមង្គលក្នុងជីវិតរស់នៅ ។

១៨.៣.៧៨ ផ្ទុយស្រឡះពីបក្សពលករ ដែលផ្ដល់សិទ្ធិសេរីភាព សុភមង្គលគ្រប់គ្រាន់ជូនប្រជាជន ។ រួចហើយ តាជ័យបានឱ្យខ្ញុំយល់ថែមទៀតអំពីភារកិច្ចរបស់បក្សពលករ ដែលត្រូវកៀកស្មាជាប់

មុឹង តេង ជាមួយបក្សពលករវៀតណាម ដែលជាយុទ្ធមិត្តរួមអាវុធយូរមកហើយ ហើយដែលជាបក្សបងប្អូននៅជិតគ្នា ។ បក្សទាំង២នេះ ធ្លាប់ឧបត្ថម្ភគ្នាទៅវិញទៅមក ហើយគោលជំហរ គឺឯកភាពគ្នាលើមាគ៌ាសង្គមនិយមទៅអនាគតដែលប្រជាជនមានសិទ្ធិសេរីភាពបរិបូណ៌ ។

បន្ទាប់មក ខ្ញុំកាន់តែបានយល់ច្បាស់ថែមទៀតអំពីបក្ស ដែលពេលនោះ ខ្ញុំកាន់តែមានការស្អប់ ហើយខ្លាចចំពោះបក្សកុម្មុយនិស្តកម្ពុជា ហើយពេញចិត្តចំពោះបក្សពលករ ដែលស្របនិងគោលបំណងរបស់ខ្ញុំ ។ ហើយពេលនោះ ខ្ញុំបានប្ដេជ្ញាដាច់ខាតបំរើបក្សពលកររហូតអស់មួយជីវិត ហើយប្រយុទ្ធប្រឆាំងដាច់ខាតចំពោះបក្សកុម្មុយនិស្តកម្ពុជា វាយផ្ដួលបក្សនេះមិនឱ្យនៅលើកម្ពុជាដាច់ខាត ។

រួចហើយ តាជ័យ ក៏បានប្រកាសបញ្ចូលរូបខ្ញុំ ជាសមាជិកបក្សពលករ ជាផ្លូវការ ហើយក៏បានផ្ដែផ្ដាំខ្ញុំបន្ថែមឱ្យខិតខំអនុវត្តភារកិច្ចរបស់បក្ស ដើម្បីសំរេចជ័យជំនះលើផែនការដែលត្រូវវាយកំទេចបក្សកុម្មុយនិស្តកម្ពុជា ។

ខែ១២-១៩៧១នោះ គ្រូសុខបានលើកផែនការបង្កទំនាស់ជាមួយ ស៊ាន សាន ជាអ្នកមកពីហាណូយ ។ ពេលនោះ ស៊ាន សាន មាននាទីជាប្រធានសេនាធិការតំបន់២៥ គ្រូសុខ បានឱ្យខ្ញុំចាក់បំផុសទំនាស់រវាងយុទ្ធជនកងទ័ពសន្តិសុខ និងហ្វូតសេ ដែលជាប្រធានសន្តិសុខ ដើម្បីឱ្យយុទ្ធជនទាំងនោះស្អប់ហ្វូតសេ រួចរត់ទៅនៅសេនាធិការជាមួយ ស៊ានសាន ហើយនៅក្នុងកងទ័ពសន្តិសុខ មានឈ្មោះជិនវ៉ាន់ ដែលមកពីហាណូយដែរ ជាអ្នកក្ដាប់កម្លាំងកងទ័ពសន្តិសុខនោះផ្ទាល់ ។

លើកផែនការ និងណែនាំខ្ញុំហើយ គ្រូសុខ ក៏ផ្ដើមបង្កទំនាស់ជាមួយស៊ានសាន ដោយបានវាយប្រហារកម្លាំងដែលមកពីហាណូយ ។ ពេលនោះ ស៊ានសានក៏ប្រមូលកម្លាំងអ្នកមកពីហាណូយ ធ្វើការវាយប្រហារតបវិញ ដែលពេលនោះមានសភាពទំនាស់ធំ ហើយអូរអាប់ពេញក្នុងតំបន់ ហើយសភាពទំនាស់នោះ រហូតដល់គួរទំនាស់ទាំងសងខាងគំរាមគ្នាដោយកម្លាំងកងទ័ពផង ។ ពេលនោះ ជិនវ៉ាន់ ក៏ឆក់ឱកាសបំផុសកងទ័ពសន្តិសុខឱ្យកាន់តែស្អប់ ហ្វូតសេ ថែមទៀត រួចក៏នាំកម្លាំងកងទ័ពទាំងនោះទៅសេនាធិការជាមួយស៊ានសាន ។ ជាបំណងរបស់ ស៊ានសាន និងជិនវ៉ាន់ គឺប្រមូលកងទ័ពឱ្យបានច្រើន ដើម្បីគំរាមសំឡុតគ្រូសុខ កុំឱ្យប្រឆាំងជាមួយពួកខ្លួនទៀត ។

១៨.៧.៧៨
ម៉ឹង តេង

ពេលនោះ គ្រូសុខ កាន់តែប្រមូលជំរុញកងកម្លាំងរបស់គាត់ ដែលធំជាងកម្លាំងខាងពួកស៊ានសាន ឱ្យគំរាមកៀបកម្លាំងស៊ានសានខ្លាំងឡើង ។

សភាពទំនាស់ក្នុងពេលនោះ បានធ្វើឱ្យប្រជាជននៅក្នុងតំបន់ ភ័យជ្រួលច្របល់ ។ ហើយគោលបំណងគ្រួសុខ ដែលបង្កទំនាស់នោះ គឺម្យ៉ាងដើម្បីធ្វើឱ្យរវល់ជាប់ស្មុកស្មាញ - គ្មានពេលវាខ្មាំង ធ្វើឱ្យខ្មាំងបានឱកាសពង្រីកទឹកដីចូលក្នុងតំបន់រំដោះ ។ ហើយ ម្យ៉ាងទៀត ដើម្បីធ្វើឱ្យប្រជាជនឃើញថា ពួកអ្នកនៅក្នុងប្រទេស ប្រឆាំងជាមួយពួកដែលមកពីហាណូយ ដោយពួកនេះជាខ្ញុំយួន ។ បំណងនេះ ដើម្បីកុំឱ្យប្រជាជនមើលឃើញថាពួកគ្រួសុខ មានខ្សែទាក់ទងជាមួយយួនដែរ ។

ខែ ១.១៩៧២ បងណាត ហៅសែម បានដឹកនាំកងទ័ពមួយវរៈសេនាតូចលេខ - ១១២ ចូលទៅប្រតិបត្តិការនៅក្នុងតំបន់២៥ ។ ហើយភារកិច្ចសំខាន់ក្នុងពេលនោះគឺដោះស្រាយទំនាស់នៅក្នុងតំបន់២៥ ។ ពេលនោះទំនាស់ស្រួច រវាងស៊ានសាន ជាអ្នកមកពី - ហាណូយ និងគ្រួសុខហើយនិងពួតសេ អ្នកនៅក្នុងប្រទេស ។ ហើយគូរទំនាស់នេះ សុទ្ធជាគណៈតំបន់ ដែលមានកងទ័ពក្នុងដៃដូចគ្នា ។

ពេលនោះ តាជ័យ និងបងណាត បានដោះស្រាយដោយការពារកម្លាំងខាងក្នុងប្រទេស ហើយបានបង្ខំស៊ានសាន ឱ្យប្រគល់កងទ័ពទាំងអស់ទៅកងវរៈ១១២ ។ រួចហើយ តាជ័យ ក៏បានបញ្ជូនស៊ានសាន ទៅអង្គការភូមិភាគ ។

ហើយក្នុងខែ១.១៩៧២នោះ ក្រោយពីប្រគល់កងទ័ពខាងស៊ានសានឱ្យទៅកង - វរៈ១១២ហើយ ខ្ញុំក៏បានជួបហ៊ូចេវ ជាកម្លាំងក្នុងខ្សែរបស់ខ្ញុំ ដែលត្រូវបានចូលក្នុងកងវរៈ ១១២ដែរនោះ ដើម្បីណែនាំពង្រឹងថែម និងណែនាំភារកិច្ចឱ្យអនុវត្តនៅក្នុងកង - ដើម្បីធ្វើសកម្មភាពវាយបក្ស ៖

១- ឱ្យខិតខំកសាងកម្លាំងនៅក្នុងកងទ័ព

១៨.៣.៧៨ ២- ឱ្យបំផុសចលនាយុទ្ធជនរត់ចោលកង ក្នុងពេលបើកសមរភូមិ

៣- ឱ្យបំផុសចលនាយុទ្ធជនបោះបង់ បំផ្លាញអាវុធ និងគ្រាប់រំសេវ

ម៉ឺង តេង បន្ទាប់មក ខ្ញុំបានណែនាំហ៊ូចេវ ឱ្យក្ដាប់និងពង្រឹងកម្លាំង ក្នុងចំណោមយុទ្ធជនសន្តិសុខមួយកងអនុ - សេនាតូច ដែលហ៊ូចេវបាននាំទៅចូលជាមួយស៊ានសាន ។ ព្រោះជាកម្លាំងយុទ្ធជនដែល - ហ៊ូចេវ ក្ដាប់បានស្រាប់ ដោយហ៊ូចេវ កាលនៅក្នុងសន្តិសុខ មាននាទីជាគណៈកង ។

រួចហើយ ខ្ញុំបានណែនាំ ហ៊ួចេវ ឱ្យណែនាំនិងពង្រឹងឈ្មោះហ៊ិន និងសោមជួ ដើម្បីជាកម្លាំងសំខាន់ រួមធ្វើសកម្មភាពក្នុងកងទ័ពបានខ្លាំង ។ ឈ្មោះហ៊ិន និងសោមជួ ទៅសានិត ជា-កម្លាំងក្នុងខ្សែរសេអ៊ីអារបស់ខ្ញុំ ដែលខ្ញុំបានអប់រំ ហើយអូសទាញបញ្ចូលបាននៅឆ្នាំ១៩៧០ ។ ហើយអ្នកទាំងនេះ សុទ្ធតែនៅក្នុងសន្តិសុខ ដែលហ៊ួចេវ ក្តាប់បានស្រាប់ ។

ខែ ១-១៩៧២ គ្រូសុខបានជួបណែនាំខ្ញុំនៅសន្តិសុខ ឱ្យស្គាល់គ្រូយូប៉េងគ្រី ទៅមុន ជាកម្លាំងក្នុងខ្សែរសេអ៊ីអារបស់គាត់ ដើម្បីឱ្យខ្ញុំបានទាក់ទងធ្វើការងារ ។ ហើយគ្រូ ប៉េង-គ្រី ខ្ញុំបានស្គាល់គ្នាជាមិត្តភក្តិ បានរៀនសូត្រជាមួយគ្នាតាំងពីនៅរៀនសាលាវត្តសំរ៉ោង ។ ហើយគ្រូសុខ និងគ្រូប៉េងគ្រី បង្រៀនក្នុងមូលដ្ឋានស្រុកកោះធំជាមួយគ្នា ដែលគ្រូសុខអប់រំ-អូសទាញបាន តាំងពីក្នុងសម័យតស៊ូនយោបាយ ឆ្នាំ១៩៦៨ ។

ហើយខែ ១-១៩៧២នោះ គ្រូប៉េងគ្រីបានជួបខ្ញុំ នៅផ្ទះខ្ញុំក្នុងភូមិព្រែកផ្កាវ ឃុំកំពង់កុង - ស្រុកកោះធំ ។ពេលនោះ ខ្ញុំឧទ្ទេសនាម ម៉ឹងទិត ជាប្អូនរបស់ខ្ញុំ និងជាកម្លាំងក្នុងខ្សែរសេអ៊ីអារបស់ខ្ញុំ ដើម្បីឱ្យគ្រូប៉េងគ្រីទទួលស្គាល់ និងរួមណែនាំការងារក្នុងសកម្មភាពប្រឆាំងបក្ស គ្រូប៉េងគ្រី ក្តាប់បាន ម៉ឹងទិតរួចហើយ ដោយគ្រូសុខបានណែនាំឱ្យស្គាល់ និងទាក់ទងតាំងពីគ្រូប៉េងគ្រីនៅធ្វើការក្នុងតំបន់២៥ក្នុងឆ្នាំ១៩៧០ ហើយគាត់ និងម៉ឹងទិត ក៏ធ្លាប់បានទាក់ទងគ្នាៗ

ក្នុងខែ ១-១៩៧២នោះដែរ គ្រូសុខបានជួបណែនាំខ្ញុំឱ្យស្គាល់បងណាត ទៅដែលគាត់ជួបណែនាំខ្ញុំនៅសន្តិសុខដដែល ។ ពេលនោះ គាត់ប្រាប់ខ្ញុំថា បងណាតជាខ្សែរសេអ៊ីអារបស់គាត់ តាំងពីឆ្នាំ១៩៦៥ ។ ហើយបងណាតត្រូវជាខ្មួយរបស់លោកសង្ឃឈ្មោះខៀវ ជុំ - និងជាខ្មួយរបស់អាខៀវណយ សក្តិខ្មែរសេរី ។

គ្រូសុខ ណែនាំខ្ញុំឱ្យស្គាល់បងណាត ជាខ្សែទាក់ទងក្នុងខ្សែរសេអ៊ីអាជាមួយគាត់ ដើម្បីឱ្យខ្ញុំ បាន
១៩.៧.៧៨ ទាក់ទងធ្វើការងារ ក្នុងសកម្មភាពប្រឆាំងបក្ស ។

ខែ ២-១៩៧២ តាជ័យបានណែនាំខ្ញុំថែមទៀត ឱ្យខ្ញុំស្គាល់បងណាត ជាកម្លាំងក្នុង -
ម៉ឹង តេង ខ្សែរបស់គាត់ ។ ពេលនោះ គាត់ណែនាំឱ្យខ្ញុំស្គាល់ នៅមន្ទីរតំបន់ ដើម្បីឱ្យខ្ញុំទាក់ទងធ្វើការងារជាមួយបងណាត ។

ហើយតាជ័យ ក៏បានណែនាំខ្ញុំ នៅក្នុងខែ២-១៩៧២នោះ ឱ្យទៅជួបបងណាត ដើម្បីចាប់យុទ្ធ-ជនម្នាក់នៅក្នុងវរៈ១១២ ។

យុទ្ធជននោះ ខ្ញុំភ្លេចឈ្មោះ ដែលបងណាតរាយការណ៍ថាធ្វើសកម្មភាពខែ១ទំនាស់នៅក្នុងកង បន្ទាប់មក ខ្ញុំក៏ទៅចាប់យុទ្ធជននោះ ដែលមានបងណាត និងគ្រូសុខរួមផង ហើយយកទៅ-សន្តិសុខ ដើម្បីសួរចំលើយ ។ ពេលនោះ បងណាត និងគ្រូសុខ បានជំរុញឱ្យធ្វើទារុណកម្មរហូតយុទ្ធជននោះស្លាប់ ។

ក្នុងខែ៣.១៩៧២ តាជ័យបានឱ្យខ្ញុំដោះលែងវៀតណាមទាំងអស់ ដែលចាប់ឃុំ-ឃាំងនៅសន្តិសុខ រួចឱ្យខ្ញុំ និងហួតសេ នាំយកទៅប្រគល់ឱ្យ ថាន់ប៊ិន ជាគណៈទាក់ទង-វៀតណាម ។ ហើយពេលនោះ ហួតសេ ជាគណៈទាក់ទងតំបន់២៥ ។ តាជ័យ បានណែនាំខ្ញុំ អំពីមូលហេតុដោះលែង គឺដើម្បីរក្សាមិត្តភាព និងសាមគ្គីភាពជាមួយវៀតណាម ។ រួចហើយ ហួតសេ និងខ្ញុំ ក៏បាននាំវៀតណាម ទាំងអាណិកជន ទាំងកងទ័ព ជាង៦០នាក់ យកទៅប្រគល់ឱ្យគណៈទាក់ទងវៀតណាម នៅមន្ទីររបស់ ថាន់ប៊ិន នៅភូមិក្បាលជ្រោយ ឃុំពោធិបាន ស្រុកកោះធំ ។

ខែ៤.១៩៧២ ខ្ញុំបានខូចសិលធម៌ជាមួយនារីម្នាក់ ឈ្មោះវណ្ណា ហៅឡា ។ នារីនេះ ត្រូវជាសាច់ញាតិរបស់ខ្ញុំ ដែលមាននាទីជាគណៈនារីតំបន់ ។ ហើយនារីនេះជាស្រីមេម៉ាយ អាយុជិត៣០ឆ្នាំ ។
បន្ទាប់មក តាជ័យ ក៏បានឱ្យដកនារីវណ្ណានេះចេញពីគណៈនារីតំបន់ ហើយដាក់ឱ្យទៅនៅក្នុងមូលដ្ឋានស្រុកកោះធំវិញ ដើម្បីការពារកុំឱ្យបែករឿងខូចសិលធម៌របស់ខ្ញុំ ។

ខែ៥.១៩៧២ ខ្ញុំបានរាយការណ៍ឱ្យតាជ័យ អំពីកម្លាំងមួយចំនួននៅក្នុងមូលដ្ឋានស្រុកកោះធំ ដែលខ្ញុំអប់រំកសាងបានក្នុងឆ្នាំ១៩៧១ ។ កម្លាំងទាំងអស់នោះ គឺ:

១- ឈ្មោះ រេប អតីតៈគណៈឃុំកោះធំ
២- " ទុយ " ព្រែកថ្មី
៣- " ជិន " ព្រែកស្ដី
៤- " សំបូរ " សំពៅពូន
៥- " សួនី " ឈើខ្មៅ

ហើយចំណុចខ្សោយរបស់អ្នកទាំង៥នេះ គឺសុទ្ធជាមនុស្សអាវ៉ាសែពីសង្គមចាស់ ។

១៥.៧.៧៨
ម៉ឹង តេង

អ្នកទាំងនេះ ចូលចិត្តសប្បាយ ស៊ីផឹក ល្បែងស៊ីសង និងស្រីញីផង ដែលខ្ញុំអប់រំអូសទាញបញ្ចូល បានមកក្នុងខ្សែរសេអ៊ីអារបស់ខ្ញុំ ។

ខែ១០-១៩៧២ ខ្ញុំបានរាយការណ៍ឱ្យតាជ័យទៀត អំពីកម្លាំងដែលខ្ញុំកសាងបានថែម-នៅក្នុងសន្តិសុខ ។ កម្លាំងទាំងនោះគឺ:

១- ប៊ុល ទោ
២- ចឹក ច្រឹង
៣- រ៉ាំង ខែម
៤- សុខា ហៅ ឈ្វី
៥- ស៊ុំ
៦- ម៉េត

អ្នកទាំង៦នេះ ខ្ញុំប្រមូលយកមកក្តាប់ ហើយអប់រំនៅក្នុងសន្តិសុខ ដែលក្នុងខែ១០-១៩៧២ ខ្ញុំ-កសាងបញ្ចូលបានក្នុងខ្សែរសេអ៊ីអារបស់ខ្ញុំ ។ ហើយជាចំណុចខ្សោយរបស់អ្នកទាំង៦នេះគឺមាន ប្រហាក់ប្រហែលគ្នា គឺចូលចិត្តសប្បាយស៊ីផឹក ភ្លើតភ្លើននិងសំភារៈ ហើយមុខមាត់បុណ្យស័ក្តិ ។

ខែ១០-១៩៧២នោះ: តាជ័យបានឱ្យខ្ញុំទៅចាប់ឈ្មោះវែថ ដែលត្រូវជាប្អូនរបស់-ហម ម៉េង យកទៅសន្តិសុខ ។ មូលហេតុ គឺឈ្មោះវែថ ជាភ្នាក់ងាររចារកិច្ចរបស់ពួក អាលន់ណុល ដែលបង្កប់នៅភូមិព្រែកផ្អាវ ឃុំកំពង់កុង ស្រុកកោះធំ ។ ហើយមូលហេតុ ឈ្មោះវែថ ចូលបង្កប់បាន ដោយយុទ្ធជនម្នាក់នៅក្នុងកងវរៈ១១២ ដែលជាសាច់ញាតិរបស់វែថ បាននាំវា ចូលមក ។ យុទ្ធជននោះ: ខ្ញុំភ្លេចឈ្មោះ តែឪពុកឈ្មោះម៉ុត ម្តាយឈ្មោះប្រិច កំណើត នៅភូមិព្រែកផ្អាវ ឃុំកំពង់កុងដែរ ។

ចាប់ហើយ ខ្ញុំក៏យកទៅសន្តិសុខ សួរចំលើយ រួចឃើញច្បាស់ជាភ្នាក់ងាររចារកិច្ចរបស់ពួក អាលន់ណុល តាជ័យ ក៏បានសំរេចឱ្យយកទៅកំទេច ។

នៅឆ្នាំ១៩៧២នោះ: តំបន់២៥ ត្រូវចូលក្នុងភូមិភាគពិសេសវិញ ។ ហើយ បង "រ"
១៩-៧-៧៨ ដែលជាប្រធានមន្ទីរភូមិភាគ បានចេញចូលទាក់ទងជាមួយតាជ័យ នៅមន្ទីរតំបន់ ។ ហើយ បង "រ" និងខ្ញុំ ក៏ធ្លាប់បានស្គាល់គ្នាស្រាប់ តាំងពីជាប់គុកខ្មាំងជាមួយគ្នា នៅក្នុងឆ្នាំ១៩៦៨ ។ រួចហើយ តាជ័យក៏បានណែនាំឱ្យខ្ញុំស្គាល់បង "រ" ជាកម្លាំងក្នុងខ្សែររបស់គាត់ ដែលជាខ្សែរ-សេអ៊ីអា ។

ហើយក្នុងពេលនោះ: បង "រ" បានទៅជួបតាជ័យ រាយការណ៍អំពីសកម្មភាពរបស់ឈ្មោះជួនប៊ិន ។

ដួន ប៊ិន ជាប្រជាជននៅភូមិព្រៃទទឹង ឃុំត្នុច ក្នុងស្រុកស្លាង ដែលបានបំផុសចលនាឱ្យប្រជា-ជនក្នុងភូមិ ដេញកងទ័ពវៀតណាម មិនឱ្យនៅក្នុងភូមិរបស់ខ្លួនទៀត ។

បន្ទាប់មក តាជ័យ ក៏បានពិភាក្សាជាមួយបង "វ" ឃើញថាសកម្មភាពបំបែកបំបាក់សាមគ្គី រវាង កម្ពុជា-វៀតណាម ក៏បានឱ្យខ្ញុំទៅពិនិត្យ ហើយចាប់ប្រជាជនឈ្មោះដួនប៊ិននោះយកទៅ សន្តិសុខ ដើម្បីសួរចំលើយ ធ្វើសំណុំរឿង ។

ខ្ញុំ ក៏បានអនុវត្តការណែនាំនេះ ហើយចាប់ដួនប៊ិនយកទៅវាយសួរចំលើយរួចឃុំឃាំងនៅសន្តិសុខ រហូត ដោយត្រូវទទួលចោទថាជាភ្នាក់ងារបង្កប់របស់ខ្មាំង ដែលបានធ្វើសកម្មភាពបំបែក បំបាក់សាមគ្គីភាព កម្ពុជា-វៀតណាម ។ ខ្ញុំចាប់ដួនប៊ិន នៅក្នុងខែ ៧.១៩៧២ ។

ហើយក្នុងខែ៧.១៩៧២នោះ តាជ័យណែនាំខ្ញុំឱ្យរៀបចំកម្លាំងក្នុងខ្សែរបស់ខ្ញុំ៦នាក់ ដើម្បីចាត់តាំងបង្កប់នៅក្នុងកងទ័ព ។ ពេលនោះ តាជ័យត្រូវពង្រីកកងទ័ពស្រុកកៀន-ស្វាយ និងស្រុកស្លាង ក្នុងមួយស្រុកមួយកងអនុសេនាធំ ។ ហើយតាជ័យឱ្យខ្ញុំប្រគល់ទៅស្រុក-កៀនស្វាយ៣នាក់ និងស្រុកស្លាង៣នាក់ ។

បន្ទាប់មក ខ្ញុំក៏បានឧទ្ទេសនាមកម្លាំង ៣នាក់ឱ្យស្រុកកៀនស្វាយ គឺ:

១- ឈ្មោះ អុល ២- ឈ្មោះ ស្រស់ ៣- ឈ្មោះ ទិហៅគង់

រួចហើយ ខ្ញុំក៏បានរៀបចំកម្លាំង៣នាក់ទៀត ឧទ្ទេសនាមឱ្យទៅស្រុកស្លាង គឺ:

១- ឈ្មោះ ទៀង ២- ឈ្មោះប៊ុនថេង ៣- ឈ្មោះ ម៉េងហេង

ហើយខ្ញុំក៏បានណែនាំឱ្យកម្លាំងដែលទៅស្រុកកៀនស្វាយ ស្គាល់ហួតសេ និងកម្លាំងដែលត្រូវទៅ ស្រុកស្លាងស្គាល់ហ៊ឹងគ្រុយ ជាកម្លាំងក្នុងខ្សែក្បត់បក្សជាមួយគ្នារួចត្រូវភ្ជាប់កងទ័ពស្រុក - ដើម្បីឱ្យអ្នកទាំង៦ ទាក់ទងធ្វើការងារ ។

១៩.៧.៧៨

ម៉ុង តេង

ហើយខែ៧.១៩៧២នោះ តាជ័យ បងណាត និងខ្ញុំ បានទៅជួបហួតសេ នៅកន្លែង កងទ័ពស្រុក នៅភូមិព្រៃកជ្រៅ ឃុំតាលន់ ក្នុងស្រុកស្លាង ។ ខ្លឹមសារ គឺតាជ័យ និងបង ណាត ជំរុញហួតសេ ឱ្យដឹកនាំកងទ័ពស្រុក ដែលមានសៅសុផល ជាអ្នកភ្ជាប់ផ្ទាល់ឱ្យជំលៀស ប្រជាជនចេញពីតំបន់ខ្មាំងកាន់កាប់ ហើយអុកឡុក រឹបបន្លំយកទ្រព្យសម្បត្តិមាសប្រាក់ របស់ ប្រជាជន ក្នុងពេលជំលៀសចេញមក ។

ជាគោលបំណង គឺដើម្បីបង្កចំលាស់រវាងប្រជាជនជំលៀស និងអង្គការ ធ្វើឱ្យប្រជាជន មិនទុកចិត្តកក់ក្តៅ ហើយមានកំហឹង ស្អប់អង្គការ ហើយប្រឆាំងអង្គការវិញ ។

ខែ៨.១៩៧២ តាជ័យបានឱ្យខ្ញុំទៅចាប់ប្រជាជន នៅឃុំឈើខ្មៅ២នាក់ យកមក សន្តិសុខ ដោយសង្ស័យថាជាដៃជើងរបស់ខ្មាំង ។ ប្រជាជនទាំង២នោះ ខ្ញុំភ្លេចឈ្មោះ ផ្ទះនៅខាងត្បូងវត្តឈើខ្មៅ ។ គោលបំណង គឺដើម្បីធ្វើឱ្យចំលាស់រវាងប្រជាជន និង អង្គការ ឱ្យប្រជាជនក្តៅក្រហាយ ចងកំហឹងចំពោះអង្គការ ដែលចាប់ប្រជាជនដោយ គ្រាន់តែមានការសង្ស័យ ។

ខែ៨.១៩៧២នោះដែរ តាជ័យបានឱ្យខ្ញុំទៅចាប់ប្រជាជនម្នាក់ទៀតឈ្មោះ - អៀងខ្លែង នៅភូមិទេពអរជូន ឃុំកោះខែល ក្នុងស្រុកស្អាង ។ មូលហេតុ ដោយប្រជាជន នេះ បានធ្វើសកម្មភាពបំបែកបំបាក់សាមគ្គីភាពរវាងកម្ពុជា-វៀតណាម ដែរ ។ បន្ទាប់មក ខ្ញុំក៏បានអនុវត្តតាមការណែនាំរបស់តាជ័យ ដោយបានចាប់ឈ្មោះអៀងខ្លែងនេះ- យកទៅសន្តិសុខ សួរចំលើយ រួចឃុំឃាំងនៅសន្តិសុខ រហូតជននេះស្លាប់ក្នុងទីឃុំឃាំង ។

ខែ៩.១៩៧២ តា "ក" បានចុះទៅដល់តំបន់២៥ ។ ពេលនោះ តាជ័យក៏បាន - នាំគាត់ទៅមន្ទីរសន្តិសុខ កន្លែងខ្ញុំផ្ទាល់ ហើយសំរាកនៅទីនោះ ។ រួចតាជ័យ ក៏បានឧទ្ទេ- សនាមរូបខ្ញុំឱ្យតា "ក" ក្តាប់បាន និងទទួលស្គាល់ ។ ពេលនោះ តា "ក" បានប្រាប់ខ្ញុំថា- គាត់ក្តាប់ខ្ញុំបានតាំងពីនៅភ្នំពេញ ក្នុងសម័យតស៊ូសម្ងាត់ ។
ហើយដល់ពេលយប់ ទើបតាជ័យនាំតា "ក" ទៅមន្ទីរ២៥ ដែលតាំងនៅក្នុងភូមិព្រែទទឹង ឃុំ ខ្ពប ដែលជាកន្លែងតាជ័យផ្ទាល់ ។ ហើយមន្ទីរសន្តិសុខ ពេលនោះតាំងនៅភូមិលេខ១ ឃុំ ពោធិបាន ក្នុងស្រុកកោះធំ ។

២០.៧.៧៨ បន្ទាប់មក តាជ័យក៏បានណែនាំខ្ញុំនៅមន្ទីរតំបន់២៥ ឱ្យស្គាល់តា "ក" ជាកម្លាំងខាង លើសំខាន់ ក្នុងខ្សែរបស់គាត់ ដែលជាខ្សែសេអ៊ីអា ដើម្បីឱ្យខ្ញុំបានទាក់ទងធ្វើការងារ។ តាជ័យបានណែនាំខ្ញុំ នៅក្នុងខែ៩.១៩៧២ ក្រោយពីតា "ក" ត្រឡប់ទៅវិញ ។

ម៉ឹង តេង

ខែ៩.១៩៧២នោះ ខ្ញុំនឹងខូចសិលធម៌ជាមួយនារីម្នាក់ឈ្មោះណាវ ។ នារីនេះ - ជាគណៈនារីតំបន់ ទទួលភារៈខាងតំបាញ ។ ហើយនារីនេះអាយុជិត៣០ឆ្នាំ ។

ហើយមូលហេតុ ខ្ញុំទាក់ទងខូចសិលធម៌ជាមួយនារីឈារ៉ា ដោយនារីនេះត្រូវជាប្អូនរបស់គ្រូ-ជ្រាង ។ ហើយខ្ញុំ និងគ្រូជ្រាង ជិតស្និតគ្នា រួចខ្ញុំក៏ស្និតស្នាលជាមួយនារីនេះ រហូតដល់បានខូចសិលធម៌ជាមួយគ្នា ។

បន្ទាប់មក នៅជិតចុងឆ្នាំ១៩៧២ ខ្ញុំបានជួបទាក់ទងបងផា លេខាស្រុកកោះធំ ដើម្បីចុះទៅពង្រឹងកម្លាំងដែលខ្ញុំកសាងបាននៅក្នុងមូលដ្ឋានស្រុកកោះធំ ។
ពេលនោះ ឈ្មោះសំបូរ ត្រូវផ្លាក់នាទីពីគណៈឃុំសំពៅពូន ដោយបានបំផុសឱ្យមានល្បែងស៊ីសងនៅក្នុងឃុំ ។ ហើយឈ្មោះបេ បានប្រព្រឹត្តសិលធម៌អាវ៉ាសែ លើស្ត្រីជាគ្រួសាររបស់ប្រជាជនម្នាក់នៅភូមិស្វាយតាមេឃ ក្នុងឃុំកោះធំ ។
ពេលនោះ ខ្ញុំណែនាំឱ្យអ្នកទាំង២ឃើញ អំពីជ័យជំនះរបស់ខ្លួនដែលបានអនុវត្តភារកិច្ចរួចមកហើយ ដែលបានធ្វើឱ្យមានទំនាស់នៅក្នុងមូលដ្ឋាន រវាងអង្គការ និងប្រជាជន ។
រួចខ្ញុំបានជំរុញអ្នកទាំង២ថែម ឱ្យខំអនុវត្តភារកិច្ចបន្តទៀត ដើម្បីពង្រីកទំនាស់នៅក្នុងមូលដ្ឋានឱ្យកាន់តែធំ ។

បន្ទាប់មកទៀត ខ្ញុំបានជំរុញឱ្យឈ្មោះផេង ជាកម្លាំងក្នុងខ្សែរបស់ខ្ញុំ ហើយជាយុទ្ធជនកងការពារកន្លែងឃុំឃាំងអ្នកទោស ឱ្យអាវ៉ាសែខាងសិលធម៌នារី ។
រួច ឈ្មោះផេង ក៏បានទាក់ទងជាមួយស្រីម្នាក់ឈ្មោះផាត ផ្ទះនៅជិតកន្លែងឃុំឃាំងអ្នក-ទោស នៅភូមិរកាក្រោម ឃុំខ្ពប ក្នុងស្រុកស្អាង ។ ស្រីនេះ ជាគ្រួសាររបស់ ឈ្មោះផា ធ្វើការនៅមន្ទីរពេទ្យតំបន់ ។
ការទាក់ទងកាន់តែស្និតស្នាល ហើយឈ្មោះផេង និងឈ្មោះផាតនោះ ក៏បានខូចសិលធម៌ជាមួយគា ។
២០.៧.៧៨ បន្ទាប់មក ដើម្បីការពារពួកខ្ញុំ ខ្ញុំក៏បានដកឈ្មោះផេងចេញពីកងការពារ ហើយឱ្យ-ទៅនៅធ្វើការក្នុងកងបង្កបង្កើនផលរបស់មន្ទីរវិញ ។
ម៉ឹង តេង ហើយនារីផាត ខ្ញុំក៏បានទាក់ទងឱ្យគ្រូសុខ យកទៅធ្វើការនៅក្នុងមន្ទីរពេទ្យតំបន់ -ជាប់កៀកកិតជាមួយគ្រួសារវិញ ។

នៅចុងឆ្នាំ១៩៧២នោះ ខ្ញុំបានជួបម៉ឹងតែ នៅមន្ទីរពេទ្យដែលស្នាក់នៅក្នុងឃុំខ្ពប ក្នុងស្រុកស្អាង ។

ពេលនោះ ម៉ឺង ទិត បានរាយការណ៍អំពីកម្លាំងដែលកសាងបានថែមទៀតនៅក្នុងឆ្នាំ១៩៧២ នៅក្នុងមន្ទីរពេទ្យ ។ កម្លាំងទាំងអស់នោះគឺ:

១- ឈ្មោះ សារី "នារី"
២- " ចន្ថា
៣- ឈ្មោះ តាំង
៤- " ឈឿន

ហើយកម្លាំងទាំងនេះ សុទ្ធតែមានចំណុចខ្សោយប្រហាក់ប្រហែលគ្នា គឺជាកូនអ្នកធូរធា ចូលសប្បាយ អំនួតមុខមាត់ ដែលម៉ឺងទិត អប់រំអូសទាញបញ្ចូលបានមកក្នុងខ្សែរសេរីអារបស់ខ្ញុំ ។ ហើយកម្លាំងដែលម៉ឺងទិត កសាងបានក្នុងឆ្នាំ១៩៧១នោះខ្ញុំសូមរាយការណ៍បញ្ជាក់ឡើងវិញ គឺមាន៥នាក់ ដែលសុទ្ធតែនៅធ្វើការក្នុងពេទ្យតំបន់ជាមួយគ្នា :

១- ឈ្មោះ ទៀបឹន ហៅផា
២- " ច៉ាក
៣- ឈ្មោះ លីវ
៤- " ផេង
៥- " ឈុក

រួចហើយ ម៉ឺងទិត បានឱយខ្ញុំដឹងអំពីសកម្មភាពបំផុសនារីពេទ្យម្នាក់ឈ្មោះ សៅ ឱយខូចសិលធម៌ជាមួយគ្រូសុខ ។ នារីសៅ បានទាក់ទងអូសទាញគ្រូសុខ តាមការបំផុស និងជំរុញរបស់វា រហូតបានកៀកកិតគ្នា ហើយបានខូចសិលធម៌ជាមួយគ្នា ។
បន្ទាប់មក ម៉ឺងទិត បានប្រាប់ខ្ញុំអំពីសកម្មភាពគ្រូសុខដែលបានណែនាំវាឱយជំរុញពេទ្យចន្ថា ចាក់ថ្នាំសំឡាប់យុទ្ធជនរបួសម្នាក់នៅមន្ទីរពេទ្យព្រែកតាកុក ដោយយុទ្ធជននោះបានវាយប្រហារគ្រូសុខ ពីរឿងអាវ៉ាវៃ ជាមួយនារីនៅក្នុងពេទ្យ ។ យុទ្ធជននោះ ផ្ទះនៅក្នុងឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ តែខ្ញុំភ្លេចឈ្មោះ ។

០.៧.៧៨ ម៉ឺង តេង

ហើយក្នុងខែ១០.១៩៧២នោះ ខ្ញុំបានការណែនាំពីតាជ័យ ឱយទៅជួបវៀតណាម ឈ្មោះណាំសុង ដើម្បីទាក់ទងទទួលអាវុធខ្លី ធុនកា៥៤ចំនួន៣ដើម ។ អាណាំសុង ជាបញ្ជាការកងវរៈសេនាតូចលេខ៤០ ដែលទីស្នាក់ការនៅក្នុងឃុំប្រាសាទ ស្រុកស្អាង ។ អាវុធទាំងនោះ តាជ័យបានទាក់ទងពិភាក្សាជាមួយអាណាំសុងរួចហើយ ។
រួចហើយ ខ្ញុំក៏បានទៅជួបអាណាំសុង តាមការណែនាំរបស់តាជ័យ រួចក៏បានទទួលអាវុធនោះពីវាគ្រប់ចំនួន ហើយខ្ញុំក៏បានយកទៅប្រគល់ឱយតាជ័យ នៅមន្ទីរតំបន់ ។

ក្នុងខែ១០.១៩៧២នោះ ឈ្មោះស៊ុំ ជាកងការពារអ្នកទោស នៅកន្លែងឃុំឃាំង បានធ្វើឱ្យអ្នកទោសឈានាក់រត់បាត់ ។ អ្នកទោសទាំង៣នោះ គឺម្នាក់ឈ្មោះសម្បត្តិ ហើយ២នាក់-ទៀតខ្ញុំភ្លេចឈ្មោះ ។ មូលហេតុរត់រួច ដោយឈ្មោះស៊ុំ បានធ្វើសកម្មភាពមិនចាក់សោរ ហើយមិនយាមការពារ ។ ហើយអ្នកទោសទាំង៣នោះ ជាគិញបង្កប់របស់ពួកអាលន់ណុល-ដែលត្រូវបានចាប់ខ្លួនពីចុងឆ្នាំ១៩៧១ ។

បន្ទាប់មក នៅចុងឆ្នាំ១៩៧២ តាជ័យបានឱ្យខ្ញុំ និងបងណាត សួរចំឡើយពី-គិញខ្មាំងម្នាក់ឈ្មោះ លីតេង ។ គិញនោះ វាបានចូលមករកទាក់ទងស៊ើបការណ៍នៅក្នុងតំបន់រំដោះ ហើយត្រូវកងឈ្លបចាប់បាននៅឃុំត្រើយស្លា រួចបញ្ជូនឱ្យសន្តិសុខ ។
សួររួចហើយ ក៏បានដឹងពត៌មានថាវាជាគិញសម្ងាត់ សំរាប់ទាក់ទងពីសក្តិ ៥ អ៊ុតសំអុន -ទៅគ្រូសុខ នៅតំបន់២៥ ។
ក្តាប់បានហើយ បងណាតបានឱ្យខ្ញុំ ប្រញាប់ទៅរាយការណ៍ឱ្យតាជ័យ ។ ព្រោះការ-ដែលវាឆ្លើយនេះ បែកការណ៍ក្នុងមហាជនមួយចំនួនហើយ ។
តាជ័យ ក៏បានសំរេចឱ្យយកអាលីតេងនោះទៅកំទេច ដើម្បីជៀសវាងកុំឱ្យបែកការណ៍ធំទាន់ ។

នៅដើមឆ្នាំ១៩៧៣ ខ្ញុំបានទាក់ទងខូចសិលធម៌ ជាមួយនារីម្នាក់ឈ្មោះភុល ហៅទន ។ នារីនេះ ជាស្ត្រីមេម៉ាយ អាយុ២៤ឆ្នាំ ហើយត្រូវជាសាច់ញាតិរបស់ខ្ញុំ ។
ហើយនារីនេះ ក៏នៅធ្វើការក្នុងកងបង្កបង្កើនផលរបស់សន្តិសុខដែរ ។
នារីទននេះ និងខ្ញុំ ស្និតស្នាលគ្នាស្រាប់តាំងពីមុនមក ហើយមកនៅសន្តិសុខ កាន់តែជិតស្និតគ្នាខ្លាំងថែមទៀត រួចក៏បានខូចសិលធម៌ជាមួយគ្នា ។
២០.៧.៧៨ ម៉ឹង តេង
បន្ទាប់មក ខ្ញុំក៏បានទាក់ទងឈ្មោះស្រាយប្រធានមន្ទីរតំបន់ ដើម្បីដកនារីទននេះឱ្យ -ទៅមូលដ្ឋានវិញ ។

បន្ទាប់មក នៅដើមឆ្នាំ១៩៧៣នោះដែរ តាជ័យបានឱ្យខ្ញុំ និងបងណាត ទៅកៀបសួរចំឡើយពីឈ្មោះជិនវ៉ាន់ ។ ឈ្មោះនេះជាអ្នកមកពីហាណូយជាមួយស៊ានសាន ហើយបានរួមសកម្មភាពជាមួយស៊ានសាន ក្នុងទំនាស់នៅក្នុងតំបន់ កាលពីចុងឆ្នាំ១៩៧១ ។

ហើយឈ្មោះនេះ បានគេចខ្លួនមួយរយៈ ក្រោយបាតុភាពទំនាស់ រួចក៏ចាប់បានមកវិញហើយយកមកឃុំឃាំងក្នុងសន្តិសុខ ។

សួរចំលើយធ្វើឈាំរៀងហើយ ខ្ញុំក៏បានឱ្យទៅតាជ័យ ដើម្បីសំរេច ។ ពេលនោះតាជ័យ និងបងណាត ក៏បានពិភាក្សាគ្នា ហើយក៏បានសំរេចយកអ្នកទោសឈ្មោះជិនវ៉ាន់នោះទៅកំទេច មូលហេតុ គឺដើម្បីបំភ័ន្តប្រជាជន និងបក្សឱ្យជឿថា ពួកតាជ័យប្រឆាំងចំពោះអ្នកដែលមកពីហាណូយ ដែលជាខ្ញុំយួន ។ បន្ទាប់មក ខ្ញុំក៏បានយកអាជិន វ៉ាន់នោះទៅកំទេចចោល ។

ហើយបន្ទាប់មក នៅក្នុងដើមឆ្នាំ១៩៧៣នោះ កងទ័ពរបស់ភូមិភាគបូព៌ា២កងវរៈសេនាធំ បានទៅដល់តំបន់២៥បន្តបន្ទាប់ គឺកងលេខ១៧៣ បានទៅដល់មុន រួចបន្ទាប់មក កងលេខ១៦៥ ក៏ទៅដល់ដែរ ។ ហើយកងទាំង២នោះ មានឈ្មោះច័ន្ទចក្រី ទទួលខុសត្រូវរួម ។

ពេលនោះ តាជ័យក៏បានណែនាំបញ្ជាក់ប្រាប់ខ្ញុំ អំពីឈ្មោះច័ន្ទចក្រី ដែលជាកម្លាំងក្នុងខ្សែសេអ៊ីអារបស់តាជ័យដែរ ។ ហើយគាត់ក៏ប្រាប់ខ្ញុំទៀតអំពីកម្លាំងដឹកនាំនៅក្នុងភូមិភាគបូព៌ា គឺតាភឹម និងតាយូក ដែលជាកម្លាំងសំខាន់ផ្នែកខាងលើ ក៏ជាខ្សែរបស់គាត់ទាំងអស់ ដែលជាខ្សែសេអ៊ីអាជាមួយគ្នា ដូចគ្រូសុខបានណែនាំខ្ញុំរួចហើយដែរ ។

តាជ័យ ណែនាំខ្ញុំនោះ ដើម្បីឱ្យខ្ញុំកាន់តែមានស្មារតីប្រយុទ្ធប្រឆាំងបក្សកុម្មុយនិស្តកម្ពុជាកាន់តែខ្លាំង និងដាច់ខាតទៀត ដោយឃើញកម្លាំងខាងបក្សពលករធំ ដែលកក់ក្តៅក្នុងការសំរេចជ័យជំនះលើបក្សកុម្មុយនិស្តកម្ពុជា ។

ហើយពេលនោះ ច័ន្ទចក្រីក៏បានចេញចូលជួបទាក់ទងជាមួយតាជ័យជាប់ ក្នុងការលើកផែនការវាយខ្ទាំង ។

២០.៧.៧៨ បន្ទាប់មក គ្រូសុខក៏បានជួបពិភាក្សាជាមួយខ្ញុំ អំពីភារកិច្ចដែលតាភឹម បានណែនាំក្នុងពេលដែលគ្រូសុខ បានទៅជួបនៅក្នុងឆ្នាំ១៩៧១ នៅឯភូមិភាគបូព៌ា ។ រួចគ្រូសុខបាន

[signature]

ម៉ឹង តេង បានលើកគោលការបំបាត់ទំនាស់រវាងកងទ័ពតំបន់២៥ និងកងទ័ពរបស់ភូមិភាគបូព៌ា ដែលឈ្មោះច័ន្ទចក្រីដឹកនាំ ។ ជាផែនការធ្វើឱ្យមានការល្អក់ល្អាញ អាប់អួររវាងកងទ័ព និងកងទ័ព រវាងកងទ័ព និងប្រជាជន ដើម្បីកុំឱ្យមានពេលវាយខ្ទាំង ។

ហើយផែនការបង្កទំនាស់នេះ ទាំងគ្រូសុខ ទាំងច័ន្ទចក្រី ទាំងតាជ័យ បានឯកភាពគ្នាលើគោលការរួចហើយ ។

គ្រូសុខ ក៏បានលើកទិសការងារឱ្យខ្ញុំ គឺទាំងកងទ័ពរបស់តំបន់ ទាំងកងទ័ពសន្តិសុខ ត្រូវមានវិ-ធានការយាមតាមផ្លូវម៉ត់ចត់ ហើយចាប់ឃាត់ខ្លួនពួកកងទ័ពបូព៌ារបស់ច័ន្ទចក្រី ដែលដើរក្នុង-តំបន់ គ្មានលិខិតអនុញ្ញាត ។ រួចហើយ គ្រូសុខបញ្ជាក់ប្រាប់ខ្ញុំ ឱ្យខិតខំតាមដានក្តាប់ចំណុចខ្សោយរបស់កងទ័ពខាងបូព៌ានោះ ដើម្បីបំផុសឱ្យប្រជាជន-មហាជនវាយប្រហារ ។

បន្ទាប់មក ក្នុងឆ្នាំ១៩៧៣នោះ សភាពទំនាស់ស្មុគស្មាញជាប់ រវាងកងទ័ពតំបន់២៥ និងកងទ័ពបូព៌ា ហើយសំខាន់រវាងប្រជាជន និងកងខាងបូព៌ា ដោយពួកនេះ បានប្រព្រឹត្តសីលធម៌អាវ៉ាសែជាច្រើន ជាមួយកូនចៅប្រជាជន ។ ហើយពេលនោះ កងទ័ពតំបន់ និងកងទ័ពខាងបូព៌ា ក៏មានចាប់ផ្ទាចង ទៅវិញ ទៅមកញឹកញាប់ ។

នៅខែ១២.១៩៧៣ តាជ័យ និងគ្រូសុខ បានណែនាំខ្ញុំ ឱ្យបំផុសប្រជាជនធ្វើបាតុកម្ម-មួយប្រឆាំងនឹងវៀតណាម ។ ពេលនោះ គាត់បានឱ្យដឹកនាំក្បួនបាតុករទៅព័ទ្ធមន្ទីរ របស់អាទីហ៊ុីវ ជាគណៈទាក់ទងវៀតណាម នៅភូមិក្បាលជ្រោយ ក្នុងឃុំពោធិបាន ។

មូលហេតុ ដោយកងទ័ពវៀតណាមបានបាញ់សំឡាប់យុទ្ធជនកងពលចល័តរបស់តំបន់២៥អស់១១នាក់កាលក្នុងខែ១១.១៩៧២ ។ ហើយប្រជាជន ក្តៅក្រហាយ និងចងគំនុំចំពោះពួកវៀតណាមៗ ហើយគោលបំណងរបស់តាជ័យ និងគ្រូសុខ ឱ្យធ្វើបាតុកម្មនោះ គឺគ្រាន់តែបំភ័ន្តភ្នែកប្រាស់ប្រជា-ជន ពន្លត់ភ្លើងកំហឹងរបស់ប្រជាជនតែប៉ុណ្ណោះ ។ ធ្វើឱ្យប្រជាជនមានជំនឿលើពួកគាត់-ថាជាអ្នកប្រឆាំងយួន ហើយគាំទ្រប្រជាជន ។

២០.៧.៧៨

ម៉ឹង តេង

រួចហើយ ខ្ញុំក៏បានអនុវត្តផែនការនោះ ដោយបានបំផុសប្រមូលកម្លាំងប្រជាជនក្នុងឃុំពោធិបាន-ហើយរៀបចំក្បួនបាតុកម្មទៅព័ទ្ធមន្ទីររបស់អាទីហ៊ុីវ ។ រួចក៏បានឱ្យបាតុករបង្ខំឱ្យអាទីហ៊ុីវ-ទៅជួបអង្គការតំបន់២៥ជាបន្ទាន់ដើម្បីដោះស្រាយរឿងឃាតកម្មនោះ ។

ហើយពេលនោះ អាទីហ៊ុីវ ក៏បានសុំបាតុករ ចេញទៅជួបតាជ័យ ដើម្បីដោះស្រាយជូនប្រ-ជាជនកម្ពុជា ។ រួចខ្ញុំក៏បានឱ្យកងទ័ពសន្តិសុខ ទៅនាំអាទីហ៊ុីវចេញមក ហើយនាំទៅឱ្យគ្រូសុខ និងតាជ័យនៅឯមន្ទីរតំបន់ ។

ក្នុងខែ ២.១៩៧៣ តាជីយបានណែនាំខ្ញុំឱ្យទៅជួបអាថៃហុីវ គណៈទាក់ទងវៀត-ណាម ដើម្បីស្នើជំនួយ គ្រាប់ផ្លុះស្ពឹកមួយចំនួន យកទៅវាយខ្មាំង ។ ពេលនោះ គាត់ឱ្យខ្ញុំទៅជាមួយ ហួតសេ គណៈទាក់ទងតំបន់២៥ ។

បន្ទាប់មក ខ្ញុំនិងហួតសេ ក៏បានទៅជួបអាថៃហុីវ រួចក៏ទាក់ទងស្នើបានគ្រាប់ផ្លុះស្ពឹកមួយប្រ-អប់ ដែលមានជាច្រើនគ្រាប់ ខ្ញុំមិនបានចាំចំនួន និងមេរៀសេ.៥ មួយកញ្ចប់ ដែលមានទម្ងន់៤គីឡូក្រាម ។ រួចហើយ ហួតសេ ក៏បានឱ្យខ្ញុំ យកទៅឱ្យតាជីយ នៅមន្ទីរតំបន់ ។

ហើយខែ១២.១៩៧៣នោះ ខ្ញុំបានទៅជួបធ្វើការនៅកន្លែងតាជីយនៅមន្ទីរតំបន់ ពេលនោះ ក៏បានជួបតា "ក" ដែលចុះមកធ្វើការជាមួយតាជីយ ។

ពេលនោះ តា "ក" បានពិភាក្សាជាមួយតាជីយ អំពីការដែលត្រូវរៀបចំកម្លាំងត្រៀមយូរ-អង្វែង សំរាប់ផែនការវាយបក្ស នៅថ្ងៃខាងមុខ ។ ហើយ គាត់ក៏បានលើកពិនិត្យអំពី -បងជា ដែលជាលេខាស្រុកកោះធំ មានលក្ខណៈសម្បត្តិច្រើន ដែលអាចយកជាកម្លាំង -ត្រៀមបាន ។ គឺម្យ៉ាងគ្មានលេចពីការពាក់ព័ន្ធជាមួយខ្សែយួនដែលបែកមុខក្នុងប្រជាជន និងម្យ៉ាងទៀត ប្រជាជនមិនចាប់អារម្មណ៍ថាបងជា ក៏ជាខ្សែក្បត់ជាមួយពួកដែលប្រឆាំង-បក្សនៅក្នុងតំបន់ទេ ។ ហើយម្យ៉ាងទៀត បងជា មានសភាពនឹងនរ ហើយមានលក្ខណៈដែលប្រជាជន-មហាជន ពេញចិត្ត ដែលបានជាកម្លាំងស្ងួននៅក្នុងតំបន់ សំរាប់ដឹកនាំអនុវត្តផែនការវាយបក្ស ។

បន្ទាប់មក តា "ក" និង តាជីយ ក៏បានឯកភាពគ្នា ក្នុងការកំណត់យកបងជា ជាកម្លាំង -ត្រៀមសំរាប់ផែនការយូរអង្វែង ដើម្បីវាយបក្ស ។

រួចហើយ តា "ក" ក៏បានណែនាំឱ្យតាជីយ យកចិត្តទុកដាក់អប់រំពង្រឹងបងជា ថែមទៀត ។
២១.៧.៧៨ ហើយគាត់ឱ្យតាជីយជំរុញភារកិច្ច និងបង្កើននាទីដឹកនាំឱ្យបងជា មួយកំរិតទៀត ដើម្បី
លើកស្មារតីប្រយុទ្ធរបស់បងជា សំរាប់ធានាលើភារកិច្ចដែលបងជា ត្រូវបន្តទទួលការដឹក-
មុឹង តេង នាំអនុវត្តផែនការវាយបក្ស នៅថ្ងៃខាងមុខ ។

ហើយតាជីយ ក៏បានបញ្ជាក់ប្រាប់ខ្ញុំ អំពីបងជា ជាកម្លាំងក្នុងខ្សែសេអ៊ីអារបស់តា "ក" ។

បន្ទាប់មក ក្នុងដើមឆ្នាំ១៩៧៣នោះ ខ្ញុំបានទៅជួបឈ្មោះទៀលលិញ តាមការ-ណែនាំរបស់តាជីយ ។ ពេលនោះ ទៀលលិញ មាននាទីជាគណៈជំលៀសតំបន់២៥ ។

មូលហេតុ គឺដើម្បីសហការចាប់ប្រជាជនជំលៀស២នាក់ ដែលបានវាយប្រហារអង្គការតំបន់២៥ គឺពួកហួតសេ អពីរៀងកងឈ្លប បានតែប្រវិញបន្លំយកប្រាក់របស់ខ្លួន នៅក្នុងពេលដែលជំលៀសចុះមក ។ ប្រជាជនជំលៀសនោះ ២នាក់ឪពុក និងកូន ដែលកូនឈ្មោះយិន តែឪពុក ខ្ញុំភ្លេចឈ្មោះ ផ្ទះនៅឃុំបន្ទាយដែក ស្រុកកៀនស្វាយ តំបន់២៥ ។

ពេលនោះ ខ្ញុំក៏ចាប់អ្នកទាំង២ យកទៅសន្តិសុខ ហើយចោទថាជាគិញពួកអាលន់ណុល ។

គោលបំណងចាប់នោះ គឺធ្វើឱ្យប្រជាជនជំលៀស ក្តៅក្រហាយចំពោះអង្គការ មិនជឿកក់ក្តៅលើអង្គការ ភ័យខ្លាច ហើយរត់ចូលខ្មាំងវិញ ។

បន្ទាប់មក ខ្ញុំ និងរៀលលិញ ក៏បានជួបគ្នាសហការចាប់ប្រជាជនជំលៀស២នាក់ទៀត គឺស្រីឈ្មោះតុល សាមឿន និងប្រុស ខ្ញុំភ្លេចឈ្មោះ ។ ហើយចាប់អ្នកទាំង២នោះ ដោយចោទថា បានប្រព្រឹត្តខូចសិលធម៌ជាមួយគ្នា ។ រួចហើយ ខ្ញុំក៏នាំទៅសន្តិសុខ ដើម្បីឃុំឃាំង សួរចំលើយ ។

គោលបំណងចាប់ គឺដូចគ្នា ដើម្បីឱ្យប្រជាជនភ័យខ្លាច ហើយរត់ចូលខ្មាំងវិញ ។

ក្នុងឆ្នាំ១៩៧៣នោះ ខ្ញុំបានណែនាំ និងចាត់តាំង ឈ្មោះសុខុម និងឈ្មោះគង់ ឱ្យលួចសំឡាប់តាឯក ។ មូលហេតុ ដោយតាឯក បានធ្វើឱ្យបែកការណ៍ ពីរឿងដែលខ្ញុំបានខូចសិលធម៌ ជាមួយនារីឈ្មោះវណ្ណា កាលពីឆ្នាំ១៩៧២ ។

ពេលនោះ តាឯកមាននាទី ជាប្រធានកងបង្កបង្កើនផលរបស់សន្តិសុខ ហើយជាកម្លាំងក្បត់បក្សនៅក្នុងខ្សែរបស់ហួតសេ ដែលហួតសេ បានប្រគល់ឱ្យសន្តិសុខ ទទួលយកមកអប់រំបន្ថែម និងដឹកនាំធ្វើការងារ ។ ហើយឈ្មោះ សុខុម និងគង់ ជាភ្នាក់ងារនៅក្នុងកងបង្កបង្កើនផលជាមួយគ្នាដែរ ។

២២.៧.៧៨

ម៉ឹង តេង

ហើយក្នុងឆ្នាំ១៩៧៣នោះដែរ ខ្ញុំបានទាក់ទងខូចសិលធម៌ជាមួយនារីម្នាក់ឈ្មោះអុន នារីនោះ អាយុ២៤ឆ្នាំ ហើយធ្វើការនៅក្នុងកងបង្កបង្កើនផលរបស់សន្តិសុខដែរ ហើយមាននាទីជាគណៈកង ។

មូលហេតុទាក់ទងបាន ដោយនារីនោះចូលចិត្តហ៊ឺហា សប្បាយលេងសើច ដែលខ្ញុំបានស្និតស្នាល រួចអូសទាញខូចសិលធម៌ជាមួយគ្នា ។ បន្ទាប់មក ឈ្មោះស្រាយ ប្រធានមន្ទីរតំបន់ បានសំរេចឱ្យនារីអុនទៅមូលដ្ឋានវិញ ។

ក្នុងឆ្នាំ១៩៧៣នោះ ឈ្មោះស្រ៊ុនទទួលភារៈកងការពារមន្ទីរឃុំឃាំង បានធ្វើឱ្យ
អ្នកទោសម្នាក់ឈ្មោះ សនសុខហេង រត់រួចពីមន្ទីរឃុំឃាំង ។
អាសនសុខហេងនោះ ជាគិញ្ញពួកអាលន់ណុល ពាក់សក្តិមួយ ដែលវាចូលមកស៊ើបការណ៍នៅ-
ក្នុងតំបន់រំដោះ ហើយត្រូវកងឈ្លបឃុំតាលន់ចាប់បាន រួចបញ្ជូនឱ្យសន្តិសុខ ។
មូលហេតុ អាគិញ្ញនោះរត់រួច គឺជាផែនការរបស់ឈ្មោះស្រ៊ុន ដែលមិនចាក់សោរ និង
មិនយាមការពារ ។

ហើយក្នុងខែ៥.១៩៧៣ ម៉ឹងរ៉ែតបានទៅជួបខ្ញុំនៅសន្តិសុខ ហើយក៏បានរាយការណ៍ឱ្យ
ខ្ញុំក្តាប់បាន អំពីកម្លាំងដែលកសាងបានថែមទៀតនៅក្នុងពេទ្យ ។ កម្លាំងទាំងនោះ គឺ:

១- ឈ្មោះ រ៉ែទ្បអ៊ិរ "នារី"
២- • ទាវអ៊ី •
៣- ឈ្មោះ សុងអ៊ី "យុវជន"
៤- • រ៉ែតគ្រី •

រួចហើយ ម៉ឹងរ៉ែត រាយការណ៍អំពីផ្ទាល់ខ្លួនរបស់វា ដែលត្រូវអង្គការភូមិភាគពិសេស យក-
ពេទ្យតំបន់បញ្ចូលទៅក្នុងពេទ្យភូមិភាគ ដើម្បីបំរើសមរភូមិ ។ ហើយអង្គការទុកឱ្យមន្ទីរ
ពេទ្យមួយកន្លែង នៅភូមិសំប៉ានលើ ក្នុងឃុំព្រែកអំបិល និងបុគ្គលិកពេទ្យមួយចំនួនសំរាប់តំបន់។
ពេលនោះ ម៉ឹងរ៉ែត ក៏ឧទ្ទេសនាមកម្លាំងមួយចំនួន ដែលត្រូវនៅធ្វើការក្នុងពេទ្យតំបន់ ត-
ទៅទៀត ដើម្បីឱ្យខ្ញុំក្តាប់ និងណែនាំអនុវត្តភារកិច្ចបន្ត ។ កម្លាំងទាំងនោះ គឺ:

១- ឡាប៊ីន ហៅជា
២- ប៉ាក
៣- លីវ
៤- ផេង
៥- ឌុក

បន្ទាប់មក ខ្ញុំបានជួបគ្រូសុខ នៅមន្ទីរសន្តិសុខ រួចគាត់ប្រាប់ខ្ញុំអំពី ម៉ឹង រ៉ែត បានទាក់ទងខូច
២២.៧.៧៨ សិលធម៌ជាមួយនារីម្នាក់ឈ្មោះរ៉ែទ្បអ៊ិរ ។ គ្រូសុខ បានប្រាប់ខ្ញុំអំពីចំណុចខ្សោយរបស់នារីរ៉ែទ្បអ៊ិ
ជាកូនអ្នកធូរធា ចូលចិត្តសប្បាយ ហើយធ្លាប់ធ្វើការជិតស្និតជាមួយរ៉ែត រួចវាក៏បានទាក់ទង
ម៉ឹង តេង អូសទាញ ខូចសិលធម៌ជាមួយគ្នា ។
រួចហើយ ដើម្បីការពារម៉ឹងរ៉ែត គ្រូសុខ ក៏បានដកនារីរ៉ែទ្បអ៊ិរចេញពីពេទ្យ ហើយឱ្យ-
ទៅធ្វើការក្នុងមន្ទីរតំបន់វិញ ។

នៅក្នុងពាក់កណ្ដាលឆ្នាំ១៩៧៣នោះ កងវរៈ១១២ ចាប់បានឈ្មួញម្នាក់ឈ្មោះ-ញ៉ាក់ ដែលដឹកជញ្ជូនទំនិញជាច្រើនមកពីភ្នំពេញ ។
ពេលនោះ បងណាតក៏បានបញ្ជូនឈ្មួញនោះ ទៅសន្តិសុខ ដើម្បីពិនិត្យស៊ើបសួរធ្វើសំណុំ-រឿង ។ បន្ទាប់មក ក្រោយពីបានសួរចំលើយហើយ ឈ្មួញឈ្មោះញ៉ាក់នោះ ក៏បានឆ្លើយឱ្យការថា វាជាគិញសម្ងាត់របស់គ្រូសុខ សំរាប់ទាក់ទងការងារពីគ្រូសុខ ទៅសិក្ដិ៍ អ៊ុត សំអុន នៅបន្ទាយស្រែពកតូច ហើយវាបង្កប់ជាប្រជាជន ដែលមានទីលំនៅញុ ភូមិស្រែពកតាដួង ឃុំស្រែពកថ្មី ក្នុងស្រុកកោះធំ ។ ហើយវា ទទួលការអប់រំណែនាំផ្ទាល់ពីគ្រូសុខ បន្តបន្ទាប់ ។
រួចហើយ ខ្ញុំក៏បានទៅជួបរាយការណ៍ឱ្យតាជ័យ រួចគាត់ក៏ក្ដាប់បានហើយក៏ណែនាំខ្ញុំ ឱ្យ-ថែរក្សាឈ្មោះញ៉ាក់នោះ នៅក្នុងសន្តិសុខឱ្យបានត្រឹមត្រូវ ដើម្បីការពារកម្លាំង -ព្រោះឈ្មោះញ៉ាក់នោះ មិនទាន់ដែលមានបែកមុខនៅក្នុងប្រជាជន ។

បន្ទាប់មក បងណាត បានចាប់បញ្ជូនយុទ្ធជនម្នាក់ ដែលជានិរសាគាត់ផ្ទាល់ឱ្យ ទៅសន្តិសុខទៀត ។ យុទ្ធជននោះ ខ្ញុំភ្លេចឈ្មោះ ដែលបងណាតរាយការណ៍ថាវាប៉ង បាញ់សំឡាប់គាត់ ។ តែយុទ្ធជននោះ តាមគ្រូសុខប្រាប់ខ្ញុំ គឺបានវាយប្រហារបងណាត ពីរឿងទាក់ទងខូចសីលធម៌ រវាងបងណាត និងនារីម្នាក់ឈ្មោះសារី នៅក្នុងកងទ័ព ។ រួចខ្ញុំក៏បានទទួលយុទ្ធជននោះ យកទៅឃុំឃាំង ហើយវាយសួរចំលើយ តែវាមិនឆ្លើយ ឱ្យពត៌មានសោះ បងណាតក៏បានជំរុញឱ្យវាយកៀបសួរទៀតរហូតយុទ្ធជននោះស្លាប់ ។

នៅក្នុងឆ្នាំ១៩៧៣នោះដែរ ខ្ញុំបានទៅជួបរាយការណ៍ឱ្យតាជ័យ អំពីកម្លាំង ដែលខ្ញុំអប់រំកសាងបានបន្ថែមទៀតនៅក្នុងសន្តិសុខ ។ កម្លាំងទាំងអស់នោះគឺ:

២២.៧.៧៨
[signature]
ម៉ឹង តេង

| | |
|---|---|
| ១- ឈ្មោះ ស្រ៊ុយ | ៤- ឈ្មោះ គ្រិត |
| ២- " ដែត | ៥- " វ៉ន |
| ៣- " លាន | ៦- " ហុង |

អ្នកទាំង៦នេះ ក៏សុទ្ធជាមនុស្សដែលខ្ញុំប្រមូលមកក្តាប់នៅធ្វើការក្នុងសន្តិសុខ ហើយអប់រំកសាង រួចអូសទាញបញ្ចូលបានមកក្នុងខ្សែសេអ៊ីអារបស់ខ្ញុំ នៅក្នុងឆ្នាំ១៩៧៣ ។

ហើយ អ្នកទាំងនេះ សុទ្ធតែទទួលការងារខាងស៊ើបសួរខ្មាំងធ្វើសំណុំរឿង និងជាយុទ្ធ-ជនយាមការពារកន្លែងឃុំឃាំងអ្នកទោស ។ រួចហើយ ខ្ញុំក៏បានណែនាំភារកិច្ច ឲ្យអ្នក-ទាំងនេះអនុវត្ត ដូចកម្លាំងមុនៗដែរ ។

ហើយក្នុងពាក់កណ្ដាលឆ្នាំ១៩៧៣នោះដែរ មានមេខ្មែរសេរីម្នាក់ឈ្មោះ - ខៀវ ណយ បានចូលមកដល់តំបន់រំដោះក្នុងតំបន់២៥ ។ ពេលនោះ វាបានចូលមក ជាមួយភ្នាក់ងាររបស់វា២នាក់ទៀត ហើយឈ្លបឃុំត្រើយស្លាចាប់បាន រួចបញ្ជូនឲ្យសន្តិសុខ ។ លុះសួរចម្លើយ អាខៀវ ណយ សារភាពអំពីប្រវត្តិ និងបេសកកម្មរបស់វាដែលចូលមកក្នុងតំបន់រំដោះ តាមបញ្ជារបស់អាអ៊ិន តាំ ។ ប្រវត្តិវា គឺជាមេខ្មែរសេរីម្នាក់ពាក់សក្តិ៣ ហើយវាត្រូវជាប្អូនរបស់លោកសង្ឃឈ្មោះខៀវ ជុំ និងជាឪពុកមារបស់បងណាត ហើយស្រុកកំណើតវា នៅភូមិអន្លង់តាសេក ឃុំព្រែកអំបិល ក្នុងស្រុកស្អាង តំបន់២៥ ។ ហើយបេសកកម្មរបស់វា ដែលចូលមកក្នុងតំបន់រំដោះក្នុងតំបន់២៥នេះ ក្នុងគោលបំណង-រកជួបអ្នកដឹកនាំបដិវត្តនៅក្នុងតំបន់២៥ ដើម្បីចរចាឈប់ច្បាំង ។ ហើយបំណង ដែលសំខាន់ទៀត គឺវាចូលមកដើម្បីជួបបងណាតផ្ទាល់ ហើយវាបញ្ជាក់ថា បងណាត ជាខ្សែរបស់វាក្នុងខ្សែខ្មែរសេរី ដែលវាបានចាត់តាំងបង្កប់ក្នុងបដិវត្តតាំងពីឆ្នាំ១៩៦២ តាមរយៈតានន សួន ហៅជ័យ ។

សួរហើយ ខ្ញុំក៏បានទៅរាយការណ៍ឲ្យតាជ័យ នៅមន្ទីរតំបន់ ។ គាត់ក៏បានសំរេច ឲ្យខ្ញុំយកអាខៀវ ណយ និងភ្នាក់ងារវា២នាក់ទៀតនោះ ទៅកំទេចចោល ។ គោលបំណង ដែលតាជ័យ សំរេចនោះ គឺដើម្បីការពារមុខមាត់បងណាត ដែលនៅក្នុងខ្សែក្បត់បក្សជាមួយគ្នា កុំឲ្យបែកការណ៍ដល់ប្រជាជន-មហាជន ។

២២.៧.៧៨
ម៉ឹង តេង

បន្ទាប់មក ក្នុងឆ្នាំ១៩៧៣នោះ គ្រូសុខ បានជួបខ្ញុំនៅមន្ទីរតំបន់ កន្លែង-តាជ័យ រួចគាត់ក៏បានប្រាប់ខ្ញុំ អំពីបងណាត បានខូចសីលធម៌ជាមួយនារីម្នាក់ឈ្មោះហ៊ុ ។ នារីនេះ មាននាទីជាប្រធាននារីតំបន់ ហើយត្រូវជាប្អូនរបស់គ្រូជាង ។ ហើយគ្រូសុខ បានបញ្ជាក់ប្រាប់ខ្ញុំថានារីហ៊ុ និងបងណាត បានស្គាល់ទាក់ទងគ្នាតាំងពីនៅភ្នំពេញក្នុងសម័យតស៊ូសម្ងាត់ម្លេះ ។

រួចមកដល់ក្នុងតំបន់រំដោះ ក្នុងពេលសង្គ្រាមនោះ អ្នកទាំង២ កាន់តែបានស្និតស្នាលគ្នា -
ខ្លាំងទៀត ក្នុងពេលដែលបងណាត មកធ្វើការនៅតំបន់២៥ ។ រួចបន្ទាប់មក អ្នកទាំង
២ ក៏បានខូចសិលធម៌ជាមួយគ្នា ។

បន្ទាប់មក ខ្ញុំបានជួបបងណាត នៅមន្ទីរតំបន់ ។ ពេលនោះ ខ្ញុំក៏បានរាយ-
ឱ្យគាត់ អំពីប្អូនខ្ញុំឈ្មោះម៉ឹង ថែត ជាកម្លាំងក្នុងខ្សែសេអ៊ីអារបស់ខ្ញុំ ដើម្បីឱ្យគាត់ -
ក្តាប់បាន ហើយទទួលស្គាល់ ដឹកនាំធ្វើការងារ និងធ្វើសកម្មភាពនៅក្នុងកងទ័ព និងក្នុង
ពេទ្យ ។ ព្រោះម៉ឹងថែត ត្រូវចូលធ្វើការក្នុងក្របខ័ណ្ឌភូមិភាគពិសេស ដែលជាប់ការ -
ងារកៀកកិតជាមួយបងណាត ។

នៅក្នុងឆ្នាំ១៩៧៣នោះ តាជ័យបានឱ្យខ្ញុំ ទៅចាប់ឈ្មោះចន្ថា ជាពេទ្យតំបន់
ហើយជាកម្លាំងក្នុងខ្សែរបស់ម៉ឹង ថែត ។ ជាមូលហេតុ ដោយឈ្មោះចន្ថានេះ បានធ្វើ
ឱ្យបែកការណ៍ថា គ្រូសុខជំរុញវាឱ្យចាក់ថ្នាំសំឡាប់យុទ្ធជនរបួសម្នាក់ នៅមន្ទីរពេទ្យ-
ព្រែកតាកុក កាលពីឆ្នាំ១៩៧២ ។ ហើយតាជ័យឱ្យចាប់ ដោយចោទថា វាជាគិញ
ខ្មាំងដែលបង្កប់ក្នុងបដិវត្ត ។
បន្ទាប់មក ខ្ញុំក៏បានអនុវត្តសេចក្តីសំរេចនេះ ដោយបានទៅចាប់ពេទ្យឈ្មោះចន្ថានោះ
យកមកសន្តិសុខ រួចវាយសួរចំលើយអំពីរឿងគិញបង្កប់ ។ តែមិនបានចំលើយតាមការ-
ចោទ តាជ័យក៏បានជំរុញឱ្យវាយសួរខ្លាំងថែមទៀត រហូតពេទ្យចន្ថានោះស្លាប់ ។

បន្ទាប់មក ក្នុងឆ្នាំ១៩៧៣នោះ តាជ័យ បានឱ្យខ្ញុំទៅចាប់ឈ្មោះ ទៀងហាវ ។
ឈ្មោះនេះ ជាអតីតៈប្រធានតំបន់២៥ក្នុងឆ្នាំ១៩៧០ ។ ហើយកម្លាំងនេះ នៅក្នុង-
ខ្សែជាមួយគ្រូសុខ រួចតាជ័យបានណែនាំឱ្យស្គាល់រួចហើយ ដើម្បីទាក់ទងធ្វើការងារ ។
២២.៧.៧៨ មូលហេតុចាប់ ដោយទៀងហាវ ត្រូវបែកមុខអំពីរឿងបំផុសប្រជាជនធ្វើបាតុកម្មប្រឆាំង
និងអង្គការនៅឃុំព្រើយស្លា ពីរឿងដកដីរបស់អ្នកនៅតំបន់ខ្សាំង ។
ម៉ឹង គេង ចាប់ហើយ តាជ័យក៏បានឱ្យខ្ញុំ នាំយកទៅប្រគល់ឱ្យគ្រូសុខ ដើម្បីឱ្យផ្នែកខាងមន្ទីរយោ-
ធាគ្រប់គ្រងថែរក្សា ។ គោលបំណង គឺដើម្បីការពារកម្លាំងក្នុងខ្សែជាមួយគ្នា ។
ឯចំពោះការចាប់ ទៀងហាវ គឺគ្រាន់តែធ្វើបំភិតប្រជាជនប៉ុណ្ណោះ ។

នៅក្នុងចុងឆ្នាំ១៩៧៣ ខ្ញុំបានបំផុសជំរុញឈ្មោះស្រេង ឱយខូចសិលធម៌ ។ ឈ្មោះនេះ ជាកម្លាំងនៅក្នុងខែ្មរបស់ខ្ញុំ ហើយដែលនៅរួមធ្វើការងារក្នុងក្រសួងសន្តិសុខ ។ រួចហើយ ឈ្មោះស្រេង ក៏បានទាក់ទងជាមួយនារីម្នាក់ឈ្មោះសឿន ជាកូនរបស់ប្រជាជនដែលផ្ទះនៅជិតមន្ទីរឃុំឃាំងអ្នកទោស ។ បន្ទាប់មក ការទាក់ទងកាន់តែជិតស្និត រហូតបានខូចសិលធម៌ជាមួយគ្នា ។

ហើយនៅចុងឆ្នាំ១៩៧៣នោះ ខ្ញុំបានទៅជួបតាលិញ ដើម្បីពិភាក្សាជំរុញឈ្មោះស៊ុង ឱយចូលទៅបក្កប់ក្នុងកងទ័ព ។ ពេលនោះ តាលិញ ជាគណៈស្រុកកោលធំទទួលភារៈខាងសន្តិសុខ ហើយដែលគាត់បានទទួលឈ្មោះស៊ុងដែលជាកម្លាំងក្នុងខែ្មរបស់ខ្ញុំ ឱយនៅក្ដាប់យុទ្ធជនសន្តិសុខស្រុក ។
បន្ទាប់មក តាលិញ ក៏បានឱទ្ទេសនាមឈ្មោះស៊ុងនោះ ឱយទៅកងវរៈ១១៩ តាមការណែនាំរបស់តាជ័យ ដើម្បីឈ្មោះខឿន ដែលជាគណៈវរៈទទួលរៀបចំទៅក្នុងកង ។

បន្ទាប់មក ក្នុងខែ១០.១៩៧៣ ខ្ញុំបានទៅជួបពិភាក្សាលើកទិសធ្វើការ អំពីការចាត់តាំងសហករណ៍ តាមការណែនាំរបស់តាជ័យ ។
ជាគោលបំណង គឺរៀបចំការអនុវត្ត បំភ្លៃមាគ៌ាបក្ស ។ ពេលនោះ ខ្ញុំបានជំរុញបងជា រៀបចំចាត់តាំង ជាដំបូងនៅក្នុងឃុំកំពង់កុង ដោយចាត់តាំងជាសហករណ៍កំរិតខ្ពស់ ។ តែការចាត់តាំងក្នុងពេលនោះ មិនបានសំរេច ដោយប្រជាជនបដិសេធ ។

បន្ទាប់មកទៀត ក្នុងចុងឆ្នាំ១៩៧៣នោះ តាជ័យណែនាំខ្ញុំ ឱយប្រមូលអ្នកទោសវៀតណាមទាំងអស់ ដែលជាប់ឃុំឃាំងនៅសន្តិសុខ ។ ហើយគាត់ឱយខ្ញុំ នាំយកទៅប្រគល់ឱយអាថៃហ៊ីវ វិញ ។ តាជ័យ ឱយខ្ញុំធ្វើការងារនោះ ជាមួយ ហួតសេ គណៈទាក់ទងតំបន់២៥ ។

២២.៧.៧៨
ម៉ុង តេង

បន្ទាប់មក ខ្ញុំក៏បានរៀបចំពួកអ្នកទោសវៀតណាមទាំងអស់ជាង៨០នាក់ ទាំងអាណិកជនទាំងកងទ័ព ដែលចាប់បានបន្តបន្ទាប់មក ហើយឃុំឃាំងនៅសន្តិសុខ ។ រួចខ្ញុំក៏បាន ទៅជួបរាយការណ៍ឱយហួតសេ ។ រួចហើយ ហួតសេ និងខ្ញុំ ក៏បាននាំវៀតណាមទាំងនោះទៅប្រគល់ឱយអាថៃហ៊ីវ ដែលជាគណៈទាក់ទងវៀតណាម នៅមន្ទីររបស់វា នៅឃុំពោធិបាន ។

ឆ្នាំ ១៩៧៤ ខ្ញុំបានជួបរាយការណ៍ឱ្យតាជ័យនៅមន្ទីរតំបន់ អំពីកម្លាំងដែលបាន-កសាងថែមថ្មីទៀត នៅក្នុងសន្តិសុខ ។ កម្លាំងទាំងអស់នោះគឺ:

| | | |
|---|---|---|
| ១- ឈ្មោះ ម៉ុត | ៣- ឈ្មោះ ម៉ែត | ៥- ឈ្មោះ រិន |
| ២- " ថោង | ៤- " ហន | ៦- " ម៉ឺន |
| | | ៧- " ឈើន |

អ្នកទាំងអស់នេះ ក៏សុទ្ធជាមនុស្សដែលខ្ញុំប្រមូលមកក្តាប់ ហើយកសាងនៅក្នុងសន្តិសុខ រួចក៏បានបញ្ចូលក្នុងខ្សែរសេអ៊ីអារបស់ខ្ញុំ នៅក្នុងឆ្នាំ ១៩៧៤ ។ ហើយអ្នកទាំងនេះ មានភារ-កិច្ចនៅក្នុងសន្តិសុខជាកងការពារមន្ទីរឃុំឃាំងអ្នកទោសទាំងអស់ ដែលខ្ញុំបានណែនាំឱ្យធ្វើ-សកម្មភាពដូចកម្លាំងមុនដែរ ។

រួចហើយ ខ្ញុំក៏បានណែនាំឱ្យអ្នកទាំងអស់នេះស្គាល់ឈ្មោះវ៉ាន់លី ដែលជាគណៈសន្តិសុខដែរ ជាកម្លាំងក្នុងខ្សែរបស់គ្រូសុខ ដើម្បីឱ្យអ្នកទាំងនេះបានទាក់ទងធ្វើការងារ ។

នៅដើមឆ្នាំ១៩៧៤នោះ ខ្ញុំបានទាក់ទងខូចសីលធម៌ជាមួយនារីម្នាក់ឈ្មោះយិន-ហៅយាន ។ នារីនេះ អាយុ២២ឆ្នាំ ហើយធ្វើការនៅក្នុងកងបង្កបង្កើនផលរបស់សន្តិសុខ-ហើយមាននាទីជាគណៈក្រុម ។

ហើយមូលហេតុទាក់ទងបាន ក៏ដូចនារីខាងមុនដែរ គឺជាអ្នកចូលចិត្តសប្បាយភ្លើតភ្លើន ដែលខ្ញុំទាក់ទងអូសទាញបាន ហើយខូចសីលធម៌ជាមួយគ្នា ។

បន្ទាប់មក ខ្ញុំបានណែនាំជំរុញឈ្មោះស្រ៊ិន ឱ្យធ្វើសកម្មភាពនៅក្នុងកន្លែងឃុំឃាំង-អ្នកទោស ។ ឈ្មោះនេះ ជាគណៈកងការពារ និងជាកម្លាំងក្នុងខ្សែរបស់ខ្ញុំ ។

បន្ទាប់មក ឈ្មោះនេះ ក៏បានបំផុសយុទ្ធជនម្នាក់ឈ្មោះយ៉ុង ឱ្យខូចសីលធម៌ជាមួយស្រីអ្នកទោស ។

២២.៧.៧៨ រួចហើយ ឈ្មោះយ៉ុង ក៏បានអនុវត្តតាមការបំផុសនោះ គឺក្នុងរយៈពេលដើមឆ្នាំ១៩៧៤នោះ វាបានខូច ជាមួយស្រីអ្នកទោសអស់២នាក់ គឺឈ្មោះភិន និងឈ្មោះអេង ។

ម៉ឹង តេង ហើយស្រី២នាក់នេះ សុទ្ធជាភ្នាក់ងារគិញរបស់ពួកអាលន់ណុល ដែលចូលមកស៊ើបការណ៍ក្នុងមូល-ដ្ឋានរំដោះ ហើយត្រូវកងទ័ពចាប់បាន ។ បន្ទាប់មក យុទ្ធជនឈ្មោះយ៉ុង ក៏បានឱ្យអ្នកទោសស្រីទាំង២នោះរត់រួចពីកន្លែងឃុំឃាំង ដោយមិនចាក់សោ ហើយមិនយាមការពារ ។

បន្ទាប់មក ខ្ញុំបានបំផុស និងជំរុញឈ្មោះស្រេង ឱ្យទាក់ទងសិលធម៌អាវ៉ាវែល ។ ឈ្មោះនេះ ក៏ជាកម្លាំងក្នុងខ្សែររបស់ខ្ញុំ ហើយនៅធ្វើការងារក្នុងក្របខ័ណ្ឌសន្តិសុខដែរ ។ រួចឈ្មោះស្រេង ក៏បានធ្វើសកម្មភាពទាក់ទងជាមួយនារីម្នាក់ឈ្មោះខុន ។ នារីនេះអាយុ ១៩ឆ្នាំ ហើយនៅធ្វើការខាងកងបក្ខបង្កើនផលរបស់សន្តិសុខ ។ រួចហើយអ្នកទាំង២ ក៏បានលេងសើចស្និតស្នាល ហើយក៏បានខូចសិលធម៌ជាមួយគ្នា ។ ពេលនោះ ស្រេង នាទីជាប្រធានកង ៗ

បន្ទាប់មក ខ្ញុំក៏បានដកឈ្មោះស្រេងចេញពីកងនេះ រួចឱ្យទៅនៅធ្វើការក្នុងក្រុមសួរចំ-ឡើយវិញ ។

ខែ៣.១៩៧៤ ខ្ញុំបានជំរុញឱ្យឈ្មោះ ប៉ុលទេវ ស្រ៊ុយ និងគ្រិត ដែលទទួល-ភារៈធ្វើស្រែប្រាំង ឱ្យធ្វើសកម្មភាពបំផ្លាញសំណាប និងសន្ទូង ។

បន្ទាប់មក អ្នកទាំង៣នេះ ក៏បានអនុវត្តផែនការបំផ្លាញស្រូវសន្ទូងនោះអស់ជាង៣០ហិកតា នៅក្នុងការដ្ឋានស្រែប្រាំងរបស់សន្តិសុខ នៅក្នុងឃុំប្រាសាទ ។ ផែនការបំផ្លាញនោះគឺ អ្នកទាំង៣ បានដឹកនាំកម្លាំងរៀបចំដីស្រែ រួចស្ទូង សំរុកទៅមុខរហូត ឥតមានគិតដោះ-ស្រាយបញ្ហាស្មៅ និងទឹកឱ្យសន្ទូងទេ ដែលធ្វើឱ្យស្រូវសន្ទូងខាងដើមជាង៣០ហិកតា ត្រូវស្វិតក្រៀមខូច ។

រួចហើយ ដោយអ្នកទាំង៣នេះត្រូវបែកមុខ ជាអ្នកបំផ្លាញបក្ស ខ្ញុំក៏បានទាក់ទងទៅគ្រូ-ហ៊ាង ដែលជាប្រធានមន្ទីរតំបន់ក្នុងពេលនោះ ឱ្យដោះស្រាយ ដើម្បីការពារកម្លាំង ។ រួចគ្រូហ៊ាង ក៏បានទទួលអ្នកទាំង៣នេះ ទៅធ្វើការនៅក្នុងការដ្ឋានរបស់តំបន់វិញ ។

បន្ទាប់មក ក្នុងឆ្នាំ១៩៧៤នោះ គ្រូហ៊ាង គ្រូជាង និងខ្ញុំ បានជួបគ្នានៅ-មន្ទីរតំបន់ ។ គោលបំណង គឺដើម្បីពិនិត្យពិភាក្សា និងដោះស្រាយរឿងរបស់ឈ្មោះ-ស្រេង ។ ឈ្មោះនេះ ជាកម្មាភិបាលមន្ទីរតំបន់ ហើយជាកម្លាំងក្នុងខ្សែររបស់គ្រូជាង ។ ហើយឈ្មោះនេះ បានខូចសិលធម៌ជាមួយនារីម្នាក់ នៅធ្វើការខាងតំបាញរបស់តំបន់ រហូតដល់ស្រើនខែទើបបែកការណ៍ ។

ហើយការជួបគ្នាពេលនោះ គឺរកការដោះស្រាយ ដើម្បីការពារកម្លាំងក្នុងខ្សែរជាមួយ-គ្នា សំរាប់រួមគ្នាសំរេចផែនការវាយបក្សនៅថ្ងៃខាងមុខ ។

២២.៧.៧៨

ម៉ឹង តេង

ពេលនោះ កីបានឯកភាពគ្នាផ្លះឈ្មោះស្រេងចេញពីមន្ទីរតំបន់ ។
ហើយស្រូហាង ដែលជាអ្នកសំរេច និងអ្នកអនុវត្តរឿងនោះ កីបានយកឈ្មោះស្រេងនេះ
ទៅនៅធ្វើការក្នុងការដ្ឋានបង្កបង្កើនផលរបស់តំបន់វិញ ។

បន្ទាប់មក ខ្ញុំបានជួបគ្រូសុខ នៅសន្តិសុខកន្លែងខ្ញុំផ្ទាល់ ។
ហើយជួបគ្នាក្នុងពេលដែលគ្រូសុខ ភៀសមកពីសមរភូមិ ដែលក្នុងពេលគ្រូសុខ មាននាទីជា-
គណៈកងពល១២ ជាមួយបងណាត ។ ពេលនោះ គ្រូសុខ បានប្រាប់ខ្ញុំអំពីសកម្មភាពកសាង -
កម្លាំងសេរីនៅក្នុងចំណោមយុទ្ធជន គឺមានប្រសិទ្ធិភាព តាំងពីសាលាទី១ ដែលមន្ទីរយោធា
តំបន់បានរៀបចំនៅក្នុងឃុំព្រែកអំបិល កាលក្នុងឆ្នាំ១៩៧៣ រហូតដល់លើកសាលានោះ ទៅ
នៅលើកោះខ្សាច់ទន្លា ។
គាត់បញ្ជាក់ប្រាប់ខ្ញុំថាអប់រំបានច្រើន រួចបានបញ្ចូលទៅក្នុងកងទ័ពឱ្យធ្វើសកម្មភាពអូសទាញ
គ្នា រត់ចោលកង ក្នុងពេលបើកសមរភូមិម្តងៗ ។
រួចហើយ គ្រូសុខ កីបានបញ្ជាក់ប្រាប់ខ្ញុំទៀត អំពីបងណាត ដែលកាលពីឆ្នាំ១៩៧៣ កីបានខូចសីល-
ធម៌ ជាមួយនារីម្នាក់ឈ្មោះសារីទៀត ។ នារីនេះ ត្រូវជាប្អូនរបស់ឈ្មោះស្រាយ ដែល
ជាកម្លាំងក្នុងខ្សែរបស់គាត់ ។ ហើយនារីសារី ជាកម្លាំងក្នុងខ្សែរបស់ មុីងទែត ។

រួចហើយ ក្នុងឆ្នាំ១៩៧៤នោះ តាជ័យបានឱ្យខ្ញុំខិតខំតាមរកចាប់យុទ្ធជន ដែលរត់
ចោលសមរភូមិ ត្រឡប់មកមូលដ្ឋានវិញ ។ គាត់បានឱ្យខ្ញុំចាប់ រួចយកទៅឃុំឃាំង ធ្វើ -
ទណ្ឌកម្ម ហើយបញ្ជូនទៅកងវិញ ។
ពេលនោះ ខ្ញុំចាប់បានបន្តបន្ទាប់ តែមិនបានចាំចំនួន និងឈ្មោះ ហើយសុទ្ធតែបានប្រគល់ឱ្យ
កងពល១២វិញ ដោយឈ្មោះ យូប៉េងគ្រី ហៅម៉ុន ចុះទៅទទួលយកផ្ទាល់ ។

២២.៧.៧៨
មុីង តេង

នៅថ្ងៃ១៦.១៩៧៤នោះ តាជ័យបានណែនាំខ្ញុំ ឱ្យរៀបចំកម្លាំងក្នុងខ្សែរបស់ខ្ញុំ-
៣នាក់ ដើម្បីដាក់ឱ្យចូលទៅបង្កប់នៅក្នុងកងទ័ពតំបន់ សំរាប់ផែនការយូរអង្វែង ។
ពេលនោះ ខ្ញុំកីបានរៀបចំកម្លាំងទាំង៣នោះ គឺ:

១- ឈ្មោះ ផេង ២- ឈ្មោះ លាន ៣- ឈ្មោះ ហុង

រួចហើយ ខ្ញុំកីបានណែនាំភារកិច្ចមួយចំនួន ដើម្បីអ្នកទាំង៣នេះយកទៅអនុវត្ត នៅក្នុងកងទ័ព ។

១- ឱ្យខិតខំកសាងកម្លាំង នៅក្នុងកងទ័ពថែមទៀត

២- ឱ្យបំផុសចលនាយុទ្ធជន រត់ចោលកង ក្នុងពេលបើកសមរភូមិ

៣- ឱ្យបំផ្លិចបំផ្លាញបោះបង់ចោល អាវុធ និងគ្រាប់រំសេវ

រួចហើយ ខ្ញុំបានណែនាំអ្នកទាំង៣ ឱ្យស្គាល់ឈ្មោះ ផន ជាស្នងការវរៈ និងជាកម្លាំងក្នុងខ្សែរបស់គ្រូសុខ ដើម្បីឱ្យអ្នកទាំង៣នេះ បានទាក់ទងធ្វើសកម្មភាពនៅក្នុងកងទ័ព ។ បន្ទាប់មក ខ្ញុំក៏បានបញ្ជូនអ្នកទាំង៣ ទៅឱ្យឈ្មោះហ៊ាង នៅមន្ទីរតំបន់ ដើម្បី យកទៅរៀបចំចាត់តាំងបញ្ចូលទៅក្នុងកងទ័ព ។

បន្ទាប់មក ក្នុងឆ្នាំ១៩៧៥នោះ ខ្ញុំបានទាក់ទងខូចសីលធម៌ជាមួយនារីម្នាក់ទៀត ឈ្មោះញាន ហៅយឿន ។ នារីនេះ ត្រូវជាសាច់ញាតិរបស់ខ្ញុំ ហើយក៏នៅរួមធ្វើការក្នុងកងបង្កបង្កើនផលរបស់សន្តិសុខដែរ ដែលមាននាទីជាគណៈកង ។
រួចហើយ ខ្ញុំក៏បានទាក់ទងទៅគ្រូហ៊ាង ជាប្រធានមន្ទីរតំបន់ដកនារីយឿននេះ ទៅឱ្យនៅធ្វើការខាងមន្ទីរយោធាតំបន់វិញ ដើម្បីបិតបាំងរឿងខ្ញុំ និងនារីនេះ ដែលបានខូចសីលធម៌និងគ្នា ។

បន្ទាប់មក ក្នុងពាក់កណ្តាលឆ្នាំ១៩៧៥នោះ តាជ័យបានឱ្យហួតសេ និងខ្ញុំ ទៅជួបទីហហ៊ុវ នៅឯព្រុំដែន ដើម្បីរកកន្លែងដោះស្រាយឱ្យកងទ័ពវៀតណាម និងមន្ទីរផ្សេងៗរបស់វៀតណាមតាំងទីស្នាក់នៅ ។ មូលហេតុ ដោយប្រជាជនកម្ពុជាក្នុងតំបន់២៥ មានកំហឹងចំពោះកងទ័ពវៀតណាម ហើយប្រឆាំងដាច់ខាតមិនឱ្យពួកនេះនៅលើទឹកដីកម្ពុជាតទៅទៀត ។

២៣.៧.៧៨
មុឹង តេង

ពេលនោះ ខ្ញុំ និងហួតសេ ក៏បានទៅជួបអាទីហហ៊ុវ ពិភាក្សាគ្នានៅមន្ទីរឃុំសំពៅពូន ដើម្បីដោះស្រាយរកកន្លែងឱ្យវៀតណាមស្នាក់នៅ ។ ហួតសេ ក៏បានពិនិត្យ រួចសំរេចប្រគល់ទីព្រៃខាងក្រោយឃុំសំពៅពូនទាំងអស់ និងទីព្រៃក្រោយឃុំព្រែកស្តីមួយភាគ ដើម្បីឱ្យវៀតណាមស្នាក់នៅ ។ រួចហើយ ហួតសេ ក៏បានណែនាំអាទីហហ៊ុវ ឱ្យនាំទាំងកងទ័ព ទាំងមន្ទីរផ្សេងៗរបស់វៀតណាម ទៅនៅក្នុងទីព្រៃដែលបានកំណត់ឱ្យនោះ ដែលដាច់ពីប្រជាជន គ្មានទំនាស់ជាមួយប្រជាជនទៀត ។

នៅខែ ៨.១៩៧៤ ខ្ញុំបានទៅជួបធ្វើការងារជាមួយតាជ័យ នៅមន្ទីរតំបន់ ។ ពេលនោះ មន្ទីរតំបន់ តាំងនៅក្នុងភូមិព្រែកសំរោង ក្នុងឃុំកោះធំ ស្រុកកោះធំ ។ ខ្ញុំ ក៏បានជួប តាដូដេត ហៅស៊ី នៅកន្លែងតាជ័យ ហើយតាស៊ី បានមកដល់កន្លែងតាជ័យ ២-ថ្ងៃរួចមកហើយ មុននិងខ្ញុំទៅជួបនោះ ។

ពេលនោះ តាជ័យ បានណែនាំខ្ញុំឱ្យស្គាល់ តាដូដេត ហៅស៊ីនោះ ជាកម្លាំងក្នុងខ្សែ - របស់គាត់ ។ ហើយតាស៊ី ជាលេខាតំបន់៣៥ កំពត ។

រួចហើយ តាស៊ីក៏បានណែនាំបង្ហាញឱ្យខ្ញុំឃើញអំពីសភាពការណ៍នៅក្នុងតំបន់របស់គាត់ ដែល-ប្រជាជន កំពង់ជួបការខ្វះខាតអត់ឃ្លាន ។ រួចអង្គការនៅមូលដ្ឋាន និងប្រជាជន កំពង់-ស្អុកស្អាញ ដោយមិនអាចដោះស្រាយការខ្វះខាតនោះបាន ។

តាស៊ីបញ្ជាក់ប្រាប់ខ្ញុំថាគឺជាផែនការដែលគាត់បង្កទំនាស់រវាងអង្គការ និងប្រជាជន ។ ហើយតាស៊ីប្រាប់ខ្ញុំនេះ ដោយគាត់ក្តាប់ខ្ញុំបានរួចហើយ តាមរយៈតាជ័យដែលឧទ្ទេសនាមរូបខ្ញុំឱ្យគាត់ ក្នុងពេលជួបគ្នាជាដំបូង ។

រួចហើយ តាស៊ីបញ្ជាក់អំពីខ្លួនគាត់ដែលថាមកតំបន់២៥ ដើម្បីរកពោតយកទៅដោះ-ស្រាយជីវភាពឱ្យប្រជាជននោះ គឺការពិត គាត់ចេញឱ្យផុតពីតំបន់របស់គាត់មក-ប៉ុណ្ណោះ ។ ហើយការដែលគាត់ចេញនេះ កាន់តែទុកឱ្យសភាពការណ៍នៅក្នុងតំបន់តានតឹងឡើងរវាងប្រជាជន និងអង្គការមូលដ្ឋាន ធ្វើឱ្យសភាពទំនាស់កាន់តែស្រួច ។

ហើយបន្ទាប់មក តាស៊ី មិនទាន់ត្រឡប់ទៅវិញទេ គាត់ទៅសំរាកចាក់ថ្នាំនៅមន្ទីរពេទ្យតំបន់ ដែលតាំងក្នុងភូមិកំពង់គរ ឃុំពោធិបាន កន្លែងគ្រូសុខ អស់ជិត១០ថ្ងៃ។ រួចបន្ទាប់មក តាស៊ីត្រឡប់ទៅតំបន់៣៥វិញ ដោយបានពោតមួយចំនួនតូចយកទៅផង ។
២៤.៧.៧៨ ពោតនោះ តាមតាជ័យប្រាប់ខ្ញុំថាបានចំនួនជិត៣ឡានប៉ុណ្ណោះ ។

ម៉ឹង តេង

បន្ទាប់មក នៅចុងឆ្នាំ១៩៧៤នោះ ខ្ញុំបានជួបទាក់ទងជាមួយបងជា ដើម្បីខ្ញុំ-ចុះទៅពង្រឹងកម្លាំងរបស់ខ្ញុំនៅក្នុងមូលដ្ឋានស្រុកកោះធំ គឺឈ្មោះបេ និងឈ្មោះសួនី ។ មូលហេតុ ដោយអ្នកទាំង២នេះ សុទ្ធតែមានវិបត្តិធ្ងន់ ហើយបានធ្លាក់ពីនាទីអស់មកហើយ គឺឈ្មោះបេ មានរឿងសិលធម៌ ឯឈ្មោះសួនី រឿងបំផុសប្រជាជននាំសេដ្ឋកិច្ចទៅយួន ។

ពេលនោះ ខ្ញុំក៏បានណែនាំពង្រឹងអ្នកទាំង២ ឱ្យខិតខំបន្តសកម្មភាព តទៅទៀត ។
រួចហើយ ខ្ញុំបានឱ្យអ្នកទាំង២ ពើញ នូវភារកិច្ចដែលអ្នកទាំង២អនុវត្តកន្លងមក ធ្វើឱ្យលុក -
លុយញាំញីដល់អង្គការនៅក្នុងមូលដ្ឋានកន្លងមក គឺជាជ័យជំនះក្នុងការអនុវត្តភារកិច្ចវាយបក ៗ
បន្ទាប់មក ខ្ញុំក៏បានណែនាំឱ្យអ្នកទាំង២ គឺឈ្មោះសួនី ស្គាល់ឈ្មោះតាក់ ហៅសុគន្ធ ជាកម្លាំង -
ក្នុងខ្សែជាមួយគ្នា ដើម្បីទាក់ទងធ្វើការងារ ។ ពេលនោះ ឈ្មោះតាក់ ជាគណៈស្រុក
កោះធំ ប្រចាំឃុំពើខ្លាំ ដែលជាមូលដ្ឋានរបស់ សួនី ។
ឯឈ្មោះរេប ខ្ញុំបានណែនាំឱ្យស្គាល់ឈ្មោះយុនគ្រី ហៅខៀវសំអាត ជាគណៈស្រុកកោះធំ -
ប្រចាំឃុំកោះធំ ដែលជាមូលដ្ឋានរបស់ឈ្មោះរេប ។

ហើយនៅក្នុងចុងឆ្នាំ១៩៧៤នោះ ខ្ញុំបានការណែនាំពីតាជ័យ ឱ្យទៅជួបពិភាក្សា
ជាមួយ ហួតសេ ដើម្បីលើកទិសអនុវត្តចាប់ខ្លួនប្រជាជនជំលៀស ដែលស្នាក់នៅភូមិជ្រោយ
ឫស្សី ក្នុងឃុំព្រាលាទ ។ ជាគោលបំណង គឺដើម្បីឱ្យប្រជាជនភ័យខ្លាចបដិវត្ត ស្អប់អង្គការ -
ហើយរត់ចូលខ្មាំងវិញ ។
ពេលនោះ ហួតសេ និងខ្ញុំ ក៏បានលើកទិសចាប់ ដោយចោទប្រជាជនទាំងនោះថា ជា
គិញរបស់ពួកអាលន់ណុលដែលចូលមកបង្កប់នៅក្នុងមូលដ្ឋានបដិវត្ត ។
រួចហើយ ហួតសេ និងខ្ញុំ ក៏បានណែនាំកម្លាំងទៅអនុវត្តចាប់តាមផែនការ រួចចាប់បាន -
ជាង១០នាក់ ហើយហួតសេ នាំយកទៅសន្តិសុខស្រុកកៀនស្វាយទាំងអស់ ដើម្បីសួរចំលើយ
ធ្វើឃាតនិរទេ ។

នៅដើមឆ្នាំ១៩៧៥ ខ្ញុំបានជួបរាយការណ៍ឱ្យតាជ័យ អំពីកម្លាំងដែលខ្ញុំកសាងបាន -
បន្ថែមទៀត នៅក្នុងសន្តិសុខ ។ កម្លាំងទាំងនោះ គឺ:



១- ឈ្មោះ សុន
២- " រុន
៣- " ហ៊ិ
៤- ឈ្មោះ អ៊ុន
៥- " ហាក់

អ្នកទាំង៥នេះ ខ្ញុំបានប្រមូលយកមកក្តាប់នៅសន្តិសុខ ហើយអប់រំកសាងដើម្បីបញ្ចូលក្នុងខ្សែ
សេអ៊ីអារបស់ខ្ញុំ ។

ហើយជាចំណុចខ្សោយរបស់អ្នកទាំង៥នោះ គឺប្រហាក់ប្រហែលគ្នា កម្លាំងមុនៗដែរ គឺជាអ្នកធូរធា ចូលចិត្តខាងការសប្បាយស៊ីផឹក អំនួតច្រើន ហើយមានលក្ខណៈមុខមាត់ ដែលធ្វើឱយខ្ញុំអប់រំអូសទាញបញ្ចូលបានមកក្នុងខ្សែរសេអ៊ីអារបស់ខ្ញុំ នៅក្នុងឆ្នាំ១៩៧៥ ។
រួចហើយ ខ្ញុំក៏បានណែនាំការកិច្ចឱយអនុវត្តដូចកម្លាំងមុនដែរ ដោយអ្នកទាំងនោះ សុទ្ធតែ-ការងារនៅក្នុងក្រសួងសន្តិសុខដូចគ្នា ។

ហើយក្នុងដើមឆ្នាំ១៩៧៥នោះ ខ្ញុំបានជួបឈ្មោះខួយ នៅមន្ទីរតំបន់ កន្លែងតាជីយ ហើយឈ្មោះខួយនេះ ជាកម្លាំងក្នុងខ្សែរបស់ ទិត ។
ពេលនោះ ខួយ បានរាយការណ៍ប្រាប់ខ្ញុំ អំពីម៉ឺងទិត បានទាក់ទងខូចសីលធម៌ជាមួយនារីម្នាក់ឈ្មោះសុវណ្ណ ។ ខួយបញ្ជាក់ប្រាប់ខ្ញុំ អំពីនារីនេះ ជាបុគ្គលិកពេទ្យ ដែលធ្វើការជាប់ជិតស្និតជាមួយម៉ឺងទិត តាំងពីនៅក្នុងពេទ្យតំបន់២៥ ។

បន្ទាប់មក ក្នុងដើមឆ្នាំ១៩៧៥នោះដែរ បង "វ" បានទៅជួបខ្ញុំនៅសន្តិសុខ-តំបន់ កន្លែងខ្ញុំផ្ទាល់ ។ ពេលនោះ គាត់បានណែនាំខ្ញុំ ឱយឈប់មានការទាក់ទងជាមួយនិងនារីទៀត ហើយកុំឱយមាននារីចេញចូលកន្លែងខ្ញុំ ដើម្បីកុំឱយអង្គការ និងមហាជន-ចាប់អារម្មណ៍ ។
គាត់បញ្ជាក់ប្រាប់ខ្ញុំថា ចំពោះរឿងចាស់ដែលមានកន្លងហើយ គឺត្រូវបញ្ឈប់ ហើយឱយខិតខំជាថ្មីវិញចាប់តាំងពីពេលនោះទៅ ដើម្បីបានរួមសំរេចផែនការវាយរំលំបក្ស ។
បង "វ" ណែនាំមូលហេតុ ឱយខ្ញុំកាន់តែឃើញច្បាស់ គឺត្រូវថែរក្សាការពារកម្លាំង-ដែលមាន សំរាប់រួមសំរេចផែនការធំនៅថ្ងៃខាងមុខ នោះព្រោះបើខ្ញុំ មានការទាក់ទងក្នុងរឿងសីលធម៌អាវ៉ាសែនោះទៀត មុខជាត្រូវខូចខាតកម្លាំង ។

២៥.៣.៧៨ ម៉ឹង តេង

ហើយនៅក្នុងខែ ៥.១៩៧៥ ម៉ឺងទិត បានទៅជួបខ្ញុំ នៅមន្ទីរសន្តិសុខ ។
ពេលនោះ វាបានប្រាប់ខ្ញុំអំពីផ្ទាល់ខ្លួនរបស់វា ត្រូវចូលទៅធ្វើការនៅភ្នំពេញ គឺខាងផ្នែកពេទ្យរបស់កងពល១២ ។ រួចហើយ វាក៏បានបញ្ជាក់អំពីការទាក់ទង ជាប់ជិតស្និតជាមួយបងណាត និងម៉ុន ។
វាបានរាយការណ៍អំពីការណែនាំរបស់បងណាត ឱយវាទាក់ទងភ្ជាប់កម្លាំង ដែលមានទាំងអស់

រួចពង្រឹងឱ្យបានរឹងប៉ឹង សំខាន់ចំពោះកម្លាំងដែលត្រូវនៅភ្នំពេញជាមួយគ្នា ។
រួចហើយ បងណាត បានឱ្យវាខិតខំកសាងពង្រីកកម្លាំងឱ្យបានច្រើនថែមទៀត ដើម្បីជា-
កម្លាំងត្រៀម សំរាប់ផែនការដែលត្រូវវាយរំលុំបក្ស ។
រួចហើយ ម៉ឹងរ៉ែត ក៏បានជំរុញខ្ញុំថែមទៀត ឱ្យចុះក្តាប់ និងពង្រឹងកម្លាំងក្នុងខេត្តរបស់វា-
ដែលមានក្នុងតំបន់ ហើយដែលវាបានឧទ្ទេសនាមឱ្យខ្ញុំរួចហើយ កាលពីឆ្នាំ១៩៧៣ ក្នុងពេល
ដែលវាត្រូវចូលទៅធ្វើការនៅក្នុងភូមិភាគ ។

បន្ទាប់មក នៅក្នុងខែ៥.១៩៧៥នោះ ខ្ញុំក៏បានទៅជួបឈ្មោះចាក់ ជាគណៈ-
ពេទ្យតំបន់ ។ ពេលនោះខ្ញុំបានណែនាំឱ្យគាត់ធ្វើសកម្មភាពបង្កទំនាស់នៅក្នុងមន្ទីរពេទ្យ
រវាងអ្នកជំងឺ និងបុគ្គលិកពេទ្យ ។ រួចហើយ ខ្ញុំបានជំរុញឱ្យឈ្មោះចាក់ បំផុសរឿងសិលធម៌
អាវ៉ាសែ រវាងយុទ្ធជន និងនារីពេទ្យ ។

ហើយក្នុងខែ៥.១៩៧៥នោះ ខ្ញុំក៏បានខូចសិលធម៌ជាមួយនារីម្នាក់ទៀតឈ្មោះ-
តុប សាមឿន ហៅសឿន ។ នារីនោះ ជាស្រីមេម៉ាយ អាយុជាង២០ឆ្នាំ ហើយធ្វើ
ការនៅក្នុងសន្តិសុខតំបន់ដែរ ។ ហើយនារីសឿន ជាមនុស្សជិតស្និតជាមួយខ្ញុំតាំងពីនៅ
ភូមិស្រុកម្លេះ ដោយផ្ទះនារីសឿន និងផ្ទះខ្ញុំ នៅជិតគ្នា ។ បន្ទាប់មក ក៏កាន់ តែ
ស្និតស្នាលគ្នាខ្លាំងទៀតនៅក្នុងសន្តិសុខ ហើយខ្ញុំក៏បានទាក់ទងអូសទាញ រួចក៏ខូចសិលធម៌ជា
មួយគ្នា ។

បន្ទាប់មក នៅក្នុងខែ៦.១៩៧៥ ឈ្មោះយូរប៉ងគ្រី ហៅម៉ុន បានទៅជួបខ្ញុំ-
នៅសន្តិសុខ ។ ពេលនោះ ម៉ុន ទៅទាក់ទងយកមនុស្សទោសពីសន្តិសុខតំបន់ ហើយ ក៏-
បានប្រាប់ខ្ញុំ អំពីកម្លាំងមួយចំនួននៅក្នុងតំបន់ គឺគ្រូសុខ និងសុខប៊ិតចំរើន ត្រូវអង្គការចាប់
២៥.៧.៧៨ ហើយគាត់បញ្ជាក់ប្រាប់ខ្ញុំ អំពីការចាប់ គឺជាគោលការរបស់បងណាត ដើម្បីផ្តាច់កម្លាំង
ដែលបែកមុខ ហើយការពារដល់កម្លាំងទាំងអស់នៅក្នុងតំបន់២៥ ដែលមិនទាន់បែកមុខ ។
ម៉ុង តេង រួចហើយ ឈ្មោះម៉ុន បានណែនាំខ្ញុំ ឱ្យខំពិនិត្យចំទៀយក្នុងខេត្តផ្ទៃក្នុងថែមទៀត រួចធ្វើ
ការទាក់ទងផ្សាឱ្យដឹងមុន អំពីកម្លាំងដែលត្រូវចាប់ទៀត និងកម្លាំងដែលត្រូវទុកពង្រឹង
ឱ្យកាន់តែរឹងមាំតទៅមុខ ។

រួចហើយ ឈ្មោះមុំន បានណែនាំខ្ញុំឱ្យខំក្តាប់ និងពង្រឹងចំពោះកម្លាំងដែលគ្មានចំឡើយពាក់ពន្ធ ហើយឱ្យខិតខំកសាងពង្រីកកម្លាំងថ្មីថែមទៀត ដើម្បីត្រៀមកម្លាំងធំ សំរាប់ផែនការវាយបក្ស ថ្ងៃខាងមុខ ។

បន្ទាប់មក តាជ័យបានណែនាំខ្ញុំ ឱ្យអនុញ្ញាតិឱ្យឈ្មោះថុង ហៅចន្ទស៊ីថន ត្រឡប់ទៅផ្ទះជួបជុំគ្រួសារវិញ ។ ឈ្មោះនេះបានធ្វើសកម្មភាពគៃបន្លំទ្រព្យសម្បត្តិរបស់ប្រជាជនជំលៀស តាមផែនការរបស់ពួកគេ ។ រួចត្រូវបែកមុខ ដែលប្រជាជនស្គាល់ច្បាស់ ហើយតាជ័យក៏បានឱ្យយកចន្ទស៊ីថននោះ ទៅរក្សាទុកនៅសន្តិសុខ ដើម្បីការពារកម្លាំង ។ ហើយកម្លាំងនេះ ជាខ្សែចាត់តាំងរបស់ពួន តាំងពីសម័យវាយបារាំង តែមិនបែកមុខធំដូចដែលតាជ័យ នៅការពារបានតទៅទៀត ។

បន្ទាប់មកទៀត តាជ័យបានណែនាំជំរុញខ្ញុំឱ្យខិតខំប្រមូលពួកមានបណ្ដាស័ក្តិទាំងអស់ ដែលទើបចេញពីក្រុងភ្នំពេញ ហើយយកទៅសន្តិសុខ រួចធ្វើឃុំរៀងដើម្បីកំទេច ។ តាជ័យបានប្រាប់ខ្ញុំអំពីមូលហេតុដែលអនុវត្តនោះ គឺដើម្បីធ្វើឱ្យប្រជាជនមិនទុកចិត្តកក់ក្ដៅលើអង្គការ ភ័យខ្លាច ហើយបង្កបញ្ហាស្មុគស្មាញនៅក្នុងមូលដ្ឋាន ។ ជាគោលបំណង គឺយកកម្លាំងថ្មីនេះ ដើម្បីរួមវាយបក្សនៅក្នុងមូលដ្ឋាន ។

បន្ទាប់មក ខ្ញុំក៏អនុវត្តការណែនាំរបស់តាជ័យ ដោយបានប្រមូលចាប់ពួកអ្នកមានបណ្ដាស័ក្តិ យកទៅសន្តិសុខបានជាច្រើន ហើយបន្តរាល់ថ្ងៃ ។ រួចហើយ ខ្ញុំក៏បានរៀបចំសួរចំឡើយ ធ្វើឃុំរៀង ហើយយកទៅជូនតាជ័យ រួចគាត់ក៏បានសំរេចឱ្យយកទៅកំទេចទាំងអស់ ។

ហើយបន្ទាប់មកទៀត គ្រូជាងបានទៅជួបខ្ញុំនៅសន្តិសុខ ។ ពេលនោះគាត់ជាគណៈស្រុកស្លាង ។

២៥.៧.៧៨ គ្រូជាង ក៏បានពិភាក្សា និងណែនាំខ្ញុំក្នុងពេលនោះ ដូចតាជ័យដែរ គឺជំរុញឱ្យប្រមូលពួកមានបណ្ដាស័ក្តិយកទៅកំទេច ក្នុងផែនការពង្រីកទំនាស់ក្នុងប្រជាជន ដើម្បីឱ្យប្រជាជនស្អប់ខ្ពើមបដិវត្ត ក្ដៅក្រហាយចំពោះអង្គការ មិនជឿទុកចិត្តលើអង្គការ ហើយប្រឆាំងនិងអង្គការវិញ ។

ម៉ឹង តេង

រួចហើយ គ្រូជាង បានណែនាំខ្ញុំ ឱ្យពិនិត្យម៉ត់ចត់ក្នុងការធ្វើឃុំរៀងពួកមានបណ្ដាស័ក្តិ ។

ស្រូផ្រាង បញ្ជាក់ប្រាប់ខ្ញុំថា ក្នុងចំណោមពួកនេះ មានកម្លាំងរបស់គាត់ ដែលបានអប់រំកសាងបង្កប់នេក្នុងខ្មាំង តាំងពីមិនទាន់ផ្ទុះអាវុធម្ល៉េះ ។ គាត់ឱ្យខ្ញុំពិនិត្យមើលចត់នោះ គឺដើម្បីកុំឱ្យប៉ះខ្មែរបង្កប់របស់គាត់ នាំឱ្យខូចខាតកម្លាំង ។

បន្ទាប់មក ក្នុងឆ្នាំ១៩៧៥នោះ ខ្ញុំមិនចាំខែច្បាស់ បងណាត បាននាំគ្រូសារថ្មី ដែលអង្គការទើបរៀបចំហើយ ទៅលេងផ្ទះតាជ័យនៅភូមិដើមព្រីង ឃុំកោះខែល ក្នុងស្រុកស្អាង ។ ពេលនោះ ខ្ញុំក៏បានទៅផ្ទះតាជ័យដែរ ដើម្បីទាក់ទងធ្វើការងារ រួចក៏បានជួបបងណាត ។

ពេលនោះ បងណាតក៏បានពិភាក្សាជាមួយតាជ័យ និងខ្ញុំ អំពីកម្លាំងមួយចំនួននៅតំបន់២៥ - ដែលបែកមុខច្បាស់ជាខ្មែរយួនខ្លះ និងជាខ្មែរសេរីការខ្លះ ។ កម្លាំងប្រភេទនេះ គឺបងណាត បានលើកគោលការថាត្រូវចាប់ខ្លួន ដើម្បីការពារកម្លាំងនៅក្នុងតំបន់ ដែលមិន- ទាន់បែកមុខ ។

តាជ័យ យល់ស្របតាមគោលការនេះ ហើយក៏បានណែនាំខ្ញុំឱ្យខំអនុវត្តឱ្យបានសំរេច តាម- គោលការនេះ ។

បន្ទាប់មក បងដា ត្រូវទទួលជាលេខាតំបន់២៥ជំនួសតាជ័យ ។ បងណាត ក៏បានឱ្យឈ្មោះម៉ុន ទាក់ទងជាមួយបងដា ដើម្បីអនុវត្តគោលការនេះ ។ បងដា ក៏បានឯក- ភាពលើគោលការ ហើយណែនាំឱ្យឈ្មោះម៉ុន រៀបចំទិសការងារសំរាប់អនុវត្តចាប់ ។ ពេលនោះ ឈ្មោះម៉ុន ក៏បានចាប់ជាបន្ត នូវពួកក្បត់មួយចំនួន គឺ:

១- ហួត សេ អតីតៈគណៈតំបន់២៥

២- តាអួន អតីតៈប្រធានមន្ទីរសេដ្ឋកិច្ចតំបន់

២៥.៧.៧៨

៣- តាមោក អតីតៈប្រធានមន្ទីរពេទ្យតំបន់

ម៉ឹង តេង

៤- ឡាប៊ីន អតីតៈគណៈមន្ទីរពេទ្យតំបន់

៥- ផន អតីតៈគណៈវរៈកងទ័ពតំបន់

៦- ខឿន អតីតៈគណៈវរៈ១១៩

៧- កាត ហៅចន្ទសារ៉េន អតីតៈគណៈវរៈ កងទ័ពតំបន់ -

កម្លាំងទាំងអស់នេះ សុទ្ធតែនៅក្នុងខ្មែរសេរីការរបស់គ្រួសុខ ដែលមហាជនស្គាល់មុខថាជាអ្នកក្បត់បក្សច្បាស់ ។

បន្ទាប់មក ក្នុងខែ៩.១៩៧៥ ខ្ញុំបានទទួលការជំរុញពីបងជាថែមទៀត ឱ្យខ្ញុំអនុវត្តចាប់ អ្នកដែលនៅក្នុងខ្សែយួន និងនៅក្នុងខ្សែក្បត់បក្សមួយចំនួនទៀត ដែលបែកមុខច្បាស់ ៗ ហើយបងជា ឱ្យខ្ញុំចាប់អ្នកទាំងនេះ ឱ្យបានបន្ទាន់ ដើម្បីការ-ពារកម្លាំងដែលមិនទាន់បែក បានល្អ ៗ

រួចហើយ ខ្ញុំក៏អនុវត្តចាប់ បានជាបន្តបន្ទាប់ គឺ:

១- តាក់ ហៅសុគន្ធ អតីតៈប្រធានស្រុកកោះធំ
២- ឈុនគ្រី ហៅខៀវសំអាត ■
៣- ឡឹក ហៅយ៉ែមសឿង អតីតៈប្រធានស្រុកស្អាង
៤- ង៉ែ ហៅសុង៉ែមុនី អតីតៈប្រធានស្រុកលើកដែក
៥- អ៊ុង យេន អតីតៈគណៈស្រុកកៀនស្វាយ
៦- ផា អតីតៈគណៈមន្ទីរពេទ្យតំបន់
៧- ធីម អតីតៈគណៈមន្ទីរផ្គត់ផ្គង់តំបន់
៨- ឌឹម អតីតៈ ក្រុមដឹកជញ្ជូនតំបន់
៩- ទុំ អតីតៈ ក្រុមមន្ទីរយោធាតំបន់
១០- សុវណ្ណទៀ ■
១១- ហម មាន អតីតៈគណៈអនុសេនាធំ កងទ័ពតំបន់
១២- ប្រាច ■

រួចហើយ ខ្ញុំក៏បានរៀបចំ ធ្វើសំណុំរឿង យកចំលើយពីអ្នកទាំងអស់នេះបានមួយចំនួន ហើយក៏បានបញ្ជូនមកអង្គការសន្តិបាលក្រុង តាមការណែនាំរបស់បងជា ហើយដែលឈ្មោះម៉ុន-បានទៅទទួលយកផ្ទាល់ ដែលការបញ្ជូននោះ បានធ្វើជាបន្តបន្ទាប់គ្នា ៗ តែមានខ្លះឈឺ ហើយស្លាប់នៅសន្តិសុខតំបន់ ហើយខ្លះទៀត មិនទាន់បានបញ្ជូនមកអង្គការសន្តិបាលក្រុង ៗ

២៥.៧.៧៨
ម៉ឹង តេង

ក្នុងឆ្នាំ ១៩៧៥នោះ នៅជិតចុងឆ្នាំ គ្រូជ្រាងបានទៅជួបខ្ញុំនៅមន្ទីរ-តំបន២៥ ៗ ពេលនោះ គាត់ទៅទាក់ទងស្នើយកឈ្មោះស្រេង ដែលជាកម្លាំងក្នុង-ខ្សែរបស់គាត់ ឱ្យទៅនៅធ្វើការក្នុងរោងចក្រនៅ នៅជីផ្ទ កៀនស្វាយវិញ ៗ

ឈ្មោះស្រេង ជាសមាសភាពស្រុកស្នាញ ដែលបែករឿងសីលធម៌កាលពីឆ្នាំ១៩៧៤ ហើយដែលគ្រូហ៊ាង បានដកឱ្យទៅនៅក្នុងកងបង្កបង្កើនផលរបស់តំបន់វិញ ដើម្បីការពារកម្លាំង ។ ហើយមូលហេតុ ដែលគ្រូជាងស្នើយកឈ្មោះស្រេងពេលនោះ ព្រោះគាត់ឃើញសភាព-ការណ៍នៅក្នុងតំបន់តានតឹង ខ្លាចប៉ះពាល់ខូចខាតដល់កម្លាំងក្នុងខ្សែរបស់គាត់ ។ បន្ទាប់មក ខ្ញុំក៏បានប្រគល់ឈ្មោះស្រេងនោះ ឱ្យទៅគ្រូជាង ហើយគាត់ក៏បានយកទៅធ្វើការជាយមួយគាត់ នៅរោងចក្ររដ្ឋ នៅដីឥដ្ឋ រហូតមក ។

បន្ទាប់មក បងជា បានណែនាំឱ្យខ្ញុំ ចាប់ស្រីម្នាក់ឈ្មោះពៅ យកទៅកំទេច។ ស្រីនេះ ផ្ទះនៅក្នុងឃុំសំពៅពូន ស្រុកកោះធំ ។ ហើយជាស្រីមេម៉ាយ អាយុជាង៣០ឆ្នាំ មានកូនប្រុសមួយ ។ ហើយមូលហេតុចាប់ ដោយឈ្មោះពៅនេះ ដើរនិយាយឱ្យបែកការពីរឿងរ៉ាវខូចសីលធម៌ជាមួយគ្រូសុខ និងប៉ាប៉ុន ។ ហើយដែលបងជា ឱ្យចាប់វាយកទៅកំទេច គឺដើម្បីការពារ-កិត្តិយសប៉ាប៉ុន ដែលនៅកំពង់បំពេញភារកិច្ចសព្វថ្ងៃ ។ រួចហើយ ខ្ញុំក៏បានអនុវត្តសេចក្តីសំរេចរបស់បងជា ដោយបានចាប់ស្រីនោះ ទៅសន្តិសុខ រួចធ្វើសំណុំរឿង ហើយស្នើបងជាសំរេច រួចកំទេច ។

ហើយនៅចុងឆ្នាំ១៩៧៥នោះ បងជា បានឱ្យខ្ញុំប្រមូលកម្លាំងដែលមាននៅសល់ ហើយដែលមិនទាន់បែកមុខ ឱ្យយកទៅគ្រប់គ្រងអប់រំផ្ទាល់នៅសន្តិសុខ ។ គោលបំណង គឺដើម្បីការពារកម្លាំងទាំងនោះសំរាប់ចូលរួមក្នុងផែនការវាយបក្ស នៅថ្ងៃខាងមុខ ។ កម្លាំងទាំងអស់នោះ គឺ:

| | | | |
|---|---|---|---|
| ១- ប៉ា ប៉ុន | អតីត:គណៈស្រុកកោះធំ | ៧- តាខែម | គណៈមន្ទីរសន្តិសុខតំបន់ |
| ២- ប | អតីត:គណៈឃុំកោះធំ | ៨- បុន | អតីត:ក្រុមឡូតិ៍នេ-សាទ |
| ៣- តាអួន | 〃 គណៈស្រុកកៀន-ស្វាយ | ៩- ផល | 〃 |
| ៤- ផៃហម | 〃 〃 | ១០- យូក | អតីត:គណៈស្រុកលើក-ដែក |
| ៥- គ្រាក់ | អតីត:ក្រុមឡូតិ៍នេសាទ | ១១- នេង | 〃 គណៈឃុំព្រែកថ្មី |
| ៦- ចំរើន | គណៈកសិដ្ឋានសន្តិសុខតំបន់ | | |

២៥.៧.៧៨

ម៉ឹង តេង

កម្លាំងទាំង១១នាក់នេះ ខ្ញុំបានយកទៅដាក់អប់រំ នៅក្នុងកសិដ្ឋានរបស់សន្តិសុខ ហើយបានចាត់តាំង និងណែនាំតាខែម ឱ្យក្ដាប់ និងគ្រប់គ្រងផ្ទាល់ ។

បន្ទាប់មក បងជា បានឱ្យខ្ញុំរៀបចំប្រមូលយុវជននៅជុំវិញមន្ទីរតំបន់ ឱ្យបានមួយ-កងអនុសេនាធំ ដើម្បីយកទៅពង្រីកកងទ័ពតំបន់ ។
បងជា បានប្រាប់ខ្ញុំអំពីមូលហេតុនៃការពង្រីកកងទ័ព គឺជាការរៀបចំពង្រីកបណ្ដើរៗ ដើម្បីត្រៀមសំរាប់ផែនការវាយបក្ស ថ្ងៃខាងមុខ ។ រួចហើយ ខ្ញុំក៏ប្រមូលយុវជនបាន៨០នាក់ - ហើយខ្ញុំយកទៅអប់រំណែនាំថែមមួយចំនួន រួចក៏បញ្ជូនឱ្យទៅឈ្មោះសាឯម គណៈវរៈកងទ័ព-តំបន់ ដើម្បីរៀបចំចាត់តាំងបញ្ចូលទៅក្នុងកងទ័ព ។

រួចហើយ បងជា បានឱ្យខ្ញុំរៀបចំកម្លាំងក្នុងខ្សែរបស់ខ្ញុំ ដែលកសាងបាននៅសន្តិសុខ ដើម្បីចាត់តាំងបញ្ចូលបង្កប់ទៅក្នុងកងទ័ពតំបន់ សំរាប់ត្រៀមកម្លាំងយូរអង្វែង ដើម្បីផែន-ការវាយបក្សនៅថ្ងៃខាងមុខ ។
បន្ទាប់មក ខ្ញុំក៏បានរៀបចំតាមការណែនាំរបស់គាត់ បានចំនួន ៧នាក់ គឺ:

១- ឈ្មោះ ម៉ុត
២- " ហន
៣- " ង៉ែត
៤- " ឈឺន
៥- ឈ្មោះ រិន
៦- " ថេង
៧- " ម៉ឺន

រៀបចំហើយ ខ្ញុំក៏បានណែនាំភារកិច្ចមួយចំនួន ឱ្យអ្នកទាំង៧នោះ អនុវត្តក្នុងកងទ័ព ដើម្បីត្រៀមលក្ខណៈសំរាប់ផែនការវាយបក្ស :

១- ឱ្យខិតខំក្ដាប់ និងកសាងកម្លាំងនៅក្នុងកងទ័ព
២- ឱ្យបំផុសញាតុភាពសេរីនៅក្នុងកងទ័ព និងស៊ីផឹកអាវ៉ាសែ
៣- ឱ្យបំផ្លិចបំផ្លាញអាវុធ និងគ្រាប់រំសេវ

២៥.៧.៧៨
ម៉ឹង តេង

រួចហើយ ខ្ញុំបានណែនាំអ្នកទាំង៧នោះ ឱ្យស្គាល់ឈ្មោះសាឯម ,, ឡេញ និង លន់ ដែលជាគណៈវរៈកងទ័ពតំបន់ ហើយនៅក្នុងខ្សែក្បត់បក្សជាមួយគ្នា ដើម្បីបានទាក់ទងធ្វើការងារប្រឆាំងបក្សនៅក្នុងកងទ័ព ។ រួចហើយ ខ្ញុំក៏ប្រគល់អ្នកទាំង៧នេះទៅបងជា ហើយក៏យកទៅចាត់តាំងក្នុងកងទ័ព នាទីជាគណៈអនុសេនាធំទាំងអស់ ។

នៅខែ ១២.១៩៧៥ បងជា បានណែនាំខ្ញុំឱ្យស្គាល់កម្លាំងនៅក្នុងតំបន់ទាំងអស់ ដែលសុទ្ធតែនៅក្នុងខ្សែក្បៀតបក្សជាមួយគ្នា ដើម្បីឱ្យខ្ញុំងាយទាក់ទងធ្វើការងារក្នុងសកម្មភាពប្រឆាំបក្ស ។ ការណែនាំនេះ គ្រាន់ជាការបញ្ជាក់ថែម ព្រោះខ្ញុំក្តាប់បានច្រើនហើយ កម្លាំងទាំងអស់នោះ គឺ:

| | | | | |
|---|---|---|---|---|
| ១- | បងស៊ិត | លេខាស្រុកកោះធំ | ៧- សាងម | គណៈវរៈកងទ័ពតំបន់ |
| ២- | បងគ្រុយ | លេខាស្រុកកណ្តាលស្ទឹង | ៨- ឡៀញ | " |
| ៣- | ម្រ៉ា | សមាជិកមន្ទីរតំបន់ | ៩- លន់ | " |
| ៤- | សារ៉ន | គណៈកសិដ្ឋានតំបន់ | ១០- ហុង | ប្រធានសេដ្ឋកិច្ចតំបន់ |
| ៥- | ពេង | គណៈឡូតិនេសាទតំបន់ | ១១- ជាគឹមអេង ហៅជា | ប្រធានមន្ទីរស្រុកកណ្តាលស្ទឹង |
| ៦- | សោម | " | | |

កម្លាំងទាំងអស់នេះ គឺសល់ពីការបោសសំអាត ដែលជាកម្លាំងមិនទាន់បែកមុខ ដែលត្រូវបន្តអនុវត្តភារកិច្ចតទៅទៀត ដើម្បីត្រៀមលក្ខណៈសំរាប់ផែនការវាយបក្ស ។

ខែ ១.១៩៧៦ ខ្ញុំបានជួបបងណាត នៅមន្ទីរតំបន់ កន្លែងបងជា នៅតាខ្មៅ ។ ពេលនោះ ជួបគ្នានៅពេលយប់ ដែលបងណាតទៅដល់កន្លែងបងជា ម៉ោង៧យប់ ។ រួចហើយ បងជា ក៏បានពិភាក្សា ជាមួយបងណាត និង ខ្ញុំ ។ នៅពេលយប់នោះ មានតែ បងជា បងណាត និងខ្ញុំ ។

ពេលនោះ បងណាត បានពិភាក្សា និងណែនាំបងជា និងខ្ញុំឱ្យរៀបចំលក្ខណៈឱ្យបានគ្រប់គ្រាន់ ត្រៀមឱ្យស្រួលសំរាប់ផែនការវាយបក្ស គឺ:

១- ឱ្យត្រៀមកម្លាំងកងទ័ព ដោយខំក្តាប់ និងពង្រឹងកម្លាំងដែលមាននៅក្នុងតំបន់ ហើយពង្រីកថែមទៀតឱ្យបានច្រើន

២- ឱ្យខំក្តាប់ និងពង្រឹងកម្លាំងប្រជាជន ដោយខំបំផុសទំនាស់ក្នុងសហករណ៍

៣- ឱ្យត្រៀមខាងសេដ្ឋកិច្ច អង្ករ អំបិល ឱ្យបានគ្រប់គ្រាន់

៤- ឱ្យត្រៀម សំភារៈពេទ្យ និងថ្នាំពេទ្យឱ្យបានច្រើន សំរាប់ប្រើប្រាស់បានគ្រប់គ្រាន់នៅថ្ងៃដែលផែនការកំណត់ត្រូវផ្ទុះ ។

២៥.៧.៧៨

ម៉ឹង តេង

បន្ទាប់មក នៅក្នុងខែ១.១៩៧៦នោះ បងជាក៏បានណែនាំខ្ញុំឱ្យចុះទៅជួប - វៀតណាម ដើម្បីទាក់ទងស្នើជំនួយ ជាអំបិល និងថ្នាំពេទ្យ ។ ពេលនោះ ខ្ញុំមាននាទីជាគណៈទាក់ទងតំបន់២៥ ជាមួយនិងវៀតណាម ខែត្រទឡុងចូវទៀង ។
រួចហើយ ខ្ញុំក៏បានទៅជាមួយឈ្មោះហុង ប្រធានសេដ្ឋកិច្ចតំបន់ ដើម្បីទៅជួបអាទ៊ីបម៉ាប់ - នៅឯមន្ទីរគណៈទាក់ទង ជិតព្រំដែនកម្ពុជា-វៀតណាម ។
ពេលនោះ ខ្ញុំក៏បានជួបអាទ៊ីបម៉ាប់ រួចក៏បានពិភាក្សាស្នើឱ្យខាងវៀតណាមជួយឧបត្ថម្ភ នូវអំបិល និងថ្នាំពេទ្យ តាមទិសដែលបងជា ណែនាំ តែមិនបានកំណត់ចំនួន ។
អាទ៊ីបម៉ាប់ ក៏បានទទួលការទាក់ទងស្នើជំនួយនេះ ដើម្បីយកទៅរាយការណ៍ស្នើដល់គណៈ - ខែត្រ ដើម្បីសំរេច ។ ហើយ អាទ៊ីបម៉ាប់ បញ្ជាក់ប្រាប់ខ្ញុំ ថានឹងផ្តល់ដំណឹងឱ្យខ្ញុំ - ក្រោយពេលបានសេចក្តីសំរេចពីគណៈខែត្ររួចហើយ ។

ហើយនៅក្នុងខែ១.១៩៧៦នោះដែរ បងជាក៏បានណែនាំខ្ញុំឱ្យបន្ថែមកម្លាំងដល់ទៀលលិញ ដែលជាអនុលេខាស្រុកលើកដែក ។ មូលហេតុ ដោយស្រុកនេះជាមូលដ្ឋានថ្មី - ដែលតាលិញក្តាប់មិនទាន់បាន ហើយក៏ខ្វះកម្លាំងសំរាប់ រួមជំរុញសកម្មភាពប្រឆាំងបក្ស - បានខ្លាំងផង ។
រួចហើយ ខ្ញុំក៏បានរៀបចំ កម្លាំង៣នាក់ គឺ:

១-ឈ្មោះស្រាយ ២-ឈ្មោះ ឌឿន ៣-ឈ្មោះ ហ៊ិន

ហើយខ្ញុំក៏បានឧទ្ទេសនាមជូនទៅអង្គការស្រុកលើកដែក ដើម្បីរៀបចំចាត់តាំងប្រគល់ - ភារកិច្ចនៅក្នុងមូលដ្ឋាន ហើយពេលនោះ អង្គការស្រុកបានចាត់តាំងកម្លាំងទាំងនោះ - ឱ្យទទួលជាគណៈឃុំ ។ តាលិញ ក៏បានកម្លាំងទាំង៣នោះ រួមក្តាប់កម្លាំងប្រជាជននៅក្នុងមូលដ្ឋាន ដើម្បីជំរុញចលនាប្រឆាំងបក្សកាន់តែបានខ្លាំង ។ ហើយកម្លាំងទាំង៣នោះ ខ្ញុំក៏បានឧទ្ទេសនាមឱ្យតាលិញបន្ថែមទៀត ដើម្បីតាលិញកាន់តែក្តាប់បានច្បាស់ ងាយដឹកនាំធ្វើសកម្មភាពក្នុងមូលដ្ឋាន ។

២៥.៧.៧៨
ម៉ុង តេង

បន្ទាប់មក បងជា បានឱ្យខ្ញុំរំសាយកសិដ្ឋានរបស់តំបន់មួយ នៅក្នុងស្រុកលើកដែកទៀត ដើម្បីឱ្យខ្ញុំយកកម្លាំងក្នុងកសិដ្ឋាននេះ បន្ថែមឱ្យតាលិញ ។

កម្លាំងក្នុងកសិដ្ឋាននេះ មានជិត២០០នាក់ ខ្ញុំចាំមិនច្បាស់ ដែលសុទ្ធជាសមាសភាពសេរី ដែលតាលិញផ្ដាប់បានក្ដាប់រួចហើយ កាលគាត់ជាប្រធានមន្ទីរ២៥ ។ បងជា ឱ្យតាលិញ យកកម្លាំងនេះទៅដាក់ក្នុងមូលដ្ឋានបញ្ចូលជាមួយប្រជាជន ដើម្បីអូសទាញកម្លាំងប្រ-ជាជន ។ ហើយប្រជាជនក្នុងស្រុកលើកដែក ភាគច្រើនជាប្រជាជនថ្មី ដែលងាយ-អូសទាញ ។

បន្ទាប់មក ខ្ញុំក៏បានទៅជួបអង្គការស្រុកលើកដែក រួចក៏បានប្រគល់ទាំងកសិដ្ឋាន ទាំង-កម្លាំងមនុស្សទាំងអស់ដែលធ្វើការនៅក្នុងកសិដ្ឋាននេះ តាមការណែនាំរបស់បងជា ។ រួចហើយ ខ្ញុំក៏បានឧទ្ទេសនាមសម្ងាត់ ឱ្យតាលិញក្ដាប់បានថែមទៀត អំពីកម្លាំងក្នុងកសិដ្ឋាន នេះ ដើម្បីតាលិញយកទៅពង្រាយឱ្យនៅក្នុងមូលដ្ឋាន ។

ហើយនៅក្នុងខែ១១.១៩៧៦នោះ ពេលនោះបងជាហៅខ្ញុំទៅធ្វើការនៅ មន្ទីរតំបន់ នៅតាខ្មៅ ខ្ញុំក៏បានជួបបងណាតទៀត ។ ពេលនោះ ជួបគ្នានៅពេល-ថ្ងៃរសៀល ដែលមានបងណាត បងជា ហើយនិងខ្ញុំ ។

ពេលនោះ បងណាត បានណែនាំបងជា និងខ្ញុំ អំពីភារកិច្ចសំខាន់ទៀត ដែលត្រូវយកចិត្ត ទុកដាក់ គឺ:

១- ឱ្យខិតខំប្រមូលក្ដាប់យុវជនទាំងអស់ដែលមាននៅក្នុងតំបន់ ហើយអប់រំ-កសាង ដើម្បីត្រៀមបញ្ចូលជាកងទ័ពឱ្យបានច្រើន ក្នុងពេលដែលផែនការវាយបក្រ ដល់ពេលកំណត់ ។

២- ឱ្យរៀបចំប្រមូលអាវុធ ដែលមានប្រើប្រាស់នៅក្នុងតំបន់ លើកលែងតែ-ខាងកងទ័ព ដើម្បីយកទៅលាក់ត្រៀមទុកឱ្យហើយស្រេច ។

២៥.៧.៧៨

រួចហើយ ឱ្យធ្វើការទាក់ទងជាមួយវៀតណាម ដើម្បីរកអាវុធ គ្រាប់រំសេវថែម ។

ម៉ឹង តេង

៣- ឱ្យខំបំផុសទំនាស់នៅក្នុងសហករណ៍ ធ្វើឱ្យប្រជាជនប្រឆាំងជាមួយអង្គការ-គ្រប់ពេល ដើម្បីត្រៀមកម្លាំងនេះ សំរាប់រួមវាយបក្រនៅពេលផែនការត្រូវផ្ទុះ ។ រួចហើយ បងណាតបានបញ្ជាក់ថែមអំពីការងារទាំងអស់នេះ ត្រូវអនុវត្តបន្ទាន់ ហើយម៉ត់-ចត់ ដើម្បីធ្វាស់ការជាស្រេចលើកិច្ចដំណើរការរបស់ផែនការ ។

បន្ទាប់មក នៅក្នុងខែ១.១៩៧៦នោះ បងផា ក៏បានជំរុញខ្ញុំឱ្យខិតខំអនុវត្តភារកិច្ចទាំងអស់ ។ ហើយសំខាន់ គឺឱ្យខ្ញុំចុះទៅជួបវៀតណាម ដើម្បីទាក់ទងស្នើជំនួយជាអាវុធ ដើម្បីយកមកទុកត្រៀមឱ្យបានច្រើន ហើយឱ្យស្នើទាំងអាវុធធុនធ្ងន់ខ្លះផង ។ រួចហើយ ខ្ញុំក៏បានទៅជួបអាច្បាថាវ នៅទីស្នាក់ការរបស់គណៈទាក់ទងវៀតណាម នៅទ្លងបិន ។

ពេលនោះ ខ្ញុំបានស្នើអាច្បាថាវ ឱ្យជួយផ្តល់អាវុធធុនអាកាចំនួន២០០ដើម អាវុធធុនធ្ងន់កាណុង៦០ម.ម.ចំនួន៤ដើម និងធុនកាណុង៨០ម.ម.ចំនួន២ដើម ។

រួចហើយ អាច្បាថាវ ក៏បានទទួលសេចក្តីស្នើដែលខ្ញុំបានលើកឡើងនេះ ដើម្បីយកទៅរាយការណ៍ និងស្នើដល់គណៈខែត្រទ្លងចូវទៀង ដើម្បីសំរេច ។ ហើយអាច្បាថាវបញ្ជាក់ថា នឹងឱ្យដំណឹងមកខ្ញុំវិញ ក្រោយពីបានសេចក្តីសំរេចពីគណៈខែត្ររួចហើយ ។

បន្ទាប់មក ក្នុងខែ២.១៩៧៦ ខ្ញុំបានណែនាំដល់គ្រប់អង្គភាពនៅជុំវិញមន្ទីរតំបន់ ឱ្យប្រមូលអាវុធទាំងអស់ ដែលប្រើប្រាស់នៅតាមអង្គភាព ។ ហើយឱ្យទុកប្រើតែក្នុងមួយអង្គភាព ២ ឬ ៣ ដើមប៉ុណ្ណោះ លើកលែងតែខាងសន្តិសុខ ឱ្យទុកប្រើចំនួន២០ដើម។

បន្ទាប់មក ខ្ញុំក៏ប្រមូលបានជាង៥០ដើម ដែលភាគច្រើនប្រមូលបានមកពីខាងទ្លូតិនេសាទដែលកន្លងមក សុខប៊ុតចំរើនគ្រប់គ្រងផ្ទាល់ ហើយដែលភាគច្រើនជាអាវុធធុនអាកា ។

រួចហើយ ខ្ញុំក៏បានឱ្យនាំអាវុធនោះ ទៅប្រគល់ឱ្យឈ្មោះម្រ៉ា រៀបចំជូតលាង ហើយលាក់ទុកឱ្យបានស្អាតល្អ ។ ខ្ញុំបានឱ្យម្រ៉ាទុកជាសម្ងាត់ នៅឃ្លាំងជិតមន្ទីរ២៥ ។

នៅក្នុងខែ២.១៩៧៦នោះ ខ្ញុំបានជួបបង "វ" នៅភ្នំពេញ ។ ពេលនោះ

២៥.៧.៧៨ ខ្ញុំមានភារៈជូនដំណើរគណៈប្រតិភូពាណិជ្ជកម្មវៀតណាម មកភ្នំពេញ ។ ហើយខ្ញុំ ក៏ស្នាក់

នៅពាណិជ្ជកម្មរដ្ឋ កន្លែងបង "វ" មួយយប់ ។

ម៉ុង តេង ពេលនោះ បង "វ" ណែនាំខ្ញុំ ឱ្យខិតខំរក្សាការសម្ងាត់ថែមទៀត ទាំងការទាក់ទងទាំងការនិយាយស្តី ។ ហើយបង "វ" បានបញ្ជាក់ខ្ញុំច្បាស់ទៀតកុំឱ្យមានទាក់ទងចេញចូលជួបតាជ័យឱ្យសោះ ព្រោះតាជ័យជាកម្លាំងដែលបែកមុខច្បាស់ ។

រួចបង "ន" បានបញ្ជាក់ប្រាប់ខ្ញុំថា តាជ័យ កំពង់ត្រូវអង្គការ តាមដានពិនិត្យសកម្មភាព ទាក់ទង ។ គាត់ប្រាប់ខ្ញុំ មិនឱ្យទាក់ទងជាមួយតាជ័យ គឺដើម្បីការពារកម្លាំង ។ គាត់បញ្ជាក់ទៀតថា បើខ្ញុំនៅតែមានការទាក់ទងជាមួយតាជ័យ នោះច្បាស់-ជាត្រូវបែកមុខដែរ ដែលនាំឱ្យប៉ះពាល់ដល់ការប្រមូលកម្លាំងសំរាប់ផែនការវាយបក្ស នៅថ្ងៃខាងមុខ ។ តែបើចាំបាច់ត្រូវជួប បង "ន" ណែនាំខ្ញុំឱ្យប្រុងប្រយ័ត្នបំផុត ។

បន្ទាប់មក នៅក្នុងខែ២.១៩៧៦ បងជា បានឱ្យខ្ញុំខំរៀបចំចាត់តាំងកម្លាំងក្នុង ខ្មែររបស់ខ្ញុំ ចូលទៅក្តាប់កម្លាំងមហាជននៅក្នុងផ្នែកឡូតិ៍នេសាទ ។ មូលហេតុ ដោយ កម្លាំងដឹកនាំនៅផ្នែកឡូតិ៍ពីមុនមកត្រូវបែកមុខ ។ នៅសល់ ឈ្មោះហេង និងសោម - តែ២នាក់ ដែលក្តាប់កម្លាំង និងក្តាប់ការងារ មិនបានល្អ ។ ហើយអ្នកទាំង២នេះ មិន សូវមានឥទ្ធិពលដឹកនាំ ដោយមហាជនស្គាល់ជាខ្មែររបស់សុខប៊ុតចំរើនច្បាស់ ។
បន្ទាប់មក ខ្ញុំក៏បានរៀបចំចាត់តាំងឈ្មោះ ជាម ឈ្មោះស្រេង ឈ្មោះឯន និង ម៉េង ឱ្យចូលទៅក្តាប់កម្លាំងទាំងអស់នៅក្នុងផ្នែកឡូតិ៍ ដើម្បីអប់រំកសាងយកជាកម្លាំង សំរាប់ រួមសំរេចផែនការវាយបក្ស ។ ហើយកម្លាំងទាំងអស់នេះ សុទ្ធតែធ្លាប់កាន់អាវុធជាកង ការពារឡូតិ៍នេសាទកាលពីក្នុងសង្គ្រាម ។

រួច នៅក្នុងខែ២.១៩៧៦ដែរ ខ្ញុំបានប្រមូលកម្លាំងយុវជនទាំងអស់នៅជុំវិញ-មន្ទីរតំបន់ យកទៅដាក់មូលនៅក្នុងកសិដ្ឋាន២របស់តំបន់ គឺកសិដ្ឋានមួយនៅក្នុងឃុំសំពៅពូន និងមួយទៀត និងមួយទៀតនៅក្តុលក្រញ៉ាញ់ក្នុងឃុំត្រើយស្លា ដែលជាកសិដ្ឋានរបស់សន្តិសុខ។ ពេលនោះ ខ្ញុំដាក់កម្លាំងយុវជនជិត២០០នាក់នៅកសិដ្ឋានសំពៅពូន ដោយចាត់តាំង - ឈ្មោះសារ៉ន ឱ្យនៅគ្រប់គ្រង និងអប់រំផ្ទាល់ ។ ហើយនៅខាងក្តុលក្រញ៉ាញ់ ដាក់ កម្លាំង១២០នាក់ ដោយឱ្យតាខែម គ្រប់គ្រង និងអប់រំ ។
កម្លាំងទាំងអស់នេះ គឺបងជា ណែនាំឱ្យប្រមូល ដើម្បីកសាងត្រៀមសំរាប់ពង្រីកកងទ័ព នៅថ្ងៃខាងមុខ ក្នុងពេលដែលផែនការវាយបក្ស ដល់កំណត់ត្រូវផ្ទុះ ។
ហើយកម្លាំងក្នុងកសិដ្ឋានទាំង២នេះ សុទ្ធតែបានបំពាក់ធាតុសេរី ភ្លើតភ្លើន ដែលប្រឆាំង និងមាគ៌ារបស់បក្ស ។

២៦.៧.៧៨
ម៉ុង តេង

នៅក្នុងខែ ២.១៩៧៦នោះ បងស៊ិត ដែលជាលេខាស្រុកកោះធំ ហើយនិងខ្ញុំ បានទៅផ្ទះតាជ័យ នៅភ្នំពេញអស់មួយយប់ ។ ពេលនោះ បងស៊ិត និងខ្ញុំ បានចូលទៅជួបតាជ័យ នៅកសិដ្ឋានរដ្ឋ នៅអង្គរជ័យក្នុងស្រុកកៀនស្វាយ លុះពេលព្រលប់ ទើបជិះឡានជាមួយតាជ័យទៅផ្ទះនៅភ្នំពេញ ។

ពេលយប់នោះ គាត់បានណែនាំបងស៊ិត និងខ្ញុំ ឱ្យខិតខំថែរក្សាសាមគ្គីភាពរវាងកម្លាំងទាំងអស់ ដែលមាននៅសល់ក្នុងតំបន់ ហើយជួបពង្រឹងគ្នាឱ្យជាប់ ។ រួចហើយ គាត់ណែនាំឱ្យខំពង្រីកកម្លាំងថ្មីថែមទៀត ទាំងកម្លាំងប្រជាជន ទាំងយុវជន-នារី ដើម្បីឱ្យបានកម្លាំងធំ ។

រួចនៅពេលយប់នោះ តាជ័យពង្រឹងជំហរបងស៊ិត និងខ្ញុំ ឱ្យប្រយុទ្ធសំរេចផែនការឱ្យបាន ដោយមិនត្រូវទុកឱ្យបក្សកុម្មុយនិស្តកម្ពុជា ដឹកនាំប្រជាជនតាមផ្លូវសមូហភាពនោះដាច់ខាត ។

នៅខែ៤.១៩៧៦ ខ្ញុំត្រូវអង្គការ ដកនាទីចេញពីមន្ទីរតំបន់ និងពីសន្តិសុខ ។ មូលហេតុ ដោយរឿងអាវ៉ាសែរបស់ខ្ញុំ ដែលបានទាក់ទងខូចសិលធម៌ជាមួយនារីសៀន កាលពីឆ្នាំ១៩៧៥នោះ បែកសុះសាយនៅក្នុងសន្តិសុខ ។

អង្គការក៏បានដកខ្ញុំចេញ ហើយឱ្យទៅនៅស្រុកកៀនស្វាយ ដើម្បីកសាងខ្លួនជាថ្មីឡើងវិញ ។ ពេលនោះ អង្គការស្រុក ក៏បានឱ្យខ្ញុំទទួលការងារ ខាងទំនប់ ប្រឡាយ និងរៀបចំឈណាង់ចាត់ចែងទឹក ។

ខ្ញុំ ក៏បានទទួលការងារថ្មី នៅក្នុងស្រុកកៀនស្វាយ តាំងពីខែ៤.១៩៧៦នោះមក ។

២៦.៧.៧៨ ហើយពេលនេះ ខ្ញុំសូមបញ្ជាក់ជូនបក្សជ្រាប អំពីសាស្ត្រាចារ្យឈ្មោះ កង ឈុំ ដែលជាខ្មែរសេអ៊ីអារបស់ខ្ញុំនៅភ្នំពេញ ។ គឺក្រោយពេលរំដោះភ្លាម ខ្ញុំបានទៀងទៅស្កាត់រកគាត់នៅតាមស្រុកកៀនស្វាយដែលជាផ្លូវធ្វើដំណើរចុះមក និងនៅតាមស្រុកលើកដែកដែលជាស្រុកកំណើតរបស់គាត់ ។ តែប្រពន្ធខ្ញុំឈ្មោះចន្ទសារ៉េនដែលនៅភ្នំពេញ ហើយបានទៅដល់ផ្ទះខ្ញុំនៅស្រុកកោះធំ បានប្រាប់ខ្ញុំថា កង ឈុំ បាននាំគ្រួសារទៅស្រុកខាងប្រពន្ធ នៅស្រុកពាមរ៍ ខែត្រព្រៃវែង តាំងពីថ្ងៃចុះមកដំបូងម្លេះ ។

[signature]
ម៉ឹង តេង

ខែ ៥.១៩៧៦ ខ្ញុំបានទៅជួបតាជ័យ នៅកសិដ្ឋានរដ្ឋអង្គរជ័យ ។ គោលបំណង ដើម្បីរាយការណ៍អំពីផ្ទាល់ខ្លួនរបស់ខ្ញុំ ដែលត្រូវអង្គការដកចេញពីមន្ទីរតំបន់ ឱ្យមកនៅស្រុកកៀនស្វាយ និងដើម្បីបានទទួលការណែនាំពីគាត់ជាថ្មីទៀត ។ ពេលនោះ ខ្ញុំក៏បានប្រាប់គាត់អំពីមូលហេតុ ដែលអង្គការបានដកខ្ញុំ និងអំពីការដែលខ្ញុំត្រូវមកនៅស្រុកកៀនស្វាយ ដើម្បីកសាងខ្លួនជាថ្មី តាមទិសរបស់អង្គការ ។

ពេលនោះ តាជ័យ ក៏បានណែនាំពង្រឹងស្មារតីខ្ញុំ ដោយបានឱ្យខ្ញុំឃើញភារកិច្ចដែលត្រូវអនុវត្តទៅទៀតនៅធ្ងន់ ។ គាត់ណែនាំខ្ញុំ ឱ្យខំក្តាប់ និងបន្តភារកិច្ចឱ្យកាន់តែខ្លាំងថែមទៀត ដើម្បីប្រមូលកម្លាំងធំឱ្យបានទាន់ពេល ។ ដូច តាជ័យបញ្ជាក់ប្រាប់ខ្ញុំ អំពីប្រជាជននៅក្នុងស្រុកកៀនស្វាយ ទាំងយុវជន-នារី សុទ្ធជាសមាសភាពថ្មីដែលទើបតែចេញពីក្រុងភ្នំពេញ ងាយក្តាប់ និងអូសទាញ ។

ដូចហើយ តាជ័យក៏បានណែនាំខ្ញុំឱ្យទាក់ទងជាមួយ ហមម៉េង ឱ្យបានជាប់ ដើម្បីធ្វើសកម្មភាពនៅក្នុងស្រុកបានខ្លាំង ។ ពេលនោះ ហមម៉េង ជាគណៈស្រុកកៀនស្វាយ ។ ហើយគាត់ជាកម្លាំងនៅក្នុងខ្សែរបស់ខ្ញុំ និងខ្សែតាជ័យ ។

បន្ទាប់មក នៅក្នុងខែ៥.១៩៧៦ ខ្ញុំបានជួបគ្រូជាងនៅរោងចក្ររដ្ឋ នៅឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ។ ពេលនោះ ខ្ញុំបានរាយការណ៍ឱ្យគាត់ស្តាប់បានអំពីផ្ទាល់ខ្លួនខ្ញុំ ដែលត្រូវមកនៅស្រុកកៀនស្វាយ និងអំពីកម្លាំងមួយចំនួនធំដែលត្រូវខូចខាតដោយបែកមុខ ហើយត្រូវអង្គការចាប់ខ្លួន ។

បន្ទាប់មក គ្រូជាង បានណែនាំខ្ញុំ អំពីភារកិច្ចដែលត្រូវអនុវត្តទៅមុខទៀត ។ គាត់បានសង្កត់ពេលនោះ អំពីការកសាងកម្លាំងថ្មីឱ្យបានច្រើន ។ ដូចហើយ គាត់ឱ្យខ្ញុំចាប់អារម្មណ៍ចំពោះយុវជនដែលមានច្រើននៅក្នុងស្រុកកៀនស្វាយ ដែលសុទ្ធជាកម្លាំងងាយក្តាប់ និងអូសទាញ ។ បន្ទាប់មក គាត់ក៏ណែនាំខ្ញុំឱ្យទាក់ទងជាប់ជាមួយហមម៉េង ដែលជាគណៈស្រុក ដើម្បីធ្វើសកម្មភាពក្នុងស្រុកមានប្រសិទ្ធិភាព ។

២៦.៧.៧៨

ម៉ឹង តេង

ដូចខែ៥.១៩៧៦នោះ ខ្ញុំក៏បានទៅជួបហមម៉េង ។. ពេលនោះ គាត់ជាគណៈស្រុកហើយទទួលភារៈឃុំភូមិធំ ។ ហើយខ្ញុំ ក៏បានជួបគាត់នៅមន្ទីរឃុំ ។

ពេលនោះ ហម ម៉េង បានណែនាំខ្ញុំឱ្យចុះក្ដាប់កម្លាំងដែលមានស្រាប់នៅក្នុងស្រុកកៀន - ស្វាយ ដើម្បីពង្រឹងថែម និងរួមធ្វើសកម្មភាព ។ ហើយគាត់ឱ្យខ្ញុំណែនាំកម្លាំងនោះធ្វើសកម្មភាពកសាងកម្លាំងក្នុងយុវជនស្រុកឱ្យបានច្រើន ។

កម្លាំងដែលមាននៅក្នុងស្រុកនោះ គឺ:

១- ឈ្មោះ ចាវ
២- " ទៀង
៣- " លឹម
៤- ឈ្មោះ អ៊ីញ
៥- " លីវ

កម្លាំងទាំង៥នេះ ហមម៉េង បានក្ដាប់និងពង្រឹងជាប់រហូតមក ដើម្បីធ្វើសកម្មភាពប្រឆាំង - បក្ស នៅក្នុងស្រុកកៀនស្វាយ ។

